ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 21-Aug-2015, 12:30
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៥**

**ម៉ោង ០៩:០៥នាទី**

**សវនាការលើកទី៣១៣**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម ធូ មណី

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

កញ្ញា ជា ស៊ីវហ៊ាង

កញ្ញា រ៉ូប៊ីន្ទី ក្រូហ្វត៍ *(Ms. Robynne CROFT)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

លោក ស្រ៊ា រតនៈ

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វ៉ិចទ័រ កូប៉េ *(Mr.Victor KOPPE)*

លោក លីវ សុវណ្ណា

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកទួរ វែកគែន
*(Mr. Arthur VERCKEN)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍
*(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក វ៉ែន ពៅ

លោកស្រី ទី ស្រ៊ីនណា

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល | បារាំង |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| លោក អាកទួរ វែកគែន | បារាំង |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោកស្រី ទី ស្រ៊ីនណា | ខ្មែរ |
| លោក ឈុំ សេង (2-TCW-828) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី÷ លោក ឈុំ សេខ** (2-TCW-828)


សួរបន្តដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល ផ្តើមពី ....................................ទំព័រ ៤

សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍ ផ្តើមពី ....................................ទំព័រ ១២

សួរដោយលោកស្រី ទី ស្រ៊ីនណា ផ្តើមពី ....................................ទំព័រ ១៧

សួរដោយចៅក្រម ក្លូឌា ហ្វេនស៍ ផ្តើមពី....................................ទំព័រ ២៣

សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្តើមពី ....................................ទំព័រ ២៦

សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្តើមពី....................................ទំព័រ ៣០

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[១០:២៩:២០]

**ប្រធានអង្គជំនុំ៖**

អញ្ជើញអង្គុយ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះធ្វើសវនាការស្តាប់សក្ខីកម្មសាក្សី ឈុំ សេង ហើយសាក្សី ឈុំ សេង ហ្នឹងមានលោក ឌុច ផារី ដែលជាមេធាវីប្រឹក្សាផង។

ក្រឡាបញ្ជីសវនាការកញ្ញា ជា ស៊ីវហ័ង ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន លើកលែងតែមេធាវីជាតិការពារក្តីឲ្យលោក នួន ជា ដែលនឹងមកយឺតបន្តិចនៅព្រឹកនេះ។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ សាក្សីដែលនឹងត្រូវមកផ្តល់សក្ខីកម្មបន្តបញ្ចប់នៅថ្ងៃនេះគឺ លោក ឈុំ សេង លោក និងមេធាវីប្រឹក្សាលោក ឌុច ផារី មានវត្តមានរួចហើយនៅក្នុងបន្ទប់សវនាការនេះ។

សូមអរគុណលោកប្រធាន។

[១០:៣០:៤២]

**ប្រធានអង្គជំនុំ៖**

បាទ សូមអរគុណ ជា ស៊ីវហ័ង។

ហើយជាដំបូងនេះ អង្គជំនុំជម្រះ សម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលសុំ -- ទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៥ ដែលបានបញ្ជាក់ថា ដោយ

គាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និង ដើម្បីមានលទ្ធភាពចូលរួមសវនាការនៅថ្ងៃមុខខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការនៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៥។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការពិនិត្យព្យាបាល ថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៥ បានកំណត់សម្គាល់ថា ស្ថានភាពសុខភាពរបស់លោក នួន ជា មានអាការៈឈឺចង្កេះហើយជាប្រចាំ និងកាន់តែខ្លាំងនៅពេលធ្វើចលនា ឬអង្គុយយូរ និងបានផ្តល់អនុសាសន៍ថា សូមឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួម តាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ខាងក្រោមសាលសវនាការនេះ។ ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុងអ.វ.ត.ក អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយ ស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយ ស្ថិតនៅខាងក្រោមសាលសវនាការនេះ ក្នុងអំឡុងពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

ជាបន្តអង្គជំនុំជម្រះផ្តល់វេទិការជូនទៅក្រុមសហព្រះរាជអាជ្ញា ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ ហើយអង្គជំនុំជម្រះសូមរំឭកថា សហព្រះរាជអាជ្ញារួមទាំងសហមេធាវីនាំមុខតំណាំងដើមបណ្តឹងរដ្ឋប្បវេណីមានរយៈពេលតែមួយវគ្គនៃសវនាការព្រឹកនេះតែប៉ុណ្ណោះ។

បាទ សូមផ្អាកសិនលោកសហព្រះរាជអាជ្ញារងអន្តរជាតិ។

សូមអញ្ជើញលោកមេធាវី អាកទ្បូរ វែកគេន!

[១០:៣២:៥៨]

**លោក អាកទ្បូរ វែកគែន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំលើកឡើងដោយខ្លី ខ្ញុំចង់ត្រឡប់មកនិយាយអំពីហេតុការណ៍កាលពីម្សិលមិញ ក្រោយពីដំបូន្មានមានរបស់អង្គជំនុំជម្រះ ដែលខ្ញុំបានអានទាំងស្រុងទៅលើសេចក្តី

សម្រេចស្តីពីការបំបែកនីតិវិធីកាលពីថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៤ គឺ E301/9/1 ខ្ញុំបានអានសម្រង់នៃកថាខណ្ឌ៤៤។ លោកប្រធាន នៅក្នុងសេចក្តីសម្រេចនោះខ្ញុំរកមិនឃើញអំពីការពន្យល់ទៅនឹងសំណួររបស់ខ្ញុំអំពីទឡ្ហីករណ៍របស់អង្គជំនុំជម្រះដែលទទួលយកអំពីការដោះស្រាយទៅលើបញ្ហាអតីតមន្ត្រីរដ្ឋការសាធារណរដ្ឋខ្មែរដោយឆ្លងកាត់តាមការបោសសម្អាត។ ខ្ញុំមិនយល់ទេ ខ្ញុំកត់សម្គាល់ឃើញថានៅក្នុងអនុស្សរណៈកាលពីខែតុលាគឺ E318 ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៤ អង្គជំនុំជម្រះបានសរសេរនូវកថាខណ្ឌពីរថា ប្រសិនបើនៅពេលជំនុំជម្រះកើតមានបញ្ហាជាក់លាក់ ជាក់ស្តែងណាមួយកើតឡើងពាក់ព័ន្ធទៅនឹងសច្ចភាពផ្លូវច្បាប់ក្នុងការរៀបចំខ្លួនរបស់មេធាវីការពារក្តីនៅក្នុងការជំនុំជម្រះក្តីនោះ គឺថាមានការសម្រេចករណីទៅតាមករណី។ ដូច្នេះនៅក្នុងស្ថានភាពយើងនេះ គឺមានបញ្ហាពាក់ព័ន្ធនឹងវិសាលភាពនៃការជំនុំជម្រះក្តី។ ខ្ញុំស្តាប់ឮខាងដើមបណ្តឹងរដ្ឋប្បវេណី គាត់បាននិយាយអំពីចំណុចនេះរួចមកហើយ ក៏ប៉ុន្តែខ្ញុំគិតថានេះគឺដើមបណ្តឹងរដ្ឋប្បវេណីទេ មិនមែនជាអង្គជំនុំជម្រះទេដែលបញ្ជាក់។ អ៊ីចឹង ខ្ញុំចង់ឲ្យអង្គជំនុំជម្រះបញ្ជាក់ឲ្យច្បាស់។ សូមបញ្ជាក់ឲ្យបានច្បាស់អំពីកថាខណ្ឌណា ចំណុចណានៅក្នុងសេចក្តីសម្រេចចុះខែមេសា ឆ្នាំ២០១៤ គឺនិយាយអំពីសេចក្តីសម្រេចបំបែកនីតិវិធី ដើម្បីឲ្យខ្ញុំដឹងច្បាស់ថាតើការជំនុំជម្រះក្តីយើងនេះមានវិសាលភាពដល់ត្រង់ណាដែរ។ សូមអង្គជំនុំជម្រះបញ្ជាក់ឲ្យច្បាស់អំពីចំណុចនេះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

[១០:៣៥:៤០]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្ទ្បាឯល៖**

សូមអរគុណ។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។ ខ្ញុំសូមឆ្លើយតបដោយខ្លី ខ្ញុំគិតថា យើងបានចំណាយពេលច្រើនទៅលើបញ្ហានេះ វាប៉ះពាល់ទៅលើម៉ោងរបស់ខ្ញុំ និងម៉ោងរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការសួរទៅលើសាក្សីរូបនេះ។ ខ្ញុំសូមរំឭកបន្ថែមថា ដើម្បីអាចបង្ហាញអំពីអាត្តិភាពនៃនយោបាយចំពោះខ្មាំង និងទាហានលន់នល់ បញ្ហាទាំងអស់ដែលពាក់ព័ន្ធទៅនឹងទាហានលន់នល់ នៅក្នុងការដ្ឋាននៃទំនប់ត្រពាំងថ្ម គឺមានភាពពាក់ព័ន្ធ។ ពីព្រោះថា ដីកាដំណោះស្រាយបាននិយាយអំពីឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញផ្នែកនយោបាយ។ គឺកថាខណ្ឌ១៤១១៧ ដែលនិយាយអំពីចំណុចនេះ។ ដីកាដំណោះស្រាយក៏និយាយអំពីត្រពាំងថ្មដែលបានបញ្ជាក់អំពីការស្វែងរកប្រវត្តិរូបរបស់កម្មករ

ដែលធ្វើការនៅការដ្ឋាន ដើម្បីចង់ដឹងថាតើប្រវត្តិរបស់ពួកគេយ៉ាងម៉េច និងចង់ដឹងថាតើពួកគេជាអតីតមន្ត្រីរដ្ឋការ ទាហាន ឬក៏ទាហានរបបចាស់ដែរ ឬក៏យ៉ាងណា។ ដូច្នេះ ខ្ញុំសូមការអនុញ្ញាតត្រូវការពេលវេលាបន្ថែមប្រហែលជា១០នាទីទៀត លោកប្រធាន ដើម្បីបញ្ចប់ការសួរសំណួរ ពីព្រោះថាមានការជំនួសទៅ ធ្វើឲ្យខាតពេលរបស់ខ្ញុំ។

*(ចៅក្រមពិភាក្សាគ្នា)*

[១០:៣៨:០៧]

**ប្រធានអង្គជំនុំ៖**

បាទ ហើយដោយសារបញ្ហានេះ ក៏មានការស្មុគស្មាញដែរ ដោយសារឯកសារវាធំ ហើយធ្លាប់បានកើតច្រើនដងមកហើយ ហើយអង្គជំនុំជម្រះបានដោះស្រាយបន្តបន្ទាប់ហើយ។ ហើយដោយសារបញ្ហានេះ គឺវាប៉ះពាល់ពេលវេលានៃរបស់ខាងភាគីម្ខាងទៀត ដែលអង្គជំនុំជម្រះផ្តល់ឱកាសក្នុងការតាំងសំណួរដេញដោលចំពោះសាក្សី ដូច្នេះអង្គជំនុំជម្រះឲ្យ អនុញ្ញាតឲ្យក្រុមតំណាងសហព្រះរាជអាជ្ញារួមទាំងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីនូវឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

ដោយឡែកការឆ្លើយតបរបស់ទៅនឹងលោក វែកគែន ដែលបានលើកឡើងអម្បាញ់មិញនេះ អង្គជំនុំជម្រះនឹងជូនតាមរយៈអ៊ីម៉ែល ជូនផ្តល់ការចម្លើយតប សមស្របទៅលោកវិញ តាមរយៈអ៊ីម៉ែលនៅពេលបន្ទាប់ ឆាប់ៗខាងមុខនេះ។

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

[១០:៣៩:១៥]

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរបន្តដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** លោកសាក្សី ខ្ញុំសូមសួរសំណួរលោកបន្តពីម្សិលមិញទៀត។ លោកបានធ្វើការនៅត្រពាំងថ្ម ខ្ញុំមិនសូវយល់ច្បាស់អំពីរយៈកាលដែលលោកធ្វើការនៅទីនោះ។ តើលោកអាចបញ្ជាក់ឲ្យច្បាស់បានទេ ថាតើលោកបានចាកចេញពីត្រពាំងថ្មហ្នឹងប៉ុន្មានខែដែរ មុនពេលវៀតណាមវាយចូល?

**លោក ឈុំ សេង៖**

**ឆ៖** បាទ ខ្ញុំបាទបានចាកចេញប្រហែលជា ៥ទៅ៦ខែ ទៅចម្ការកប្បាសកងវ៉ា ទើបវៀតណាម

វាយចូលដល់ខេត្តសៀមរាប។

**ស៖** នៅពេលដែលលោកចេញពីត្រពាំងថ្ម តើមាននៅសល់ការងារអ្វីខ្លះទៀតនៅត្រពាំងថ្មនុ៎ង ដើម្បីឱ្យបញ្ចប់១០០ភាគរយ? ខ្ញុំដឹងថាទំនប់ហ្នឹង គឺធ្វើហើយៗ ក៏ប៉ុន្តែតើនៅមានការងារអីផ្សេងទៀត ដើម្បីឱ្យចប់រួចរាល់ទាំងស្រុង១០០ភាគរយតែម្តងដែរឬទេ?

**ឆ៖** ក្រៅអាងត្រពាំងថ្ម គឺយើងអាចសម្រេចបានប្រហែលជា៩៥ភាគរយហើយ ក៏ប៉ុន្តែដោយឡែកនៅធ្វើស្ពានទី១, ទី២ និងទី៣។ ស្ពានទាំងអស់នោះ គឺមានបញ្ហា ទី១ គឺខ្វះដែក ខ្វះស៊ីម៉ង់ត៍ ខ្វះអីទាំងអស់ ហើយជាងក៏បែកបាក់មិនដឹងជាទៅណាមកណើ។ ដូច្នេះបានជាគេដកកម្លាំងពីអាងត្រពាំងថ្មហ្នឹង ទៅវាយសម្រុកនៅចម្ការកប្បាសកងវ៉ា។

[១០:៤១:២៧]

**ស៖** ខ្ញុំសូមការបញ្ជាក់តូចមួយពាក់ព័ន្ធទៅនឹងចំនួនពលករនៅការដ្ឋាន។ កាលពីម្សិលមិញ លោកបាននិយាយថា មានប្រហែល១០.០០០នាក់ ហើយលោកបានបែងចែកអំពីអ្នកដែលធ្វើការនៅក្នុងកងចល័តតំបន់៥ និងអ្នកដែលមកពីសហករណ៍ ឬក៏មកពីស្រុកថ្មពួក និងស្រុកព្រះនេត្រព្រះ។ ខ្ញុំចង់ដឹងថា តើនៅក្នុងកងចល័តតំបន់៥ ដែលលោកធ្វើការហ្នឹងមានពលករប៉ុន្មាននាក់ដែរ?

**ឆ៖** រឿងបញ្ហានេះ ខ្ញុំបាទគឺពុំបានរាប់ ហើយពុំបានដឹងចំនួនពិតប្រាកដទេ ក៏ប៉ុន្តែខ្ញុំដឹងច្បាស់តែក្នុងកងរបស់ខ្ញុំ ក្នុងវរៈរបស់ខ្ញុំដែលមានកម្លាំង៣០០នាក់ប៉ុណ្ណោះ។

**ស៖** កាលពីម្សិលមិញប្រហែលជាម៉ោង ១៥:១៤នាទី លោកបាននិយាយថា មានកងពិសេសសម្រាប់តាមដានពលករនៅក្នុងកងដែលចូលរួមក្នុងការសាងសង់ទំនប់ត្រពាំងថ្ម។ ខ្ញុំចង់ដឹងថា តើអ្នកទាំងអស់ហ្នឹងជាអ្នកណា អ្នកដែលតាមដានពលករទាំងអស់ហ្នឹង ហើយពួកអ្នកតាមដានហ្នឹងគេធ្វើយ៉ាងម៉េចខ្លះ?

**ឆ៖** បាទ អ្នកដែលដើរតាមដានហ្នឹង គឺជាភូមិភាគពាយ័ព្យ។ ពេលនោះ អង្គការបញ្ចុះតាមកងមួយម្នាក់ៗ ជាក់ស្តែងដូចនៅក្នុងកងអនុសេនាធំរបស់ខ្ញុំ គឺមានម្នាក់។ សូម្បីតែខ្ញុំក៏មិនដឹងថាគេធ្វើអីដែរ។ គេចុះមកដល់ គឺគេជួយកាប់ដីយើង ហើយគេសួរទាក់ទងនឹងប្រវត្តិរបស់យើងពីសម័យលន់ នល់ តើយើងធ្វើអី តែប៉ុណ្ណឹងទេ។

[១០:៤៣:៤៩]

**ស៖** នៅក្នុងកងធំរបស់លោក តើមានគេស្វែងរកឃើញអំពីអតីតកាលរបស់ពួកគាត់ ហើយ

បន្ទាប់មកមានអ្នកណាបាត់ខ្លួនទេ?

**ឆ៖** បាទ នៅក្នុងកងរបស់ខ្ញុំបាត់ខ្លួនពីរនាក់ ទី១ គឺឈ្មោះ ផុន, ទី២ គឺឈ្មោះ រ៉ុម។ ដោយគេលាក់ប្រវត្តិរូបមិនជិតក៏មិនដឹង ក៏ប៉ុន្តែបើតាមខ្ញុំដឹងច្បាស់ រូបផុន ហ្នឹងគេធ្វើទាហានលន់នល់ ពាក់ស័ក្តិ២ ហើយមួយទៀតហ្នឹង គេនិយាយថា ឪពុកម្តាយគេជាកូនអ្នកមាន គេជាកូនរបស់នាយទុន សក្តិភូមិ។ ដូច្នេះ យប់ឡើងក៏ពួកទាហាន បើនិយាយឲ្យខ្លីទៅ គឺពួកយោធារបស់ៗខ្មែរក្រហមហ្នឹង គឺចាប់យកទៅ។

**ស៖** លោកដឹងថា គេយកអ្នកទាំងអស់នោះទៅណាទេ ឬក៏លោកមិនធ្លាប់ដឹងរឿងនេះទេ?

**ឆ៖** បាទ ឃើញតែបាត់ខ្លួនពីកន្លែងខ្ញុំអត់ដឹងថា គេយកទៅណាទេ។ តែរយៈពេលដែលយកទៅគឺមិនឃើញវិលត្រឡប់មកអង្គភាពវិញ។

**ស៖** កាលពីម្សិលមិញ យើងនិយាយអំពីការចាប់ខ្លួន និងការសម្លាប់មនុស្សនៅទំនប់។ នៅក្នុងបទសម្ភាសន៍របស់លោកជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា លោកបានលើកឡើងអំពីបុរសម្នាក់ ដែលជាក្មួយរបស់ អ៊ុន តាំ តើលោកអាចបញ្ជាក់បានទេ ថាមានរឿងអ្វីកើតឡើងចំពោះក្មួយប្រុសរបស់ អ៊ុន តាំ នេះ?

**ឆ៖** បាទ ក្មួយប្រុសម្នាក់របស់ អ៊ុន តាំ នោះ ខ្ញុំអត់ដឹងថាឈ្មោះអីពិតប្រាកដទេ ក៏ប៉ុន្តែខ្ញុំហៅវាតែអាម៉ាប់ៗ។ អាម៉ាប់ ហ្នឹងវានៅជាមួយខ្ញុំ ក្រោយមកវាក៏សុំខ្ញុំផ្ទាល់ថា "ខ្ញុំទៅរកមារបស់ខ្ញុំ"។ ហើយខ្ញុំសួរថា "តើមាឯងនៅឯណា?" ថា "មាខ្ញុំ ឈ្មោះ អ៊ុន តាំ នៅប្រទេសថៃ"។ ពេលដែលសុំទៅខ្ញុំក៏មិនបានឲ្យវាទៅដែរ ក៏ប៉ុន្តែវាក៏លួចទៅប្រទេសថៃ។ ទៅបានរយៈពេលប្រហែលជាងមួយអាទិត្យក៏ត្រឡប់មករកខ្ញុំវិញ ហើយឃើញមានស្នាមរបួសដៃ ថាទៅដល់ជិតកន្លែងត្រង់ណាដែលវាមិនស្គាល់ស្រាប់តែពួកយោធាហ្នឹងដេញបាញ់វា ក៏ប៉ុន្តែវារត់រួច។

[១០:៤៧:០៦]

**ស៖** ពេលដែលគាត់ត្រឡប់មកវិញហ្នឹង តើគេចាប់ខ្លួនគាត់ ឬក៏គេដាក់បញ្ចូលគាត់ទៅក្នុងកងរបស់លោកវិញ?

**ឆ៖** បាទ មកដល់ហ្នឹង គឺគ្មានអ្នកណាដឹងម្នាក់ក្រៅពីរូបខ្ញុំ។ ដូច្នេះ ខ្ញុំពុំបានរាយការណ៍ទៅណាខ្ញុំក៏លាក់វាទុកនៅកងរបស់ខ្ញុំទៅ។

**ស៖** នៅក្នុងបទសម្ភាសន៍របស់លោកជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា គឺលេខ E3/9010 គឺទំព័រ៣០ ជាបារាំង, ៣២ ជាភាសាអង់គ្លេស, ៥៥ ជាភាសាខ្មែរ។ លោកបាននិយាយថា មានមនុស្ស

ពីរនាក់ដែលបានចាកចេញទៅ ហើយម្នាក់ត្រូវបានគេសម្លាប់ចោល។ អ៊ីចឹងលោកអាចបញ្ជាក់បានទេថា ពេលដែលចាកចេញទៅហ្នឹង គឺក្មួយរបស់ អ៊ិន តាំ គាត់ចេញទៅមនុស្សម្នាក់ទៀត ហើយម្នាក់នោះត្រូវបានគេសម្លាប់ចោល។ តើអ៊ីចឹងមែនទេ?

**ឆ៖** រឿងទាំងអស់ហ្នឹង គឺឈ្មោះ ម៉ាប់ មកប្រាប់ខ្ញុំថា ទៅពីរនាក់ ក៏ប៉ុន្តែម្នាក់ហ្នឹងត្រូវទាហានរបស់ខ្មែរក្រហមនោះបាញ់ស្លាប់ ហើយគេហ្នឹងបានមកដល់កន្លែងខ្ញុំវិញ។

**ស៖** តើមានអ្នកណាផ្សេងទៀត ដែលត្រូវបានចាប់ខ្លួន និងសម្លាប់ចោល នៅពេលដែលលោកធ្វើការនៅត្រពាំងថ្មនោះ ទោះបីជានៅក្នុងកងរបស់លោក ឬក៏នៅក្នុងវរសេនាតូចណាផ្សេងទៀត ក៏ដោយឲ្យតែលោកដឹង។

**ឆ៖** បាទ នៅកងខ្ញុំបាត់តែពីរនាក់ ក្រៅពីហ្នឹង កងផ្សេងៗ គឺខ្ញុំពុំបានដឹងទេ ដឹងតែកងសម្រាប់កងខ្ញុំប៉ុណ្ណោះ។

[១០:៤៩:២០]

**ស៖** ខ្ញុំសូមរំឭកការចងចាំរបស់លោក។ នៅក្នុងបទសម្ភាសន៍ដែលលោកបានផ្តល់ជូនមជ្ឈមណ្ឌលឯកសារកម្ពុជា គឺឯកសារE3/9010 នៅទំព័រ៣១ ជាភាសាបារាំង, ៣៣ ជាភាសាអង់គ្លេស និង ៥៦ ទៅដល់ ៥៧ ជាភាសាខ្មែរ។ លោកបាននិយាយដូចតទៅ ខ្ញុំសូមដកស្រង់៖ “កម្មករជាច្រើនត្រូវបានសម្លាប់ចោល”។ បន្ទាប់មកលោកបញ្ជាក់ថា មានមនុស្សម្នាក់ដែលលោកស្គាល់នោះ លោក ហៅគាត់ថា តាញ៉ូប។ ខ្ញុំមិនដឹងឈ្មោះគាត់ទេ គាត់ត្រូវបានគេបញ្ជូនចេញទៅ”។ ចុះបន្តមកទៀតគាត់បាននិយាយថា៖ “បីនាក់ត្រូវបានគេបញ្ជូនទៅឲ្យកប់សព នៅក្រោមស្ពានទី៣” ហើយលោកបាននិយាយថា លោកបានឮគេនិយាយថា មានមាស មានគ្រឿងអលង្ការមាស”។ បន្ទាប់មកលោកក៏បានបន្តទៀតថា៖ “បងប្អូនណាមានមាសអ៊ីចឹង ត្រូវតែយកមកជូនអង្គការទាំងអស់ បើអង្គការឆែកឆេរឃើញថាមិនប្រគល់ទេ គឺគេនឹងសម្លាប់ចោល។ ក៏ប៉ុន្តែក៏មានអ្នកខ្លះហ្នឹង ក៏មានលាក់ទុកមិនឲ្យផងដែរ”។ តើលោកនៅចាំថា លោកមានស្គាល់នរណាម្នាក់ដែលមានលាក់គ្រឿងអលង្ការ ឬក៏លាក់មាសអ៊ីចឹង ហើយមិនព្រមប្រគល់ជូនទៅឲ្យសហករណ៍ហ្នឹងហើយត្រូវបានគេចាប់ខ្លួនទេ?

**ឆ៖** បាទ នៅក្នុងកងខ្ញុំ មានម្នាក់ហ្នឹង គឺភ្នែកគាត់មីញ៉ូប ដោះវ៉ែនតាចេញ គឺមើលអ្វីមិនឃើញទេ ពេលនោះគាត់គ្រុនឈឺ ក៏ដេកនៅនឹងកន្លែង ស្រាប់តែបាត់បីថ្ងៃ ខ្ញុំសួរថា៖ “ឯណាបាត់តាដែលភ្នែកមីញ៉ូបទៅណា?” ដល់បន្តិចនោះគេថាៗ “គ្រុន”។ ក្រោយមកទៀតទើបពួកសេដ្ឋកិច្ច ពួកដាំបាយទៅ

ប្រាប់ខ្ញុំថា “តាវ៉ែនតាហ្នឹងស្លាប់បាត់ទៅហើយ”។ បាទ ដល់ស្លាប់បាត់ទៅហើយខ្ញុំក៏មកមើល ដល់មើលទៅឃើញស្លាប់ ក៏ឲ្យមនុស្សបីនាក់សែងយកទៅកប់នៅខាងត្បូងស្ពានទី៣ ចម្ងាយប្រមាណជា១៥០ម៉ែត្រ។ ពេលដែលកប់ហើយស្រាប់តែម្នាក់ហ្នឹងនៅដេកក្បែរថា៖ “បងឯងមិនបានឃើញមាសគាត់ទេ?” ថា៖ “ ខ្ញុំមិនបានឆែកឆេរទេ” ក៏ប៉ុន្តែអ្នកដែលសែងទៅ អ្នកដែលនេះទៅថា ឃើញមាសហ្នឹងពីរបីខ្សែ ហើយធាតុ មិនដឹងជាធាតុម៉ែ ឬឪគាត់ មានរូបថតបងប្អូន។ បាទនេះ សម្រាប់អ្នកយកទៅកប់គេនិយាយប្រាប់ខ្ញុំ។

[១០:៥២:១១]

**ស៖** សូមអរគុណលោកសាក្សី។ តាញ៉ុប ដែលលោកនិយាយហ្នឹង តើគាត់ស្លាប់ដោយសារជំងឺ ឬស្លាប់ដោយសារគេចាប់ខ្លួនហើយសម្លាប់?

**ឆ៖** បាទ ឈ្មោះ គាត់ដែលភ្នែកមីញ៉ុបហើយ ដែលខ្ញុំហៅតែតាវ៉ែនតាហ្នឹង គឺជំងឺរបស់គាត់គឺគ្រុន ដេកគ្រុន ហើយក៏ស្លាប់នៅនឹងកន្លែង។

**ស៖** សូមអរគុណ។ តើថ្នាក់លើមានចេញសេចក្តីណែនាំអំពីរបៀបរបបនៃការធ្វើ ការអនុវត្តចំពោះអ្នកដែលមិនព្រមស្តាប់បង្គាប់ ឬក៏អ្នកជំទាស់ ឬប្រឆាំងនឹងអង្គការទេ?

**ឆ៖** បាទ សម្រាប់ថ្នាក់លើ គឺគ្រាន់តែបញ្ជាក់ប្រាប់ថា បើសិនជាអ្នកណាក្បត់អង្គការ អ្នកណាមិនធ្វើតាមបង្គាប់បញ្ជារបស់អង្គការ គឺត្រូវតែសម្លាប់ចោល។

**ស៖** នៅក្នុងកងចល័តតំបន់៥ តើមាន “កងករណី” ដែលគេបញ្ជូនអ្នកដែលធ្វើការមិនសូវបានល្អ ទៅទីនោះ ដើម្បីអប់រំកែប្រែទេ លោកធ្លាប់ឮគេនិយាយអំពី “កងករណី”ហ្នឹងទេ?

**ឆ៖** បាទ ខ្ញុំធ្លាប់ឮហើយមេកងគេនោះគឺឈ្មោះ ស្រេះ។ ដូច្នេះ អ្នកទាំងអស់ហ្នឹង គឺដូចជាថាមានការតវ៉ាខ្លះៗ ពីអង្គការទើបគេប្រមូលម្តុំយកទៅដាក់ឲ្យឈ្មោះ មិត្តស្រេះ ហ្នឹង ជាអ្នកគ្រប់គ្រង។ នេះសម្រាប់ការលើកអាងទឹកត្រពាំងថ្ម។

**ស៖** ដូច្នេះ តើនៅក្នុងកងនេះ គេធ្វើយ៉ាងម៉េច គេឲ្យកម្មករហ្នឹងធ្វើការធ្ងន់ ហើយបានហូបតិចជាងគេឬក៏យ៉ាងម៉េច?

**ឆ៖** បាទ ការហូបចុកដូចតែគ្នា ក៏ប៉ុន្តែមនុស្ស ដូចថាត្រីកំភ្លាញស្លាប់ដោយសារមាត់ “ដីម៉ែឪអញៗនៅមិនដែលបានមកតស៊ូអីប៉ុណ្ណឹង ធ្វើបាប ឯណាធ្វើឲ្យធ្វើពលកម្មរែកដីវាល់ព្រឹកវាល់ល្ងាច ឲ្យបាយស៊ីមិនឆ្អែត” គ្រាន់តែគ្នានិយាយប៉ុណ្ណឹង គេចោទថាយើងករណីប្រឆាំងនឹងអង្គការ ទើបគេប្រមូល

យើងទៅដាក់ម្ដុំ ដើម្បីងាយស្រួលក្នុងអ្នកដែលតវ៉ា ឬប្រឆាំងនឹងអង្គការ។

[១០:៥៥:៣៨]

**ស៖** លោកបាននិយាយថាមានកងចល័តតំបន់៥ និងមានកងផ្សេងៗទៀតដែលមានសហករណ៍នៃស្រុកផ្សេងៗដែលនៅក្បែរនោះ។ ដូច្នេះ ខ្ញុំចង់ដឹងថារបបអាហារដែលគេចែកជូនកម្មករហ្នឹងមានភាពខុសគ្នាទេរវាងកងចល័តតំបន់៥ និងកងផ្សេងៗដែលមកពីសហករណ៍នៃស្រុកក្បែរៗនោះ?

**ឆ៖** បាទ ចំពោះកងចល័តមកពីសហករណ៍ ខ្ញុំបាទពុំបានដឹងទេ មិនដឹងជាជីវភាពរស់នៅរបស់គាត់ ការហូបចុកមិនដឹងយ៉ាងណាទេ។ ហើយចំពោះខ្ញុំដឹងតែសម្រាប់កងចល័តតំបន់៥ ជាពិសេសគឺកងខ្ញុំផ្ទាល់តែម្ដង។

**ស៖** លោកបានឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជាគឺឯកសារ E3/9010, ទំព័រ១៩ ជាភាសាបារាំង, ២០ ជាភាសាអង់គ្លេស និង៣២ជាភាសាខ្មែរ។ លោកនិយាយអំពីសហករណ៍ ហើយលោកបានបញ្ជាក់ថា "ពួកគេខ្វះខាតអាហារ ពីព្រោះថាមិនមានជំនួយពីសហករណ៍ចល័តតំបន់ គឺសហករណ៍ខ្លួនឯងជាអ្នកដោះស្រាយបញ្ហាហូបចុកដោយខ្លួនឯង"។ ហើយបន្ទាប់មកទៀត គេសួរលោកទៀតថា អ៊ីចឹងគឺសហករណ៍ដោះស្រាយបានច្រើន ក៏បានហូបទៅអ៊ីចឹងមែនទេ? ហើយលោកក៏បានឆ្លើយថា "បាទ គឺវាអាស្រ័យលើសហករណ៍ បើសហករណ៍ដោះស្រាយមិនទាន់ទេ គ្នាក៏ហូបបបរអ៊ីចឹងទៅ គឺបបររាវ"។ សូមបញ្ចប់ការដកស្រង់។ តើលោកបានឃើញពលករដែលធ្វើការនៅត្រពាំងថ្មហ្នឹង គឺខ្ញុំចង់សំដៅទៅពលករដែលមកពីកងចល័តសហករណ៍នោះ តើរាងកាយគាត់ហ្នឹងយ៉ាងម៉េចដែរ លោកមានបានសង្កេតឃើញទេ?

**ឆ៖** បាទ ពេលហ្នឹងសហករណ៍ក្នុងស្រុកថ្មពួក គឺជាប់នឹងកងរបស់ខ្ញុំ។ ពេលនោះខ្ញុំស្គាល់ថ្នាក់ដឹកនាំគេម្នាក់ឈ្មោះ ខាន់ ហើយខ្ញុំក៏បានទៅជួបគាត់។ ហើយបើយើងពិនិត្យទៅលើកម្មករហ្នឹងគឺទៅលើអ្នករែកដី បើនិយាយឲ្យខ្លីទៅគឺថាមានរូបរាងស្គមៗជាងកងចល័តតំបន់ទៅទៀត។

**ស៖** សូមអរគុណលោកសាក្សី ខ្ញុំមិនសល់ពេលច្រើនទៀតទេ។ កាលពីម្សិលមិញលោកបាននិយាយអំពីការលំបាកក្នុងការហូបទឹកស្អាត លោកប្រាប់ថាគេឲ្យទឹកតែនៅពេលហូបចុកទេ គឺគេដឹកតាមឡានមក ហើយទឹកនោះមិនមែនជាទឹកថ្លាទេ គឺជាទឹកល្អក់ខ្វល់។ តើលោកមានព្យាយាមជីករណ្ដៅ -- ជីក សូមទោស ជីកអណ្ដូងដើម្បីរកទឹកទេ?

**ឆ៖** បាទ នៅពេលហ្នឹងនៅក្នុងកងខ្ញុំគឺមានចាត់តាំងឲ្យជីកៗរណ្ដៅ ក៏ប៉ុន្តែជីកធ្វើអណ្ដូងជម្រៅ

១ម៉ែត្រ ឬក៏ជាងមួយម៉ែត្រ ក៏ប៉ុន្តែទឹកចេញពុំបានគ្រប់គ្រាន់។ ជួនកាលបានមួយប៉ោត ជួនកាលបានបីផ្តិលក៏មាន។ ដូច្នេះទឹកមិនគ្រប់ ទើបបានឡានដោះដឹកយកមកចែកចាយទៅតាមកង តាមវរៈ។

[១១:០០:២១]

**ស៖** ពាក់ព័ន្ធនឹងលក្ខណការងារនៅត្រពាំងថ្ម ខ្ញុំចង់អានសម្រង់មួយចេញពីទស្សនាវដ្តីនៅសម័យនោះ គឺទស្សនាវដ្តីរបស់កម្ពុជាប្រជាធិបតេយ្យដែលមានឈ្មោះថា "យុវជន-យុវនារីបដិវត្ត" ដែលបាននិយាយអំពីលក្ខខណ្ឌការងារ ហើយនិងការខ្វះខាតទឹកស្អាត។ លោកប្រធាន គឺឯកសារនោះលេខ E3/771 ចុះខែកក្កដា-សីហា ឆ្នាំ១៩៧៧ ទំព័រពាក់ព័ន្ធជាភាសាបារាំងគឺ 00594053 ទៅដល់ 55, ERN ជាភាសាអង់គ្លេស 00509686 ទៅដល់ 87, ជាភាសាខ្មែរគឺ 00376343 ទៅដល់ 45។ ខ្ញុំនឹងដកស្រង់នូវសម្រង់មួយចំនួននៅក្នុងទំព័រទាំងបីនេះ ហើយបន្ទាប់មកខ្ញុំនឹងសូមឱ្យលោកឆ្លើយតបទៅនឹងអ្វីដែលបានសរសេរ។ ខ្ញុំសូមដកស្រង់ "ការដ្ឋាននេះ បងប្អូនចាប់បើកនៅថ្ងៃ១៦ ខែកុម្ភៈ ឆ្នាំ១៩៧៧"។ នៅទំព័របន្ទាប់មកទៀត "ក្នុងរយៈកាលវាយសម្រុកធ្វើប្រព័ន្ធសំណង់ចាត់ចែងទឹកត្រពាំងថ្មកន្លងមកនេះ យុវជន-យុវនារីសហករណ៍យើងនៅតំបន់បាត់ដំបងខាងជើងបានយកអស់កម្លាំងកាយ កម្លាំងចិត្តរបស់ខ្លួន និងបានលះបង់នូវអ្វីៗទាំងអស់ដើម្បីបម្រើផលប្រយោជន៍រួមរបស់សមូហភាព និងសម្រេចផែនការរបស់បក្សឱ្យបានជោគជ័យទាំងស្រុង។ បងប្អូនរស់នៅធ្វើការត្រាំត្រែងនៅលើការដ្ឋានរាប់ខែ។ បងប្អូនប្រយុទ្ធកាប់ដី រែកជញ្ជូនដីទាំងយប់ទាំងថ្ងៃក្រោមកំដៅថ្ងៃចែងចាំងពេញមួយរដូវប្រាំង អត់ដែលត្អូញត្អែរមួយអឺសឡើយ ផ្ទុយទៅវិញនៅគ្រប់ពេលធ្វើការទាំងអស់ បងប្អូនរីករាយជាប់ជានិច្ច"។ បន្ទាប់មកគឺចុះមកក្រោមមក "ជាក់ស្តែង គឺប្រយុទ្ធនឹងការខ្វះខាតទឹកប្រើប្រាស់ ព្រោះរទេះ និងឡានដឹកជញ្ជូនទឹកដឹកយកមកផ្តល់ជូនមិនទាន់ និងមិនគ្រប់តាមសេចក្តីត្រូវការនោះទេ"។ សូមបញ្ចប់ការដកស្រង់។ សំណួរទី១ពាក់ព័ន្ធទៅនឹងសម្រង់ទាំងនេះ តើលោកឯកភាពជាមួយនឹងទស្សនាវដ្តីនេះទេ ដែលថាពលករធ្វើការដោយរីករាយក្នុងអំឡុងពេលសាងសង់នោះ ទោះបីជាធ្វើការក្រោមកម្តៅថ្ងៃក្តៅហែងទាំងយប់ទាំងថ្ងៃក៏ដោយនោះ? តើលោកមានសង្កេតឃើញអ៊ីចឹងទេ ថាកម្មករ ពលករហ្នឹង គាត់ធ្វើការដោយសប្បាយរីករាយណាស់?

[១១:០៣:៥២]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញមេធាវី គង់ សំអុន!

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមធ្វើការកត់សម្គាល់មួយ មិនមែនជាការជំទាស់ទេ។ ដោយហេតុថាសាក្សីរូបនេះបានឆ្លើយខាងដើមអំពីពេលវេលាដែលលោកមកធ្វើការនៅទំនប់ត្រពាំងថ្មនោះ មានពេលវេលាខុសគ្នាពីការចាប់ផ្តើមសាងសង់ដំបូង។ ដូច្នេះការបញ្ជាក់ផ្សេងៗពាក់ព័ន្ធទៅនឹងការងារនៅក្នុងទំនប់ត្រពាំងថ្មនេះ វាអាចមានការមិនត្រឹមត្រូវ មិនស្របគ្នា។ បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សាក្សីឆ្លើយតបនឹងសំណួរ។

**លោក ឈុំ សេង៖**

**ឆ៖** រឿងការងារទាំងអស់ ខ្ញុំចាំបានគឺដូចដែលខ្ញុំនិយាយ។

[១១:០៥:០០]

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** សំណួរអម្បាញ់មិញនេះ ខ្ញុំចង់ដឹងថាៗតើកម្មករ ពលករហ្នឹង គាត់ធ្វើការដោយសប្បាយរីករាយមែនទេ ទោះបីជាត្រូវធ្វើការក្រោមកម្តៅថ្ងៃ ធ្វើការទាំងយប់ទាំងថ្ងៃមិនសូវមានពេលសម្រាកក៏ដោយនោះ?

**ឆ៖** បាទ ពុំពិតទេ ព្រោះធ្វើការក្រោមកម្តៅថ្ងៃ ហើយរបបអាហារមិនគ្រប់ធ្វើការនេះ ក្នុងនាមខ្លាចស្លាប់ ខ្លាចអង្គការយកទៅសម្លាប់តែប៉ុណ្ណោះ។

**ស៖** តើពលករមានជម្រើសក្នុងការប្រកែកថា អត់ទេ ខ្ញុំមិនចង់ធ្វើការក្រោមកម្តៅថ្ងៃក្តៅហែងអីចឹងអី គាត់អាចប្រកែកអីចឹងបានទេ?

**ឆ៖** បាទ ពុំប៊ានប្រកែកទេ ព្រោះអ្នកប្រកែកបានន័យថាអ្នកប្រឆាំងនឹងអង្គការ ដូច្នេះគឺត្រូវតែស្លាប់ហើយ ពេលនោះ។

**ស៖** នេះជាសំណួរចុងក្រោយរបស់ខ្ញុំ ក្នុងអំឡុងពេលវាយសម្រុកសាងសង់ទំនប់ត្រពាំងថ្ម តើកម្មករ ពលករ មានសិទ្ធិចាក់ចេញពីកន្លែងធ្វើការ ហើយទៅលេងក្រុមគ្រួសារបានតាមចិត្តចង់ទេ?

**ឆ៖** ពេលនោះ សូម្បីតែឆ្លងពីកងមួយទៅកងមួយក៏មិនបានដែរ ដូច្នេះគ្មានសិទ្ធិឯណាដែលសុំច្បាប់គេបានទៅផ្ទះទៅសម្លែងឡើយ។

[១១:០៧:១២]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្ហាងលៈ**

ខ្ញុំអស់ពេលដើម្បីសួរលោកហើយ លោកសាក្សីទោះបីជាខ្ញុំនៅមានសំណួរបន្ថែមក៏ដោយ។

សូមអរគុណលោកប្រធាន ខ្ញុំអស់សំណួរហើយ។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍ៈ**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍ៈ**

**សៈ** ជម្រាបសួរលោកសាក្សី ខ្ញុំឈ្មោះ ម៉ារី ហ្គីរ៉ូដ៍។ ខ្ញុំជាមេធាវីនាំមុខ ហើយខ្ញុំមានសំណួរបន្តិចបន្តួចទេ ដើម្បីសួរបន្ត ហើយនិងលើកពីចំណុចមួយចំនួនឡើង ដើម្បីសួរបំភ្លឺពីលោក។ ខ្ញុំចង់ដឹងថា តើមានអ្នកឈឺដែរឬទេនៅក្នុងកងដែលលោកគ្រប់គ្រងនោះ?

**លោក ឈុំ សេងៈ**

**ឆៈ** បាទ នៅកងរបស់ខ្ញុំឈឺជាប្រចាំ ក៏ប៉ុន្តែជួនកាលក៏ឈឺតិច ជួនកាលក៏ឈឺច្រើន។

**សៈ** តើគេមានជំងឺអីខ្លះ?

**ឆៈ** ជំងឺសំខាន់បំផុតគឺ ជំងឺស្គមរីងរៃ ជំងឺអត់អាហារបណ្ដោយ មានការហើម មានការស្គម មូលហេតុគឺអាហារពុំគ្រប់គ្រាន់។

**សៈ** តើមានបុគ្គលិកដែលមកពិនិត្យអ្នកជំងឺទេ ឬក៏អ្នកដែលប្រាប់ថាខ្លួនឈឺនោះ?

**ឆៈ** បាទ នៅពេលហ្នឹងគឺមានពេទ្យ ក្នុងមួយកងមានគឺម្នាក់ ក៏ប៉ុន្តែឈឺអីក៏ដោយគេឲ្យថ្នាំមួយគ្រាប់។ ថ្នាំនោះដូចជារាងអាចម៍ទន្សាយ ឈឺក្បាលក៏ថ្នាំនោះ ឈឺពោះក៏ថ្នាំនោះ ហើមក៏ថ្នាំនោះ បានន័យថាថ្នាំហ្នឹងវាត្រូវចូលមួយរយជំពូកទៅហើយ។ ឈឺគឺគេឲ្យតែថ្នាំមួយមុខហ្នឹង ក្រោយពីថ្នាំហ្នឹងគឺគ្មាន។

[១១:០៩:៤២]

**សៈ** តើលោកមានទទួលបានបញ្ជាជាក់លាក់ពីថ្នាក់លើ ពាក់ព័ន្ធនឹងអ្នកជំងឺដែរឬទេ? តើអ្នកជំងឺទាំងអស់នោះ គេប្រព្រឹត្តទៅលើយ៉ាងម៉េចដែរ? គេឲ្យគាត់សម្រាក ឬឲ្យត្រូវតែធ្វើការ? តើលោកអាចជម្រាបជូនតុលាការបានដែរឬទេ? គេមានចេញបទបញ្ជាយ៉ាងម៉េចខ្លះ? ថ្នាក់លើចេញបទបញ្ជាយ៉ាងម៉េចខ្លះពាក់ព័ន្ធនឹងឈឺទាំងអស់នេះ?

**ឆ៖** បាទ អ្នកដែលឈឺធ្ងន់ក្រោកមិនរួចអីមិនរួច ទើបគេបញ្ជូនទៅពេទ្យ។ ពេទ្យហ្នឹង គឺកាលខ្ញុំនៅ គឺពេទ្យនៅក្នុងវត្តត្រពាំងថ្ម។ តែអ្នកដែលឈឺល្មមៗ គេឱ្យតែថ្នាំនោះលេប បើក្រោកទៅធ្វើការមិនរួច ក៏សម្រាកសិនទៅ មិនជាអីទេ។ ក៏ប៉ុន្តែគេនៅតែតាមដានយើង ក្រែងយើងឈឺសតិអារម្មណ៍។

**ស៖** ខ្ញុំរៀបនឹងសួរសំណួរទៅលោកទាក់ទងនឹងពាក្យ "ជំងឺសតិអារម្មណ៍"ហ្នឹង។ ព្រោះយើងឮពាក្យ "ជំងឺសតិអារម្មណ៍" ហ្នឹងច្រើនដងហើយ។ អ៊ីចឹងចំពោះលោកនោះ ពេលដែលលោកនិយាយថា ជំងឺសតិអារម្មណ៍ហ្នឹង មានន័យយ៉ាងម៉េចដែរ ហើយពួកគាត់ហ្នឹង មានជោគវាសនាយ៉ាងម៉េចដែរ?

**ឆ៖** បាទ ជំងឺសតិអារម្មណ៍ គឺយើងមិនឈឺ យើងប្រាប់គេថាយើងឈឺ។ ហើយវាសនារបស់គាត់ បើសិនជាគាត់មិនមែនឈឺ គេឱ្យយើងដេកនៅនោះ។ បើឈឺ ទាល់តែយើងហើម ឬក៏ដើរមិនរួច ហើយអាហ្នឹង បានគេបញ្ជូនទៅពេទ្យតែប៉ុណ្ណឹង។

[១១:១១:៤២]

**ស៖** តើអ្នកណាជាអ្នកសម្រេចថា អ្នកហ្នឹងជាអ្នកឈឺមែនទែន មិនមែនអ្នកជំងឺសតិអារម្មណ៍ទេ។ ខ្ញុំសួរលោកថា អ្នកណាជាអ្នកសម្រេចអ៊ីចឹង?

**ឆ៖** ពេលហ្នឹង គឺជាសកម្មភាពរបស់ដែលយើងធ្វើ ព្រោះគេមានមនុស្សតាមដានយើងរហូត។ ពេលដែលយើងឈឺគឺយើងដេកទៅ។ ជួនកាល អ្នកមួយចំនួន ពេលដែលថាឈឺ គេទៅធ្វើអស់ ក៏មានការក្រោកដើរទៅរកជីកកណ្តុរ រកក្តាម ឬក៏ដេកនិយាយ ប្រឡែងគ្នាអីក៏មាន។ ដូច្នេះ មនុស្សជំពូកហ្នឹងឯងដែលគេចាត់ទុកថាឈឺសតិអារម្មណ៍។

**ស៖** តើលោកធ្លាប់មានទទួលបញ្ជាឱ្យដាក់ទណ្ឌកម្មលើអ្នកដែលគេហៅថាមានជំងឺសតិអារម្មណ៍ហ្នឹងដែរឬទេ?

**ឆ៖** បាទ ចំពោះនៅក្នុងកងខ្ញុំ គឺភាគតិចណាស់ដែលឈឺចុះ។ តែសម្រាប់ចំពោះខ្ញុំ ពុំដែលមានទណ្ឌកម្មអីដាក់ទៅលើកម្លាំងរបស់ខ្ញុំទេ។

**ស៖** កាលពីម្សិលមិញ លោកបានពន្យល់ថា លោកត្រូវរាយការណ៍ ឬក៏ត្រូវតាមដានអ្នកធ្វើការហ្នឹង យ៉ាងហោចណាស់ឱ្យម្នាក់ ហើយក្រោយមករាយការណ៍ទៅថ្នាក់។ អ៊ីចឹង ខ្ញុំសួរលោកថាតើលោកមានទទួលបទបញ្ជាពីថ្នាក់លើមក ឱ្យតាមដានអ្នកមានជំងឺសតិអារម្មណ៍ហ្នឹងដែរឬទេ?

**ឆ៖** បាទ ខ្ញុំបានប្រជុំ ពេលនោះគឺប្រធានកងទាំងអស់គឺប្រជុំ ដែលតាវ៉ាល់ ប្រជុំផ្ទាល់។ ហើយតាវ៉ាល់ ដាក់បញ្ជាថា ក្នុងនាមយើងម្នាក់ជាកម្មាភិបាលត្រូវតាមដានកូនកងមួយថ្ងៃឱ្យបានម្នាក់ ជាពិសេស

គឺអ្នកដែលមានប្រវត្តិរូបមិនល្អ ហើយនិងបើនិយាយឲ្យខ្លីទៅ សកម្មភាពទាំងអស់ដែលប្រឆាំងអង្គការ។

[១១:១៤:២៦]

**ស៖** នៅពេលដែលលោកនិយាយថា សកម្មភាពប្រឆាំងនឹងអង្គការនេះ លោកអាចផ្តល់ឧទាហរណ៍បានដែរឬទេ តើសកម្មភាពបែបណាខ្លះដែលគេចាត់ទុកថា សកម្មភាពប្រឆាំងនឹងអង្គការហ្នឹង?

**ឆ៖** បាទ សកម្មភាពប្រឆាំងនឹងអង្គការ គឺមានច្រើនបើគិតទៅ។ សូម្បីតែដេកយប់ ក៏គេមិនឲ្យនិយាយគ្នាខ្សឹបៗដែរ ម៉ោងដេកគឺត្រូវតែដេក។ ហើយយើងនិយាយថា "អូ៎! រែកដីនេះ គឺពិបាកណាស់។ ពិបាកធ្ងន់ធ្ងរ ពលកម្មហួសហេតុ បាយហូបមិនគ្រប់"។ អីទាំងអស់នេះ គឺសុទ្ធជាសកម្មភាពប្រឆាំងនឹងអង្គការហើយមិនស្តាប់អង្គការចាត់តាំង។ អង្គការចាត់តាំងឲ្យរែកដី មិនព្រមទៅរែក។ បាទ នេះគឺសុទ្ធតែសកម្មភាពប្រឆាំងនឹងអង្គការហើយ និយាយដើមអង្គការជាដើម...។ល។

**ស៖** តើអង្គាល់នោះ ពេលដែលយើងឈឺហ្នឹងក៏ជាសកម្មភាពប្រឆាំងនឹងអង្គការដែរ ឬយ៉ាងណា?

**ឆ៖** បាទ បើឈឺពិតប្រាកដ គឺមិនមែនជាសកម្មភាពដែលប្រឆាំងនឹងអង្គការទេ ព្រោះគ្នាឈឺពិតប្រាកដ។

**ស៖** ចុះចំពោះអ្នកមានជំងឺសតិអារម្មណ៍ហ្នឹង គេចាត់ទុកថាពួកគាត់ហ្នឹង នៅពេលដែលឈឺហ្នឹងគេហៅឈឺប្រឆាំងនឹងអង្គការ ឬក៏យ៉ាងម៉េច?

[១១:១៦:១៤]

**ឆ៖** បាទ ចំពោះជំងឺសតិអារម្មណ៍ហ្នឹងក៏ចាត់ចូលក្នុងការប្រឆាំងនឹងអង្គការដែរ ព្រោះយើងមិនបានទៅបញ្ចេញពលកម្ម យើងមិនបានទៅជីកដីតាមការកំណត់របស់អង្គការ។ ហ្នឹងបានន័យថាអាយកជើងរាទឹក គេទៅធ្វើគ្រប់គ្នាយើងមិនទៅ។ បាទ នេះការងារជំងឺសតិអារម្មណ៍ គឺអង្គការចាត់ទុកថាយ៉ាងនេះ។

**ស៖** អម្បាញ់មិញនេះលោកនិយាយថា ជជែកគ្នាពេលយប់នុ៎ង ក៏ត្រូវអាចគេចាត់ទុកថាជាសកម្មភាពប្រឆាំងនឹងអង្គការដែរ។ អ៊ីចឹងអ្នកធ្វើការនោះ យប់ឡើងហ្នឹងមានគេឃ្លាំមើលពួកគាត់ ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ នៅពេលហ្នឹង សកម្មភាពដែលមិនល្អ គឺមានកងឈ្លបរបស់គេ គឺជួនកាលលួនពី

ក្រោមក៏មាន។ ជួនកាល ប៉ុន្តែកន្លែងច្រើនតែក្រាល ច្រើនដេកនឹងដី។ ក្រាលបាវ ក្រាលកន្ទេលកញ្ចាស់ ជួនកាលក៏នៅពីលើក្បាលដំណេកយើង ឬក៏នៅចុងជើងយើង ដើម្បីស្ដាប់ពាក្យសម្ដីដែលយើងនិយាយ។ បើយើងនិយាយថា កម្មាភិបាល -- អ៎! បើយើងនិយាយថា នៅជាមួយអង្គការស្រួល ឬក៏មិនជាអីទេ ការងារប៉ុណ្ណឹង ហូបបាយប៉ុណ្ណឹង អាហ្នឹងគឺល្អ ក៏ប៉ុន្តែគ្រាន់តែនិយាយមួយម៉ាត់ ឬក៏ពីរបីឃ្លា "អ៊ូ! ធ្វើការនេះវាហួសហេតុ ធ្វើការងារនេះវានេះ ពីដើមមិនអី អ៊ីចេះ អ៊ីចុះអី អាហ្នឹងសុទ្ធតែជាសកម្មភាពនេះ។

**ស៖** តើឈ្លបនុ៎ងសុទ្ធតែមានអាវុធកាន់ដែរឬទេ បើតាមការចងចាំរបស់លោកនោះ?

**ឆ៖** បាទ នៅពេលហ្នឹង វាពេលយប់ ងងឹត តែមិនអាចដឹងថា តើគេមាន ឬមិនមានទេ។ ព្រោះនៅពេលមួយ ខ្ញុំក៏បាននេះដែរ ភ្ញាក់ ក្រោកពីដេកភ្ញាក់មកបត់ជើងតូច ស្រាប់តែឃើញគេដើរចេញ គេនៅក្បែរខ្លួនរបស់ខ្ញុំដែរ។ ដើរចេញទៅ ក៏ខ្ញុំមើលទៅ គឺស្លៀកខោខ្មៅ អាវខ្មៅ។ ហ្នឹងខ្ញុំថាពិតជាឈ្លបរបស់អង្គការហើយ តែត្រង់មានអាវុធ ឬក៏គ្មានអាវុធ ខ្ញុំបាទ ពេលយប់ គឺមើលមិនបានច្បាស់។

[១១:១៩:០៣]

**ស៖** សូមអរគុណ នេះជាសំណួរចុងក្រោយរបស់ខ្ញុំ។ តើលោកធ្លាប់ចូលរួមពិធីរៀបការនៅលើទំនប់ត្រពាំងថ្មហ្នឹងដែរឬទេ កាលពីសម័យនុ៎ង?

**ឆ៖** បាទ ខ្ញុំបាទបានរៀបការជំនួន២០គូ -- ២៥គូ មិនមែន២០ទេ។ ២៥គូ ដែលអង្គការរៀបចំឲ្យតែមួយពេលហ្នឹង គឺមិនមែននៅអាងត្រពាំងថ្មទេ គឺទៅរៀបការនៅឆ្នាំមួយពាន់ប្រាំបួនចិត -- ចុង ៧៨ ដើម៧៩ហ្នឹងឯង គឺនៅចម្ការកប្បាសកងវ៉ា។

**ស៖** ហើយនៅពេលដែលលោកនៅត្រពាំងថ្មនោះ តើមានសមាជិកកងរបស់លោករៀបការនៅទីនោះដែរឬទេ កាលសម័យនុ៎ង?

**ឆ៖** បាទ នៅសម័យនោះ គឺគេបែងចែក បែងចែកវណ្ណៈ បែងចែកអីសម្រាប់ប្រជាជនមូលដ្ឋាន។ បានន័យថា គេរៀបចំជាប្រជាជនរំដោះ ប្រជាជនចាស់ និងប្រជាជនជម្លៀស ប្រជាជន១៧មេសា អីទៅ។ ក៏ប៉ុន្តែគេមានសិទ្ធិតែសម្រាប់ប្រជាជនរំដោះ គឺត្រូវតែរៀបការជាមួយប្រជាជនរំដោះ។ ដូច្នេះ ប្រជាជនមូលដ្ឋានយើងធម្មតា គឺទាល់តែរៀបការជាមួយហ្នឹង។ ហើយប្រជាជន១៧មេសា គឺរៀបការជាមួយប្រជាជន ១៧មេសា មិនអាចច្រឡូកច្រឡំគ្នាបាន។

[១១:២០:៤៥]

**ស៖** តើសេចក្ដីណែនាំនោះចេញមកពីណាដែរ? លោកឮសេចក្ដីណែនាំហ្នឹងដោយផ្ទាល់ត្រចៀក

ឬក៏យ៉ាងណា?

**ឆ៖** បាទ នេះគឺបញ្ហាដែល -- នេះគឺសម្រាប់មេវរៈរបស់ខ្ញុំគឺ តាខូវ និងតាវន ដែលប្រជុំហើយជម្រាប ហើយគាត់ប្រាប់ដល់ខ្ញុំព្រមទាំងកងធំទាំងអស់។

**ស៖** អ៊ីចឹងនៅក្នុងកងវរសេនាតូចរបស់លោក កងទី១ហ្នឹង ថាមានគេរៀបការជាមួយអ្នកដែលនៅវណ្ណៈដូចគ្នា អ៊ីចឹងមែនទេ? ហើយមិនអាចឲ្យរៀបការប្រជាជនចាស់ និងប្រជាជនថ្មីទេ។ អ៊ីចឹងមែនទេ?

**ឆ៖** បាទៗ ពិតជាត្រឹមត្រូវណាស់។

**ស៖** តើរូបលោកផ្ទាល់ហ្នឹងធ្លាប់ទៅចូលរួមក្នុងរៀបការដែលរៀបចំនៅក្នុងកងរបស់លោក កងធំរបស់លោកដែរឬទេ?

**ឆ៖** បាទ នៅពេលហ្នឹងសម្រាប់ត្រឹមថ្នាក់កង អនុសេនាធំអីចុះក្រោម គឺគ្មានសិទ្ធិ គេពុំឲ្យយើងចូលទេ មានតែអង្គការលំដាប់ខាងលើដូចជាត្រឹមថ្នាក់ តាវ៉ាល់ ឬក៏ត្រឹមថ្នាក់វរសេនាតូច ត្រឹមអីហ្នឹង ទើបគេមានសិទ្ធិចូលរួមរៀបការ និងការណែនាំរបស់អង្គការបន្តទៅទៀត ក្រោយពីយើងបានគ្រួសារហើយ។

[១១:២២:៣៥]

**ស៖** តើលោកមានតួនាទីអ្វីណាមួយដែរឬទេនៅក្នុងការរៀបចំពិធីរៀបការ ហើយនិងការជ្រើសរើសគូស្រករនោះ ក្នុងឋានៈលោកជាមេកងនោះ តើលោកមានទំនួលខុសត្រូវណាមួយក្នុងការរៀបចំផ្សំផ្គុំហ្នឹងដែរឬទេ?

**ឆ៖** បាទ ជាក់ស្ដែងដូចជាខ្ញុំស្រលាញ់មិត្តនារីណាមួយ ខ្ញុំធ្វើពាក្យស្នើ។ ធ្វើពាក្យស្នើទៅ បើនារីយល់ព្រមក៏បានរៀបការ បើគេមិនយល់ព្រមក៏មិនបានរៀបការ ហើយគ្មានអ្វីក្រៅពីហ្នឹងទេ។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

ខ្ញុំសូមបញ្ចប់ត្រឹមចំណុចហ្នឹងតែម្ដង។ សូមអរគុណច្រើនលោកប្រធាន ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី! ហើយអាចមានពេល អង្គជំនុំជម្រះនឹងថែមជូន ១០មីនុត។ បានន័យថា រហូតដល់ម៉ោងមួយសែសិបនាទីក្នុងការសួរនេះ ដោយព្រឹកមិញបាត់បង់ពេលវេលា ១០នាទី។

**លោកស្រី ទី ស្រ៊ុនណា៖**

សូមអរគុណលោកប្រធាន និងសូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និង អង្គសវនាការទាំងមូល។

**សួរដោយលោកស្រី ទី ស្រ៊ុនណា៖**

**ស៖** សូមគោរពលោកសាក្សី ខ្ញុំឈ្មោះ ទី ស្រ៊ុនណា ជាមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី។ ខ្ញុំសូមធ្វើការតាំងសំណួរទៅលោកដូចតទៅ៖ កាលពីម្សិលមិញហ្នឹង លោកបានលើកឡើងទាក់ទងទៅនឹងការងារដែលគេតម្រូវឱ្យ ប្រជាជនគាត់ធ្វើនៅក្នុងការដ្ឋានហ្នឹង លោកបានលើកឡើងថា គេឱ្យគាត់ធ្វើទោះបីជាមានភ្លៀង មានផ្គរអី ក៏ប្រជាជនហ្នឹង ក៏តម្រូវឱ្យធ្វើការនៅទីនោះដែរ មិនអាចឈប់សម្រាកបានទេ។ អ៊ីចឹងខ្ញុំចង់សុំសួរបញ្ជាក់លោកថា ពេលនុ៎ង អំឡុងពេលនុ៎ង តើប្រជាជនទាំងអស់ ឬក៏កម្មករទាំងអស់ហ្នឹង គាត់អាចសុំឈប់សម្រាកថា ចាំរាំងភ្លៀង ចាំគាត់ធ្វើបានដែរឬទេលោក?

**លោក ឈុំ សេង៖**

**ឆ៖** បាទ នៅពេលហ្នឹង បើភ្លៀងតិចៗ គឺនៅតែឱ្យធ្វើការជាបណ្ដើរៗ។ រហូតដល់ភ្លៀងខ្លាំងដល់នៅក្នុងកន្លែងដែលយើងកាប់រណ្ដៅដែលយើងកាប់ វាលិចជ្រៅ កាប់មិនកើត ទើបយើងមានសិទ្ធិអាចសម្រាកបានដោយសារតែយើងៗមើលទៅហេតុផលដូចជាកាប់មិនកើត ព្រោះវាទឹកវាស្មើជង្គង់អីទៅហើយ កាប់ម៉េចកើត។ ដូច្នេះគេអាចអនុញ្ញាតឱ្យយើងសម្រាកបាន។

**ស៖** សូមអរគុណ។ អ៊ីចឹងករណីដែលមានភ្លៀងនេះ មិនមែនតែមួយលើកទេ គឺមានន័យថា ក្នុងរដូវភ្លៀងទាំងអស់ គឺនៅតែធ្វើបន្តការងារកាប់ៗទំនប់ ១មករាហ្នឹងដដែល កាប់ឬក៏ជីក ឬក៏រែកទំនប់ ១មករាហ្នឹងដដែល។ តើអ៊ីចឹងមែនទេលោក?

**ឆ៖** បាទៗ គឺពិតជាដូចអ៊ីចឹងមែន។

**ស៖** សូមអរគុណ--

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី គង់ សំអុន។

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន ខ្ញុំសូមធ្វើការកត់សម្គាល់។ អម្បាញ់មិញខ្ញុំស្ដាប់ឮថា ទំនប់១មករា អ៊ីចឹងដែលយើងកំពុងតែប្ដូរទីតាំង ឬមួយយ៉ាងម៉េចបាទ? សូមអរគុណ។

**លោកស្រី ទី ស្រ៊ីនណា៖**

សូមអរគុណដែលបានជួលរំឭក។ ប្រហែលជាដោយសារតែយើងធ្វើការពីលើកមុន សួរជាប់ៗមកបានជាប្រើប្រាស់ពាក្យច្រឡំ។ សូមអរគុណដែលបានរំឭក សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សួរបញ្ជាក់សំណួរចុងក្រោយអំមិញឡើងវិញ សំណួរភ័ន្តច្រឡំហ្នឹង។

[១១:២៦:៥១]

**សួរដោយលោកស្រី ទី ស្រ៊ីនណា៖**

**ស៖** ខ្ញុំសូមធ្វើការបញ្ជាក់ឡើងវិញដោយសារតែ -- ខ្ញុំសូមសួរលោកថា តើនៅក្នុងរដូវភ្លៀង – រដូវភ្លៀង បានន័យថា ជួនកាលវាអាចមានរយៈពេលវែង ពីរបីខែអ៊ីចឹងទៅ អ៊ីចឹងខ្ញុំចង់សូមសួរលោកថា តើនៅរដូវភ្លៀងហ្នឹង គឺគេតម្រូវឲ្យប្រជាជនហ្នឹង នៅធ្វើការនៅការដ្ឋាននៅត្រពាំងថ្មហ្នឹង បន្តធ្វើរហូត ឬមួយក៏យ៉ាងម៉េចដែរលោក?

**លោក ឈុំ សេង៖**

**ឆ៖** ដូចខ្ញុំបាទ បានជម្រាបរួចមកហើយថា បើភ្លៀងតិចៗ គឺយើងនៅតែកាប់រហូត នៅតែធ្វើការរហូត។ តែបើភ្លៀងខ្លាំងរហូតទឹកដក់ក្នុងរណ្ដៅហ្នឹង ជម្រៅចំនួនស្មើជង្គង់ យើងមិនអាចកាប់បានហើយយើងបាន ទើបគេឲ្យយើងសម្រាក។

**ស៖** សូមអរគុណ។ អ៊ីចឹងក្នុងករណីដែលប្រជាជនធ្វើការ នៅការដ្ឋានហ្នឹង នៅពេលដែលគាត់ពួកគាត់កំពុងធ្វើការហ្នឹង ចុះមានអ្នកគេដែលធ្វើៗទៅ ស្រាប់តែដួលស្លាប់នៅនឹងកន្លែងដែរឬទេលោក?

**ឆ៖** បាទ ចំពោះការដួលស្លាប់នៅនឹងកន្លែង ពុំមានទេ តែបើមានការដួល មានអី គឺពិតជាមានជាក់ស្ដែង ដូចនៅកងខ្ញុំក៏មានដែរ បាទ។

**ស៖** សូមអរគុណ។ អ៊ីចឹងនៅក្នុងកន្លែងការដ្ឋានហ្នឹង គេមានៗគេប្រើកុមារឲ្យនៅធ្វើការនៅទីនោះដែរឬទេលោក?

[១១:២៨:៤៧]

**ឆ៖** បាទ មានៗកុមារ ក៏ប៉ុន្តែកងកុមារគឺគេដាក់ដោយឡែក។ កុមារដែលតូចៗ គេឲ្យមកកាប់ទន្រ្ទានខែត្រនៅភូមិគោកតាសុខ ហើយកុមារដែលរាងទ្រើសគ្រាន់ ហ្នឹងគឺគេឲ្យរែកដី តាមកម្លាំងរបស់គេមួយថ្ងៃ ១ម៉ែត្រគូប ឬ 0,៥ម៉ែត្រគូប ហ្នឹងគឺប្រធានកងគេជាអ្នកចាត់ចែងទេ។

**ស៖** ចុះរបបអាហាររបស់ពួកកុមារ តើដូចទៅនឹងមនុស្សធំដែរ ឬក៏យ៉ាងម៉េចដែរលោក?

**ឆ៖** បាទ ចំពោះបញ្ហាហ្នឹង គឺខ្ញុំមិនបានឃើញច្បាស់ ខ្ញុំក៏មិនហ៊ាននិយាយ ព្រោះមិនដឹងជាគេបើករបបយ៉ាងណា អីយ៉ាងណា ព្រោះកងវរៈរបស់ខ្ញុំធ្វើការឆ្ងាយពីកងរបស់កុមារ។

**ស៖** សូមអរគុណ។ កាលពីម្សិលមិញផងដែរ លោកបានជម្រាបជូនអង្គជំនុំជម្រះថា គេបានផ្ដល់អង្ករឲ្យទៅប្រជាជនដែលធ្វើការនៅទីនោះ ហើយគេផ្ដល់ហ្នឹងទៅតាមប្រភេទអ្នកដែលធ្វើការកម្រិតធ្ងន់ និងកម្រិតធម្មតា ហើយនិងពួកពិការ ហើយដោយបែងចែកអង្ករពីមួយកំប៉ុងទៅពីរកំប៉ុងទៅតាមទំហំហ្នឹង។ តែខ្ញុំចង់សុំសួរលោកថាតើមួយកំប៉ុងពីរកំប៉ុងហ្នឹង គេបែងចែកឲ្យសម្រាប់មនុស្សម្នាក់ៗ ឬក៏សម្រាប់ក្នុងក្រុមតែម្ដង?

**ឆ៖** បាទ សម្រាប់ការបែងចែកអង្ករនេះ គឺមួយកំប៉ុងហ្នឹងសម្រាប់មនុស្សម្នាក់។ អ្នកដែលពលកម្មបានតិច ដូចជារែកដីបានតែមួយចំនួន ១ម៉ែត្រគូប ឲ្យលើសក៏លើសតិចតួចប៉ុណ្ណឹង។ តែអ្នកដែលរែកបាន ២ម៉ែត្រគូបទៅ ៣ម៉ែត្រគូបអាហ្នឹងគឺអង្កររបបផ្សេង បាទ មានមួយថ្ងៃពីរកំប៉ុងក៏មាន ជួនកាលក៏មិនបាន ជួនកាលក៏បានពីរកំប៉ុង។ អាស្រ័យទៅលើអង្ករដែលគេបើក គេដឹកមកទាន់ ឬមិនទាន់បាទ។

[១១:៣១:២៣]

**ស៖** សូមអរគុណ។ តើការចែកឲ្យនេះ គឺចែកឲ្យតែចាប់តាំងពីការចាប់ផ្ដើមការដ្ឋានរហូតដល់ចប់ការដ្ឋានហ្នឹងតែម្ដង ឬក៏យ៉ាងម៉េចដែរលោក?

**ឆ៖** បាទ ការបើកអង្ករនេះគឺចាប់ផ្ដើមតាំងពីបើករដ្ឋាន ក៏ប៉ុន្តែចុងភៅទៅបើកហ្នឹង គឺរាយការណ៍ពីកម្លាំងរបស់យើង ហើយបើកក្នុងមួយថ្ងៃនោះ គឺបើកដាំព្រឹក ហើយនិងល្ងាច ពីរពេលបាទ។

**ស៖** សូមអរគុណ។ ឥឡូវខ្ញុំចង់សុំសួរលោកពាក់ព័ន្ធជាមួយនឹងការបោសសម្អាតខ្មាំងបន្តិច។ តើនៅក្នុងអំឡុងពេលដែលប្រជាជនធ្វើការនៅក្នុងការដ្ឋានអាងត្រពាំងថ្មហ្នឹង តើគេមានធ្វើការស្រង់ប្រវត្តិរូបប្រជាជនទាំងនោះដែរឬទេ ហើយពេលដែលគេ -- បើមាន តើគេមានធ្វើការស្វែងរកជនក្បត់អីដែរឬទេលោក?

**ឆ៖** ពេលហ្នឹង សម្រាប់កងខ្ញុំគឺគ្មានទេ តែសម្រាប់កងដទៃគឺខ្ញុំអត់ដឹង។ ជាពិសេស គឺអង្គការគឺមានតែ ដូចខ្ញុំបាននិយាយរួចហើយ គឺមានឈ្លបមានអីគេចុះមកជួយកាប់ដីយើង តាមដានយើងមួយថ្ងៃឲ្យបានម្នាក់ ហើយសម្រាប់ប្រធានកងក៏តាមដានក្នុងមួយថ្ងៃឲ្យបានម្នាក់ដែរ។ ការចុះធ្វើប្រវត្តិរូបសម្រាប់

កងខ្ញុំ គឺគ្មាន។

[១១:៣៣:០០]

**ស៖** សូមអរគុណ។ ចុះលោកដែលឮគេស្វែងរកខ្មាំង សេ.អ៊ី.អា ឬក៏កា.ហ្សេ.បេ អីដែរឬទេ ជំនាន់នុំង?

**ឆ៖** បើនិយាយរួមទៅ ការប្រជុំដែល តាវ៉ាល់ ប្រជុំ គឺឲ្យស្វែងរកពួកហ្នឹងឯង។ ជាពិសេសដូចជាទាហាន លន់ នល់ ហើយឲ្យស្វែងឲ្យតាមបំផុតគឺយួន។ អាខ្មាំងយួនដែលមកនៅទឹកដីកម្ពុជានេះ គឺឲ្យតាមឲ្យសំខាន់ជាជាងទាហាន លន់ នល់ ជាងពួក -- ហើយនិង សេ.អ៊ី.អានេះ។ ពីរនេះគឺឲ្យតាមឲ្យច្បាស់។

**ស៖** សូមអរគុណ។ អ៊ីចឹងកន្លងមក ដែលមានចាប់ខ្មាំង សេ.អ៊ី.អា ឬក៏ពាក់ព័ន្ធខ្មាំងដែលមានការពាក់ព័ន្ធជាមួយយួនហ្នឹងដែរឬទេលោក?

**ឆ៖** បាទ ចំពោះកងខ្ញុំគឺគ្មានទេ តែចំពោះកងវរៈគេផ្សេង ខ្ញុំពុំបានដឹង។

**ស៖** សូមអរគុណ។ អ៊ីចឹងលោកមានពាក់ព័ន្ធជាមួយនឹងកន្លែងកងរបស់លោក ក៏ដូចជាកងដែលនៅជុំវិញលោក ជាពិសេសគឺនៅតំបន់ដែលលោកអាចទៅដល់ ហើយអាចប្រាស្រ័យទាក់ទងបាន ហើយជជែកគ្នា អាចដឹងពីដំណើរការខ្លះ។ ខ្ញុំចង់សុំសួរលោកថា តើលោកមានបានធ្លាប់ឮគេនិយាយអំពីការបាត់ខ្លួនពីកងរបស់គេដែរទេ ក្រៅពីកងរបស់លោក?

[១១:៣៥:០៧]

**ឆ៖** បាទ ខ្ញុំបានដឹង តែដឹងតែពីរឿងប្រធានវរៈដូចជាឈ្មោះ ស្រេះ, ឈ្មោះ ធួន ឈ្មោះអីដែលបាត់ខ្លួនប៉ុណ្ណឹងគឺដឹង ដោយសារប្រធានកងដូចគ្នានិយាយ “អ៊ូ! ពួកហ្នឹងអ្នក រត់បាត់អស់ហើយ រត់ទៅណាមិនដឹងទៅណា” ដឹងថាត្រឹមប៉ុណ្ណឹងទេ សម្រាប់ថ្នាក់ដឹកនាំត្រឹមប្រធានកងធំ ត្រឹមវរៈអីដឹង តែសម្រាប់បងប្អូននៅក្រោមនោះ គឺខ្ញុំពុំបានដឹងទេ។

**ស៖** សូមអរគុណ។ ពាក់ព័ន្ធជាមួយនឹងការសម្ពោធវិញ។ តើនៅក្នុងការដ្ឋានត្រពាំងថ្មហ្នឹង គេមានរៀបចំការសម្ពោធដែរឬទេលោក?

**ឆ៖** ទំនប់អាងត្រពាំងថ្មមិនទាន់ធ្វើរួចជាស្ថាពរទេ ពេលនោះគេធ្វើពិធីសម្ពោធ ពេលនោះរូបខ្ញុំក៏មានវត្តមានទៅឈរទទួលដែរ។ ពេលហ្នឹង គណៈអធិបតីគេប្រកាសថាជនជាតិចិនមកម្នាក់ ហើយឲ្យយើងទាំងអស់គ្នាក្រោកឈរទះដៃស្រែកខ្លាំងៗថា “ស្វាគមន៍យ៉ាងកក់ក្ដៅសមមិត្ត ឆឹង យីងគួយ”។

បាទពេលហ្នឹង សមមិត្ត ឆឹង យើងគួយ គឺមកទស្សនកិច្ចនៅអាងត្រពាំងថ្ម។ បាទ ឃើញសម្ពោធម្តង ប៉ុណ្ណឹងបាទ។

**ស៖** ចុះលោកអាចចាំបានដែរឬទេ ពេលដែលគេសម្ពោធហ្នឹងនៅក្នុងឆ្នាំណាដែរលោក?

**ឆ៖** បាទ សម្ពោធនៅៗក្នុងអំឡុងឆ្នាំ១៩៧៨។

**ស៖** សូមលោកជួយរកនឹកឡើងវិញមើល តើក្នុងឆ្នាំ៧៧ ឬក៏ឆ្នាំ៧៨?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតប ក្បាលមីក្រូហ្វូនមិនទាន់ប្រតិបត្តិការទេ សាក្សី។

**លោក ឈុំ សេង៖**

**ឆ៖** បើតាមខ្ញុំចាំបាន ខ្ញុំថាឆ្នាំ១៩៧៨។

**លោកស្រី ទី ស្រ៊ីនណា៖**

**ស៖** សូមអរគុណ។ ខ្ញុំសូមសួរពីរសំណួរចុងក្រោយទៀត។ ពាក់ព័ន្ធជាមួយថ្នាក់ដឹកនាំវិញ តើលោកដែលធ្លាប់ឮគេនិយាយអំពីបងទី១ បងទី២អីដែរឬទេនៅក្នុងជំនាន់ពេលហ្នឹង?

[១១:៣៨:១៩]

**ឆ៖** សម្រាប់ខ្ញុំពុំដែលឮគេនិយាយថាបងទី១ ទី២ គឺពុំដែលឮទេ។

**ស៖** ចុះលោកដែលឮគេនិយាយអំពី អ៊ំប៉ុលពត, អ៊ំនួន ឬក៏អ៊ំហែម អីដែរឬទេ? តើពួកគាត់មានបានចូលរួមក្នុងកម្មវិធីសម្ពោធហ្នឹងដែរឬអត់?

**ឆ៖** ពេលហ្នឹង ខ្ញុំស្គាល់ច្បាស់តែ តាវ៉ាល់ មួយ ហើយៗតាវ៉ាល់ហ្នឹងគាត់បាននិយាយក្នុងអង្គមីទ្ទិងនោះថា "គឺមានភ្ញៀវចិនមក ធ្វើទស្សនកិច្ចនៅអាងត្រពាំងថ្ម" តែមានសៗដែរ សម្បុរហាក់នឹងដូចជាជនជាតិចិនដែរពីរនាក់ ក៏ប៉ុន្តែមិនដឹងជាជនជាតិណាទេ ព្រោះ តាវ៉ាល់ មិនបានជម្រាបប្រាប់បងប្អូនដែលចូលរួមនោះទេ។

**ស៖** សូមអរគុណ។ ចុះកន្លងមក នៅក្នុងការដែលយើងធ្វើការនៅក្នុងការដ្ឋានកន្លងមកចាប់ពីការចាប់ផ្តើមរហូតដល់ចុងបញ្ចប់ហ្នឹង តើដែលមានៗគណៈប្រតិភូ ឬក៏ដែលមានខាងថ្នាក់លើអីគេចុះទៅពិនិត្យមើលការដ្ឋានហ្នឹងដែរឬទេលោក?

**ឆ៖** ខ្ញុំដឹងតែម្តងទេនៅពេលដែលធ្វើមីទ្ទិងសម្ពោធអាងទឹកត្រពាំងថ្ម ដែលមានភ្ញៀវចិនចូលរួមក្រៅពីនោះ គឺខ្ញុំពុំបានដឹងពុំបានឃើញទេ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកស្រីមេធាវី។

បាទ ឥឡូវនេះ ដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះទៅរហូតដល់ម៉ោងមួយកន្លះរសៀលនេះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ មន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំ សម្រាប់សាក្សី និងអ្នកជំនាញដល់សាក្សីរូបនេះ នៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់រួមទាំងមេធាវីប្រឹក្សាសាក្សីមកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការចំពោះមុខអង្គជំនុំជម្រះនេះ នៅវេលាម៉ោងមួយកន្លះរសៀលនេះ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំង នាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះ ឲ្យបានមុនម៉ោងមួយកន្លះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង១១:៤១ នាទី ដល់ម៉ោង១៣:៣០ នាទី)*

[១៣:២៩:០៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយសវនាការតទៅនេះ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដី ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សី ហើយ -- កុំអាលទាន់ក្រុមមេធាវីការពារក្ដី ចៅក្រម ក្លូឌា ហ្វេនស៍ មួយចំនួនសុំសួរទៅសាក្សី។

សូមអញ្ជើញលោកស្រីចៅក្រម ក្លូឌា ហ្វេនស៍!

**សួរដោយចៅក្រម ក្លូឌា ហ្វេនស៍៖**

**ស៖** មានសំណួរខ្លីៗពីរទេ សួរបន្តពីសហមេធាវីនាំមុខ។ លោកសាក្សីកាលពីម្សិលមិញ

លោកបានឆ្លើយថា មនុស្សជាច្រើនធ្លាក់ខ្លួនឈឺ ហើយមនុស្សជាច្រើនត្រូវបានគេយកទៅសម្លាប់ចោល ដោយសារតែអ្នកទាំងនោះចោទថា ឈឺសតិអារម្មណ៍។ មានន័យថា ឈឺពុត។ លោកអាចជម្រាបអង្គជំនុំជម្រះបានទេ អ្នកណាជាអ្នកសម្រេចថា ឈឺហ្នឹង ជាការឈឺពិត ឬក៏ជាការធ្វើពុតឈឺ? ខ្ញុំមិនចង់ស្តាប់លោករៀបរាប់ឡើងវិញអំពីរឿងជំងឺខ្វាក់មាន់អីនោះទេ។ សួរតែថា តើអ្នកណាជាអ្នកសម្រេចថា ប្រជាជនហ្នឹង គឺថាឈឺមែនទែន ឬក៏ឈឺពុតនោះ?

**លោក ឈុំ សេង៖**

**ឆ៖** បាទ នៅពេលក្នុងនោះ ដែលឈឺច្រើនៗ ពេទ្យជាអ្នកដើរពិនិត្យតាមរោង តាមកន្លែង។ ដូច្នេះគឺជំងឺនោះ គឺពេទ្យជាអ្នកសម្រេចថា មនុស្សនោះពិតជាឈឺ ឬមិនឈឺ បាទ។

**ស៖** ពេទ្យដែលលោកថាជាអ្នកមកពិនិត្យហ្នឹង គឺមានជំនាញខាងផ្នែកពេទ្យ មានជំនាញខាងផ្នែកវេជ្ជសាស្ត្របានទទួលការបណ្តុះបណ្តាលអីត្រឹមត្រូវទេ?

**ឆ៖** បាទ ពេទ្យទាំងអស់នុ៎ង គឺសុទ្ធតែពេទ្យអ្នកល្ងង់ ពេទ្យមិនចេះអក្សរ។ ដូចខ្ញុំនិយាយថា ថ្នាំ គឺមានតែថ្នាប្រភេទដូចអាចម៍ទន្សាយមួយមុខទេ ដែលយកទៅឲ្យគ្នាលេប។ ដូច្នេះលោកពេទ្យសម្រេចថាមនុស្សនោះឈឺ មនុស្សនោះឈឺសតិអារម្មណ៍ មនុស្សនោះអីៗ គឺនៅលើពេទ្យជាអ្នកសម្រេច។

[១៣:៣២:០៨]

**ស៖** សូមលោកលើកឧទាហរណ៍មួយមើល តើពេទ្យទៅពិនិត្យអ្នជំងឺ ឧទាហរណ៍ថា អ្នកជំងឺប្រាប់ថា ខ្ញុំមានជំងឺហើមពោះអីយ៉ាងដូច្នេះ តើបុគ្គលិកពេទ្យនុ៎ងមានពិនិត្យ មានឧបករណ៍អីត្រឹមត្រូវទេ?

**ឆ៖** បាទ តាមសង្កេតឃើញពេទ្យនោះមានតែសាក់កូដមួយ ពេទ្យហ្នឹង គេហៅសាក់កូដអាប្រដាប់សម្រាប់ស្តាយហ្នឹង ហើយនិងដាក់ថ្នាំឫសឈើ ថ្នាំអីតិចតួចទៅតែប៉ុណ្ណោះទេ ហើយទៅដល់ថា ដូចថាយ៉ាងច្រើនក៏ស្ទាបខ្លួន ហើយសួរថាឈឺអី? ដូច្នេះ អ្នកជំងឺក៏បានរាយការណ៍ប្រាប់ថា ខ្ញុំឈឺនេះឈឺនោះ បាទ។ ក៏ប៉ុន្តែពេទ្យគេឲ្យថ្នាំលេបទេ ប៉ុណ្ណឹងទៅ។ គេដើរចេញទៅ យើងឈឺក៏នៅតែឈឺអ៊ីចឹងទៅ បាទ។

**ស៖** តើលោកអាចរៀបរាប់ករណីណាមួយដែលពេទ្យមកមើលហើយ ពេទ្យឆ្លើយៗថា អ៊ូ! អ្នកឯងឈឺពុតទេ ឬក៏មានករណីណាមួយដែលពេទ្យពិនិត្យស្ទាបខ្លួនប្រាណអ្នកជំងឺហើយ ធ្លាប់ដែលឆ្លើយថា "អ៊ូ! អ្នកឯងឈឺពុតទេ"។ លោកអាចលើកករណីបែបនេះបានទេ?

**ឆ៖** បាទ សម្រាប់នៅកងរបស់ខ្ញុំ ដែលខ្ញុំចុះផ្ទាល់ដឹងឮ គឺមិនដែលមានជំងឺហ្នឹងទេ ហើយក៏ពេទ្យក៏មិនដែលបានប្រាប់ខ្ញុំថា កងរបស់លោក គឺមានជំងឺសតិអារម្មណ៍អី គឺគ្មានទេ។ តែបើតាមដែលខ្ញុំឃើញ គ្រាន់តែឃើញថាយកថ្នាំទៅឱ្យ គឺស្ដាបមើលបន្តិចបន្តួច ឱ្យថ្នាំលេបទៅថាជាហើយ អីហើយតែប៉ុណ្ណោះ។ តែចំពោះកងគេអ្នកដទៃ ដែលនៅឆ្ងាយពីខ្ញុំ ខ្ញុំបាទ មិនបានឃើញ ហើយក៏យល់មិនដល់ដែរ។

**ស៖** ចុះហេតុអ្វីបានជាកាលពីម្សិលមិញ លោកដកស្រង់ ខ្ញុំសូម -- លោកបានឆ្លើយ ខ្ញុំសូមដកស្រង់៖ “ប្រជាជនជាច្រើនត្រូវបានគេយកទៅសម្លាប់ចោល ដោយសារពួកគាត់ត្រូវបានគេចោទប្រកាន់ថាមានជំងឺសតិអារម្មណ៍” បញ្ចប់ការដកស្រង់។ នេះ ខ្ញុំស្រង់សម្ដីលោកកាលពីម្សិលមិញ ត្រង់ទំព័រ៦៤នៃសេចក្ដីព្រាងប្រតិចារឹក កាលពីម្សិលមិញ។

**ឆ៖** បាទ--

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតប! សូមអញ្ជើញលោកមេធាវី គង់ សំអុន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ លោកស្រីចៅក្រម បញ្ជាក់ម៉ោងបានទេ?

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំរកម៉ោងអត់ទាន់ឃើញទេ ក៏ប៉ុន្តែជាភាសាអង់គ្លេសនេះ សេចក្ដីព្រាងប្រតិចារឹកដែលខ្ញុំទទួលបានពីព្រឹកមិញនេះ គឺត្រង់ទំព័រ៦៤ ជាភាសាអង់គ្លេសដែលខ្ញុំទទួលបានព្រឹកមិញនេះឯង។

**ប្រធានអង្គជំនុំ៖**

លោកស្រីចៅក្រម តាំងសំណួរសាជាថ្មីម្ដងទៀត។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

**ស៖** ខ្ញុំនឹងសួរឡើងវិញលោកសាក្សី ដោយលើកសម្ដីលោកឆ្លើយកាលពីម្សិលមិញ គឺយោងទៅលើសេចក្ដីព្រាងប្រតិចារឹកដែលខ្ញុំទទួលបានព្រឹកមិញមានការសួរអំពីរុយ ហើយក្រោយមកលោកឆ្លើយថា ប្រជាជនជាច្រើនបានធ្លាក់ខ្លួនឈឺ ប្រជាជនជាច្រើនត្រូវបានគេយកទៅសម្លាប់ចោល ដោយសារពួកគាត់ត្រូវបានគេចោទប្រកាន់ថា មានជំងឺសតិអារម្មណ៍។

**លោក ឈុំ សេង៖**

**ឆ៖** បាទ ជំងឺសតិអារម្មណ៍នេះ បើតាមពិតទៅគឺមានមែន ជាក់ស្តែងដូចជានៅក្នុងកងខ្ញុំក៏មាន។ ពេលនោះ ពុតថាឈឺ តែពេលដែលគេទៅរែកដី បែរជាយើងដើរទៅបេះអន្លក់ បេះត្រកួន ទៅជីកកណ្តុរ ឬក៏ទៅធ្វើការងារអីផ្សេងៗដើម្បីយកមកហូប។ ពេលហ្នឹងក៏គេចាត់ទុកថា យើងឈឺសតិអារម្មណ៍ ពេលនោះ ក៏អង្គការក៏ត្រូវតែសម្លាប់ដែរ។ តែចំពោះនៅក្នុងកងរបស់ខ្ញុំនេះ ពុំដែលមានអង្គការណាដែលយកមនុស្សឈឺសតិអារម្មណ៍ទៅសម្លាប់ទេ។ តែចំពោះកងផ្សេងៗ គឺខ្ញុំបាទពុំបានដឹងដល់។

[១៣:៣៧:៣១]

**ស៖** អ៊ីចឹងហេតុអ្វីក៏លោកឆ្លើយ នូវអ្វីដែលខ្ញុំដកស្រង់សម្តីលោកនេះ គឺលោកឆ្លើយកាលពីម្សិលមិញថា "ប្រជាជនជាច្រើនត្រូវបានគេយកទៅសម្លាប់ចោលដោយសារពួកគាត់ត្រូវបានគេចោទប្រកាន់ថាមានជំងឺសតិអារម្មណ៍" បញ្ចប់ការដកស្រង់។ នេះគឺជាសម្តីរបស់លោកផ្ទាល់។ ហេតុម៉េចលោកឆ្លើយថាអ៊ីចឹង?

**ឆ៖** បាទ ពីម្សិលមិញ ខ្ញុំបាននិយាយពីរឿងសុខភាព ពីរឿងថាសត្វរុយច្រើន ប្រជាជនឈឺច្រើន ហើយការដែលថាឈឺសតិអារម្មណ៍គេយកទៅវាយចោល ខ្ញុំបាទថាដូចជាមិនបាននិយាយទេ។

**ស៖** ខ្ញុំដកស្រង់ចេញពីប្រតិចារឹកជាភាសាអង់គ្លេស ដើម្បីឲ្យច្បាស់សួរឡើងវិញ។ លោកដឹងទេ នៅខាងក្រៅកងរបស់លោក លោកឆ្លើយថា ក្នុងកងរបស់លោកមិនដែលមានករណីហ្នឹងទេ ក៏ប៉ុន្តែក្រៅពីកងរបស់លោក ថាតើមានប្រជាជនឈឺសតិអារម្មណ៍ទេ ហើយបើឈឺសតិអារម្មណ៍មានគេយកទៅសម្លាប់ចោលទេ? និយាយពីរឿងកង ក្រៅពីកងរបស់លោក លោកដឹងទេ?

**ឆ៖** បាទ ក្រៅពីកងរបស់ខ្ញុំបាទ ខ្ញុំបាទពុំដឹងទេ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ដូច្នេះ បញ្ជាក់ឲ្យឃើញថាត្រូវតែកែប្រែប្រតិចារឹកដែលបានបកប្រែរួចមកហើយនេះ។ ខ្ញុំអស់សំណួរហើយលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ សូមអរគុណលោកប្រធាន។

[១៣:៣៩:៤៣]

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** លោកសាក្សី ខ្ញុំយល់តាមរយៈចម្លើយរបស់លោក គឺថាស្ថានភាពរបស់អ្នកធ្វើការនៅទំនប់ត្រពាំងថ្ម ខុសគ្នាពីកងមួយទៅកងមួយ កងចល័តសហករណ៍ ឬក៏កងចល័តរបស់តំបន់ ជាដើម។ ខ្ញុំយល់ថាអ្នកធ្វើការដែលនៅក្នុងកងចល័តសហករណ៍នោះ មានការខ្វះម្ហូបអាហារច្រើន ហើយអ្នកខ្លះធ្លាក់ខ្លួនឈឺ ហើយអ្នកខ្លះហ្នឹងក៏ស្លាប់ដោយសារខ្វះអាហារហ្នឹងផងដែរ ក៏ប៉ុន្តែលោកដែលស្ថិតនៅក្នុងកងចល័តដែលស្ថិតនៅថ្នាក់តំបន់នោះទទួលរបបអាហារគ្រប់គ្រាន់។ តើខ្ញុំយល់ដូច្នេះត្រឹមត្រូវដែរឬទេបើតាមចម្លើយរបស់លោកកាលម្សិលមិញនេះ លោកនិយាយអ៊ីចឹង?

**លោក ឈុំ សេង៖**

**ឆ៖** បាទ ពេលហ្នឹងអ្នកដែលធ្វើពលកម្មដែលរែកដីបានត្រឹម៣ម៉ែត្រគូបទៅ គឺបានអង្ករក្នុងមួយថ្ងៃ គឺម្នាក់ពីរកំប៉ុង។ ដូច្នេះ ពីរកំប៉ុងបើដាំរួមគ្នាទៅគឺអាចហូបគ្រប់។

**ស៖** តើនៅក្នុងកងរបស់លោក ឬក៏កងតំបន់ផ្សេងៗមានអ្នកដែលខ្វះរបបអាហារហូបចុកដែរឬទេ? នេះខ្ញុំមិនមែននិយាយអំពីកងចល័តតាមសហករណ៍នោះទេ ក៏ប៉ុន្តែនិយាយអំពីកងចល័តតំបន់ ឬក៏ស្រុកជាដើម។ តើនៅក្នុងកងចល័តទាំងអស់ហ្នឹងមានខ្វះចំណីអាហារ ឬក៏អាហារូបត្ថម្ភដែរឬទេ?

**ឆ៖** បាទ នៅក្នុងកងចល័តទាំងមូល អាហារូបត្ថម្ភ គឺមានការខ្វះខាតខ្លះ ក៏ប៉ុន្តែសម្រាប់អាហារបន្លែបន្ថែម គឺពុំដែលមានទេ។

[១៣:៤២:៣៥]

**ស៖** ខ្ញុំមិនយល់នូវចម្លើយលោកនៅឡើយទេ អ៊ីចឹងខ្ញុំសួរម្តងទៀត។ នៅក្នុងកងរបស់លោកនោះតើមានអ្នកខ្វះអាហារូបត្ថម្ភដែរឬទេ? តើមានអ្នកដែលហូបចុកមិនគ្រប់គ្រាន់បើធៀបទៅនឹងទំហំការងារដែលខ្លួនត្រូវបំពេញដែរឬទេ? អាហារតិចជាងទំហំការងារ ខ្ញុំចង់សួរអ៊ីចឹង។

**ឆ៖** បាទៗ សួរចំណុចហ្នឹង ខ្ញុំស្តាប់បាន ព្រោះថាការងារដែលធ្វើនោះវាធ្ងន់ធ្ងរ ក៏ប៉ុន្តែការហូបចុកដូចអាហារូបត្ថម្ភហ្នឹង គឺមិនគ្រប់គ្រាន់ទេ បាទ។

**ស៖** អ៊ីចឹងខ្ញុំយល់ថានៅក្នុងកងទាំងអស់ហ្នឹងអ្នកធ្វើការហ្នឹងស្រេកឃ្លាន ហើយអ្នកខ្លះហ្នឹងស្រេកឃ្លានជាងគេ។ តើខ្ញុំយល់អ៊ីចឹងត្រឹមត្រូវដែរឬទេ? តើលោកចង់និយាយអ៊ីចឹងឬក៏យ៉ាងម៉េច អាហារមិនគ្រប់គ្រាន់ អ្នកខ្លះឃ្លានតិច អ្នកខ្លះឃ្លានច្រើនអ៊ីចឹងទៅ?

**ឆ៖** បាទ រឿងហ្នឹងពិជាត្រឹមត្រូវ ព្រោះនៅដំណាក់កាលនោះសម្រាប់កម្មាភិបាល គឺដូចជារាងបានផ្តែតជាគេបន្តិច ហើយបើសម្រាប់ថ្នាក់ក្រោម គឺគ្នាពិតជាអត់ឃ្លាន គ្នាពិតជាពុំបានគ្រប់គ្រាន់ទេ។

[១៣:៤៤:១៨]

**ស៖** បាទ សូមអរគុណដែលបានឆ្លើយបំភ្លឺទាំងអស់នេះ។ ឥឡូវខ្ញុំសូមចោទសំណួរមួយចំនួនទាក់ទងទៅនឹងអ្នកបច្ចេកទេស ដែលធ្វើការនៅការដ្ឋានហ្នឹងដែរ។ តើនៅពេលណាមួយ តាវ៉ាល់ មានបានសុំឲ្យមេកងស្វែងរកអ្នកដែលមានសមត្ថភាពនៅក្នុងការធ្វើទំនប់នេះដែរឬទេ ហើយតើមានមនុស្សណាដែលអាចមកជួយការងារ តាវ៉ាល់ នេះដែរឬទេ នៅពេលនោះ?

**ឆ៖** បាទ នៅពេលហ្នឹង តាវ៉ាល់ បានប្រជុំប្រធានកងទាំងអស់ឲ្យរកអ្នកណាដែលជាវិស្វករធ្វើស្ពាន បាទធ្វើស្ពាន គឺស្ពានទី១ ស្ពានទី២ ទី៣ តាមបណ្តោយអាងទឹកត្រពាំងថ្ម។ ដល់សួរចំខ្ញុំ សួរថាមិត្តសេង កងមិត្តឯងមែនទេ? ខ្ញុំក៏បានជម្រាបទៅគាត់ថា សម្រាប់កងខ្ញុំ គ្មានទេបង សុទ្ធតែមនុស្សល្ងង់អត់មានអ្នកណាចេះទេ អត់មានទេ ខ្ញុំបានសួរស្រាវជ្រាវអស់ហើយ តែកងផ្សេងៗទៀតមិនដឹងជាគាត់រកបាននៅកន្លែងណា ខ្ញុំក្រោយមក បានឮថាគាត់រកបាន តែខ្ញុំអត់ដឹងថាគាត់យកមកពីណាទេ។

**ស៖** តើលោកមានចាំឈ្មោះវិស្វករទាំងអស់ហ្នឹងដែរឬទេ? ហើយពេលក្រោយមក វិស្វករទាំងអស់ហ្នឹងក្លាយជាអ្វីដែរ?

[១៣:៤៦:២០]

**ឆ៖** បាទ ពេលហ្នឹងខ្ញុំចាំឈ្មោះបាន ឈ្មោះគាត់គឺឈ្មោះ តាទេន គេហៅ ជាងទេនៗ។ ជាងហ្នឹងគាត់បាននិយាយថា គាត់ជាវិស្វករជំនាន់មុន។ ការពិតទៅ គាត់ពិតជាចេះមែន ព្រោះគាត់បានជួបនឹង តាវ៉ាល់ – ខ្ញុំក៏បានឃើញ – ហើយគាត់សួរ តាវ៉ាល់ ថាបងចង់ធ្វើស្ពាននេះ តើទទឹងប៉ុន្មាន ប៉ុន្មានហើយស៊ីម៉ង់ត៍នោះ បងឯងលាយក្នុង១ម៉ែត្រគូបហ្នឹង ស៊ីម៉ង់ត៍ប៉ុន្មាន ប៉ុន្មានការ៉ុង។ តាវ៉ាល់ ក៏ប្រាប់តាមដំណើរ ហើយ តាទេន គាត់ថាឲ្យដឹកដែក៦លី អាតូច អាធំចំនួនប៉ុណ្ណោះដើម ស៊ីម៉ង់ត៍ចំនួនប៉ុណ្ណោះការ៉ុង ហើយល្បសដែលចងប៉ុណ្ណោះគីឡូ។ ពេលនោះ គឺខ្ញុំឃើញនឹងភ្នែក ហើយរហូតដល់ តាទេន រាយការណ៍ឲ្យ តាវ៉ាល់ ហើយតាវ៉ាល់ ជាអ្នកឆ្លើយប្រាប់ តាទេន។

**ស៖** អ៊ីចឹង វិស្វករហ្នឹង បើខ្ញុំយល់មិនច្រឡំទេ គឺគាត់បានត្រួតពិនិត្យការដ្ឋានការងារនៅលើទំនប់ហ្នឹង ផ្នែកបច្ចេកទេស។ តើលោកដឹងថា ពេលក្រោយមកហ្នឹង គាត់រស់រានមានជីវិតទេ ឬក៏គាត់ក្លាយទៅជាអ្វីបាត់ទៅហើយ?

**ឆ៖** ពេលហ្នឹង ស្ពានទី១ ស្ពានទី២ ស្ពានទី៣ កសាងមិនទាន់រួចរាល់នៅឡើយទេ។ មូលហេតុដោយសារខ្វះខ្សាច់ ខ្វះស៊ីម៉ង់ត៍ ខ្វះដែក គេក៏ដកគាត់ឲ្យទៅកសាងស្ថានីយបូមទឹកនៅចារគោកទាន តាមបណ្តោយផ្លូវពីគោករំចេក កាត់ភូមិស្នាច់ ទៅដល់ចារគោកទាន គាត់ក៏ធ្វើសំណង់នៅទីនោះ។ ក្រោយមកទៀត ស្រាប់តែខ្ញុំបានដកកម្លាំងទៅបាត់ហើយ មិនដឹងជាគាត់ស្លាប់ ឬក៏រស់ទេ។

[១៣:៤៨:៥៨]

**ស៖** កាលពីព្រឹកមិញ លោកបាននិយាយអំពីទស្សនកិច្ចនៅការដ្ឋានហ្នឹង ទស្សនកិច្ចរបស់ជនជាតិចិនម្នាក់ឈ្មោះ ឆឹង យឹងគួយ។ តើលោកអាចជម្រាបជូនតុលាការបានដែរឬទេ ថាក្រៅពីបុគ្គលរូបនេះ តើមានអ្នកបច្ចេកទេសជនជាតិចិនដែលបានមកធ្វើទស្សនកិច្ចនៅទំនប់ហ្នឹងដែរ ឬក៏មានជនជាតិចិនហ្នឹងដែលនៅទីនោះជាប្រចាំ ឬក៏មកទៀងទាត់មកការដ្ឋានហ្នឹង តើលោកមានដែលសង្កេតឃើញថាមានវត្តមានចិន ឬក៏ជនជាតិចិនផ្សេងទៀតដែលមកទស្សនកិច្ចនៅទីហ្នឹងទេ ជាប្រចាំ ឬក៏ជាទៀងទាត់ជាដើមនោះ?

**ឆ៖** បាទ នៅក្នុងការដ្ឋានអាងត្រពាំងថ្មនោះ គឺគ្មានកន្លែងដែលស្នាក់នៅរបស់ជនជាតិចិនទេ ទើបតែក្នុងអំឡុងឆ្នាំ៧៨ ពេលនោះគេធ្វើកិច្ចសម្ពោធន៍អាងទឹកត្រពាំងថ្មដែលមិនទាន់ជារួចស្រេចបាច់នោះ ពេលនោះ តាវ៉ាល់ ក៏បញ្ជាឲ្យយកតែអ្នកដែលធាត់ៗយកទៅឈរដើម្បីទទួលភ្ញៀវចិន។ ហើយពេលដែលភ្ញៀវចិនចូលមកដល់ យើងត្រូវក្រោកឈរទះដៃឲ្យខ្លាំងស្រែកថា "ស្វាគមន៍យ៉ាងកក់ក្តៅសមមិត្ត ឆឹង យឹងគួយៗ!"។ ពេលដែលដើរចូលមកដល់ គឺឃើញសម្បុរសៗចំនួនបីនាក់ តែម្នាក់ហ្នឹងគឺតាវ៉ាល់ បានប្រកាសថានេះគឺជាជនជាតិចិនដែលមកធ្វើទស្សនកិច្ចនៅអាងត្រពាំងថ្ម តែពីរនាក់ទៀតសម្បុរសំបក ដូចគ្នាហ្នឹង មិនដឹងជាជនជាតិអីទេ ព្រោះ តាវ៉ាល់ មិនបានប្រកាសសមាសភាពប្រាប់។

**ស៖** លោកនិយាយពីទស្សនកិច្ចហ្នឹង លោកនិយាយថាទស្សនកិច្ចហ្នឹងបានធ្វើកើតឡើងនៅឆ្នាំ១៩៧៨។ អ៊ីចឹងបើតាមយោបល់របស់លោក គឺទស្សនកិច្ចហ្នឹងបានធ្វើឡើងមុនពេលកម្មាភិបាលភូមិភាគនិរតីមកដល់ ឬក៏ក្រោយពេលដែលភូមិភាគនិរតីមកដល់ហើយទេ? ហើយបើតាមលោកចាំនោះ តើពេលដែលធ្វើកិច្ចសម្ពោធន៍ហ្នឹងទំនប់ហ្នឹង តើមានវត្តមាន រស់ ញឹម ដែរឬទេ គាត់មកធ្វើជាគណៈអធិបតីអីដែរឬទេ? បើសិនជាលោកមិនចាំទេនោះ លោកនិយាយថាមិនចាំទៅ គ្មានបញ្ហាអ្វីទេ។

[១៣:៥២:១៦]

**ឆ៖** បាទ នៅក្នុងពេលនោះ សម្រាប់ រស់ ញឹម គឺខ្ញុំឮតែឈ្មោះទេ តែមុខមាត់មិនដែលស្គាល់

ហើយបើខ្ញុំមិនដែលស្គាល់ ក៏ខ្ញុំមិនដឹងថាគាត់អញ្ជើញមក ឬក៏មិនអញ្ជើញមក។ ខ្ញុំអត់ដឹង។

**ស៖** ហើយទស្សនកិច្ចហ្នឹងបានប្រព្រឹត្តទៅមុនពេលកម្មាភិបាលភូមិភាគនិរតីមកដល់ ឬក៏ក្រោយពេលកម្មាភិបាលភូមិភាគនិរតីមកដល់ហើយ បានមានទស្សនកិច្ចហ្នឹង?

**ឆ៖** បាទ ពេលហ្នឹង គឺគេធ្វើរយៈពេលខ្លីបានប្រហែលជាពីរបីថ្ងៃ ក៏ភូមិភាគនិរតីចូលមកដល់។ ខុសគ្នាតែពីរបីថ្ងៃប៉ុណ្ណឹង ស្រាប់តែឮឃើញភូមិភាគនិរតីចូលមកដល់ទឹកដីភូមិភាគពាយ័ព្យ។

**ស៖** នៅការដ្ឋានត្រពាំងថ្មហ្នឹង តើមានសម្ភារៈដូចជាឡានធំ ឡានប៊ុល ឬក៏គ្រឿងចក្រផ្សេងៗ ដែលគេត្រូវបានប្រើប្រាស់ដែរឬទេ? ហើយបើសិនជាមាននោះ តើមានច្រើនដែរឬទេ លោកអាចរៀបរាប់ជូនតុលាការស្តាប់បានទេ?

**ឆ៖** បាទ ពេលដែលសាងសង់អាងទឹកត្រពាំងថ្ម ឃើញតែមានឡានមួយគ្រឿង ឡានហ្នឹងគឺសម្រាប់ទាក់ថ្មបាយក្រៀម ដែលថ្មចាស់បុរាណនៅកន្លែងគេហៅ ស្ពានរាប។ ឃើញតែមួយគ្រឿងហ្នឹងទេ ហើយក្រៅពីហ្នឹងទៀត សង្កេតឃើញមានតែឡានត្រាវ៉ូ ឡានដឹកដី ជាពិសេសដែលច្រើនជាងគេបួនដប់គ្រឿងនោះ គឺមានត្រាក់ទ័រ។ ត្រាក់ទ័រសម្រាប់ដឹកថ្ម ដឹកខ្សាច់។ បាទ គឺមានឃើញតែប៉ុណ្ណឹងទេ សម្រាប់ឡានធំៗពុំដែលឃើញទេ។

**ស៖** តើលោកមានដឹងថាគ្រឿងចក្រ ឬក៏រថយន្តទាំងអស់ហ្នឹង គេយកមកពីណាទេ?

**ឆ៖** បាទ តាមខ្ញុំពិនិត្យមើលជាក់ស្តែង គឺសុទ្ធតែរបស់ចាស់ៗ របស់ដែលសល់ពីសម័យលន់នល់ ហើយគេយកមកប្រើប្រាស់ ពុំមានរបស់ថ្មីដែលចេញមកពីប្រទេសណាទេ ដែលខ្ញុំឃើញ តែក្រោយមកទៀត ខ្ញុំមិនបានឃើញ អានោះគឺខ្ញុំអត់និយាយ។

[១៣:៥៥:៤២]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

បាទ លោកសាក្សីខ្ញុំសូមអរគុណដែលបានឆ្លើយបំភ្លឺទាំងអស់នេះ។

លោកប្រធាន ខ្ញុំអស់សំណួរហើយ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ បាទ សូមអញ្ជើញ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោក លោកស្រីចៅក្រម។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី លោកបាននិយាយពីឈ្មោះ តាវ៉ាល់ យ៉ាងច្រើនទាំងថ្ងៃនេះ ទាំងពីម្សិលមិញ។ នៅក្នុងចម្លើយរបស់លោកឆ្លើយជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា លោកថាលោកជិតដិតជាមួយ តាវ៉ាល់។ បាទ អាហ្នឹងជាអ្វីដែលលោកបានឆ្លើយកាលពីម្សិលមិញ ហើយលោកក៏បានឆ្លើយនៅក្នុងជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជាថាលោកគឺថាត្រូវរ៉ូវគ្នាជាមួយ តាវ៉ាល់ ជិតដិតនឹងគ្នា ហើយលោកក៏ប៉ានទាំងតមាត់ជាមួយគាត់ផ្ទាល់ផងពេលខ្លះ។ គឺនៅត្រង់ទំព័រ 0028625 ជាភាសាអង់គ្លេស, បារាំង 0112--

**អ្នកបកប្រែ៖**

សូមអធ្យាស្រ័យលោកប្រធាន តាមអត់ទាន់ទេ លោកប្រធាន ញាប់ពេក។

**ប្រធានអង្គជំនុំ៖**

លោកមេធាវី វ៉ិចទ័រ កូប៉េ ញាប់ៗពេកអំមិញ ខាងអ្នកបកប្រែអត់អាចបកប្រែសម្តីដែលលោកប្រសាសន៍អំមិញអត់បានទេ សូមលោកនិយាយឡើងវិញ ហើយសូមនិយាយយឺតៗមួយៗដើម្បីឲ្យដំណើរការប្រព្រឹត្តទៅបានល្អ។

[១៣:៥៧:៥៤]

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ លោកប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី នៅពេលដែលលោកនិយាយថា លោកប៉ានតវ៉ាផ្ទាល់មាត់ជាមួយ តាវ៉ាល់ តើលោកចង់និយាយថាម៉េចនៅពេលដែលលោកឆ្លើយទៅប្រាប់អ្នកស៊ើបអង្កេតនៃមជ្ឈមណ្ឌលឯកសារកម្ពុជាថាអ៊ីចឹង?

**លោក ឈុំ សេង៖**

**ឆ៖** បាទ ពេលនោះខ្ញុំជាមួយនឹង តាវ៉ាល់ ខ្ញុំពិតជាជិតស្និទ្ធនឹងគាត់មែន។ ហើយត្រង់ចំណុច

ណាមួយដែលគាត់ប្រើខ្ញុំទៅធ្វើអី ទៅអីចេះចុះនាយអាយទៅ បើធ្វើ បើមាន ខ្ញុំមកវិញប្រាប់គាត់ថាមាន ពេលណាប្រើទៅមិនបាន ឬមិនអីថា “បងអត់បានទេ” “អ្នែងទៅដល់កន្លែងហើយ” ថា “ទៅដល់ហើយបង ប៉ុន្តែវាមិនមាន មិនដឹងធ្វើម៉េចបើវាមិនមាន”។ ប៉ុណ្ណឹងខ្ញុំហ៊ានតមែនប៉ុណ្ណឹង តែបើតខ្លាំងៗថាទេឱ្យទៅហើយមិនទៅ ឬក៏ទៅមិនដល់គោលដៅនោះ គឺមិនដែលទេបាទ មានអីចឹងមែន ពិតជាក់ស្តែងនេះសម្រាប់រូបខ្ញុំ។

**ស៖** ហើយចុះ តាវ៉ាល់ គាត់មានប្រតិកម្មយ៉ាងម៉េចដែរនៅពេលដែលលោកតវ៉ាជាមួយគាត់យ៉ាងដូច្នេះ?

**ឆ៖** ចំពោះគាត់ ដែលខ្ញុំនិយាយប៉ុណ្ណឹង គាត់មិនដែលថាអីផង មិនដែលឮថាមាត់តូចមាត់ធំថាអីប៉ុណ្ណឹងទេ ក៏ប៉ុន្តែគ្រាន់តែនិយាយមកខ្ញុំថា “ប្រយ័ត្នតឹងធូរ ក៏នៅលើវ៉ាល់” គាត់បានន័យថាវ៉ាល់ហ្នឹង គឺសម្រាប់ទប់ខ្យល់ សម្រាប់នេះខ្យល់ “ឱ្យតឹង ឬឱ្យធូរ នៅលើវ៉ាល់ អ្នែងត្រូវប្រយ័ត្ន” “បាទបង” ប៉ុណ្ណឹងខ្ញុំក៏ដើរចេញទៅ។

[១៤:០០:០២]

**ស៖** ខ្ញុំនឹងត្រឡប់មកនិយាយអំពីឈ្មោះតា វ៉ាល់ ឡើងវិញ។ ឥឡូវនេះខ្ញុំនិយាយអំពីពិធីសម្ពោធការដ្ឋានលើកទំនប់។ លោកទើបតែឆ្លើយនឹងសំណួរមុននោះ ហើយលោកបានឆ្លើយថា តាវ៉ាល់ ឡើងនិយាយក្នុងពិធីសម្ពោធបើកការដ្ឋាន ហើយប្រតិភូចិននៅហ្នឹង អឹង យឹងគួយ ក៏នៅទៅនោះ។ លោកចាំពាក្យសម្តី តាវ៉ាល់ ផ្ទាល់ៗដែរឬទេ? ឮគាត់និយាយថាម៉េច ផ្ទាល់ៗដែរទេ?

**ឆ៖** បាទ ពេលនុ៎ងគឺខ្ញុំនៅផ្ទាល់។ ខ្ញុំនៅផ្ទាល់ហើយ គាត់បាននិយាយដូចខ្ញុំនិយាយរួចហើយប្រាប់ថាចិនហ្នឹងគឺជនជាតិចិនហ្នឹងមក គឺមកសម្ពោធការដ្ឋាន មកទស្សនកិច្ចនៅអាង។ ក៏ប៉ុន្តែ តាវ៉ាល់ក៏បានឡើងរាយការណ៍អំពីសកម្មភាពដែលធ្វើទំនប់នេះ បាទ ប្រវែងប៉ុន្មានគីឡូ ហើយពលករដែលចូលរួម កម្លាំងដែលចូលរួមគឺប៉ុន្មាន។ ហើយក្នុងនោះគឺមានអ្នកបកប្រែ បាទ អ្នកបកប្រែមកក៏សម្រាប់ចិនគឺគ្រាន់តែងក់ក្បាលតែប៉ុណ្ណឹង។ មិនឮគាត់និយាយអីទេ គ្រាន់តែងក់ក្បាលតែប៉ុណ្ណឹងបាទ។

**ស៖** នៅពេល តាវ៉ាល់ និយាយទៅកាន់ប្រតិភូចិន តើទំនប់ហ្នឹងលើកបានប៉ុន្មានទៅហើយ? ពីខាងដើមមុននោះ លោកឆ្លើយថាពេលតា វ៉ាល់ ឡើងថ្លែងយ៉ាងដូច្នេះ គឺថាទំនប់ហ្នឹងធ្វើហើយបាន ៩៥ ភាគរយហើយ។ អីចឹងឬក៏យ៉ាងណា?

**ឆ៖** បាទ ទំបន់ពេលហ្នឹងគឺមិនទាន់បាន ៩៥ ភាគរយទេ។ ទំនប់ពេលហ្នឹង វាធ្វើប្រហែលជា

៦០ ទៅ ៧០ ភាគរយប៉ុណ្ណោះ។ ដែលធ្វើបាន ៩៥ភាគរយហើយហ្នឹង ពេលដែលពួក ជិតពួកនិរតីចុះមកដល់ ពេលនុ៎ងទើបទំនប់នោះបន្តបាន ៩៥ភាគរយ ពេលហ្នឹងឯងដែលទុកកម្លាំងខ្លះសម្រាប់រែកដីចាក់បំពេញខ្នង ឬក៏តាមក្បាលស្ពាន។

[១៤:០២:៥៧]

**សៈ** ខ្ញុំសុំអានសម្រង់ខ្លីមួយនៃចម្លើយដែលលោកឆ្លើយទៅមជ្ឈមណ្ឌលឯកសារកម្ពុជាទាក់ទងនឹងដំណើរទស្សនកិច្ច។ ERN ជាភាសាអង់គ្លេស 00728631, បារាំង 01123597 និងខ្មែរ 00730797 ដល់ 98។ ហើយក្រោយពីអានសម្រង់នេះហើយ ខ្ញុំនឹងសួរសំណួរទៅលោក។ "អឹងយើងគួយ បានបើកឡានមកនៅពេលគាត់មកទំនប់ត្រពាំងថ្ម ពួកគេបានឃើញកងរបស់យើង។ តាវ៉ាល់សួរកម្មករឲ្យគ្រវីដៃ លើកគ្រវីដៃជាមួយនឹងក្រណាត់ក្រហម ពីព្រោះគាត់ចង់ឲ្យធ្វើដូច្នេះឯង អ៊ីចឹងមែនឬ?" "បាទ" លោកឆ្លើយអ៊ីចឹង។ គឺថា "ចិន -- យើងៗ ពេលដែលប្រតិភូចិនគាត់ៗដើរដូចថារាងឆ្គងណាស់ ប៉ុន្តែគេមិនឲ្យយើងសើចទេ។ យើងនិយាយស្ងាត់ៗថា ពួកប្រតិភូចិនដូចជារាងឆ្គួតៗពីព្រោះពាក់មួកអត់បានត្រឹមត្រូវពាក់ខុស។ តើ តាវ៉ាល់ ឃើញ តាវ៉ាល់ បែរទៅនិយាយជាមួយចិនទេ? តាវ៉ាល់ ចេះនិយាយចិនទេ? ឆ្លើយថា៖ អត់ទេ គាត់គ្រាន់តែញញឹម ស្វាគមន៍ប្រតិភូចិន។ តើប្រតិភូចិនចេះនិយាយខ្មែរទេ? គាត់ប្រហែលជាចេះ គាត់ចេះតែពាក្យៗស្វាគមន៍ពីរបីម៉ាត់ទេ។ គាត់មកជាមួយតាហ៊ីង្ស ដែរទេ? បាទ គាត់មកជាមួយ តាហ៊ីង្ស ម្តងដែរ។" លោកសាក្សី លោកនៅចាំថាលោកធ្លាប់បានឆ្លើយយ៉ាងដូច្នេះទៅប្រាប់អ្នកស៊ើបអង្កេតមជ្ឈមណ្ឌលឯកសារកម្ពុជាទេ?

**ឆៈ** បាទ ពេលហ្នឹង ខ្ញុំពិតជាបានឆ្លើយមែន។ ព្រោះដែលចិនមក គឺយើងឈរទះដៃ ដូចខ្ញុំបាននិយាយមុន ហើយចិនហ្នឹងគេចង់បានមួកស្លឹកត្នោត ដេរមួកស្លឹកត្នោតហ្នឹងគេដាក់ប្ញកក្រហមខាងមុខខ្សែចង្កា ក៏ប៉ុន្តែដល់ចិនយកពាក់វាដាក់អាមុខទៅក្រោយ។ ខ្ញុំអ្នកនិយាយផ្ទាល់ថា "អ៊ូ! អ្អែងមើលចិនអ្ហ៎ាដូចឆ្កួតដល់អ្ហ៎ា! គេដាក់ឲ្យខ្សែចង្កាពាក់ទៅមុខវាដាក់មកក្រោយ" ហើយអាមួយហ្នឹងវា-- ក៏ខ្ញុំថា "អ្អឺះ! កុំឲ្យនិយាយឮអានេះ តែព្ញតិចគេ..." ពេលនុ៎ង គឺខ្ញុំជាអ្នកនិយាយផ្ទាល់។ បាទ គ្មានអ្នកណាទេ បាទ។

[១៤:០៦:០៣]

**សៈ** លោកនិយាយថា តាវ៉ាល់ ឡើងនិយាយនៅក្នុងពិធីសម្ពោធនុ៎ង តាហ៊ីង្ស មានឡើងនិយាយដែរទេ?

**ឆៈ** បាទ នៅពេលហ្នឹង តាហ៊ីង្ស តួនាទីភារកិច្ចរបស់គាត់ជាគណៈតំបន់។ ចូលរួមនៅកន្លែង

ហ្នឹង គឺគាត់ពុំបាននិយាយអីទេ គ្រាន់តែអង្គុយក្បែរជនជាតិចិនតែប៉ុណ្ណោះ។

**ស៖** លោកសាក្សី ខ្ញុំចង់សួរលោកបន្ថែម សូមឲ្យលោកគិតឲ្យបានហ្មត់ចត់បន្តិចនូវអ្វីដែលខ្ញុំសួរទៅលោកបន្តិចទៀតនេះ។ យើងដឹងហើយថា ប្រតិភូចិនបានមកពិនិត្យមើលទំនប់នោះ នៅពេលធ្វើពិធីសម្ពោធបើកការដ្ឋាននោះ គឺថានៅពាក់កណ្ដាលឆ្នាំ១៩៧៧ ហើយយើងក៏ដឹងដែរថា តាហ៊ីង្ស ហើយនិង តាវ៉ាល់ ត្រូវបានចាប់ខ្លួននៅក្នុងខែមិថុនា ១៩៧៧ ប្រាំមួយខែមុនពិធីសម្ពោធនេះ។ តើលោកអាចពន្យល់បានទេថា តាវ៉ាល់ ហើយនិង តាហ៊ីង្ស ឡើងនិយាយក្នុងពេលនុំងប្រាំមួយខែ ក្រោយពួកគាត់បានចាប់ខ្លួនហើយនោះ?

**ឆ៖** បាទ នៅពេលដែលគេធ្វើពិធីសម្ពោធអាងទឹកត្រពាំងថ្ម ពេលនោះ តាវ៉ាល់, តាហ៊ីង្ស ហ្នឹងគេមិនទាន់ចាប់ខ្លួនទេ។ គេចាប់ៗខ្លួនពេលដែលនិរតីចុះមកដល់។

**ស៖** ប៉ុន្តែឥឡូវហ្នឹងខ្ញុំប្រាប់លោក គឺថាមានភស្តុតាងដែលមិនអាចប្រកែកបាន ដែលថាដំណើរទស្សនកិច្ចហ្នឹង គឺគេធ្វើឡើងនៅក្នុងខែធ្នូ ៧៧ ភាគីទាំងអស់យល់ស្របថាអ៊ីចឹង ហើយឯ តាវ៉ាល់ និង តាហ៊ីង្ស នេះចាប់ខ្លួននៅខែមិថុនា ៧៧។ ដូច្នេះ ពួកគាត់ទាំងពីរនេះ មិនអាចមានវត្តមានឡើងនៅក្នុងពិធីសម្ពោធនេះបានទេ។ តើអ៊ីចឹងត្រឹមត្រូវដែរឬទេ?

[១៤:០៨:៣៦]

**ឆ៖** បាទ រឿងហ្នឹង គឺពិតមិនត្រឹមត្រូវ។ មិនត្រឹមត្រូវត្រង់ចំណុចណា? មិនត្រឹមត្រូវត្រង់ចំណុចដែលពិធីសម្ពោធហ្នឹង គឺគេមិនទាន់ចាប់ តាវ៉ាល់ ទេ។ ក្រោយមកទៀត ពេលនិរតីចូលមកដល់ទឹកដីពាយ័ព្យ បានគេចាប់ តាវ៉ាល់ ទៅ។ បាទ ហើយបើសិនជាអីផ្សេងទៀត ខ្ញុំក៏សូមទោសដែរប្រហែលជាខ្ញុំច្រឡំថ្ងៃ ខែ ឆ្នាំ។

**ស៖** តើលោកនេះ ប្រាកដ១០០ភាគរយទេ អំពីពេលវេលានេះ?

**ឆ៖** ពេលវេលានោះ វាកន្លងទៅជាង៣០ឆ្នាំទៅហើយ ហើយខ្ញុំក៏ពុំអាចចាំបានទាំងអស់ដែរ។ ដូច្នេះ អ្វីៗទាំងអស់ បើខ្ញុំឆ្លើយច្រឡំ ក៏សូមមេត្តាអធ្យាស្រ័យ។

**ស៖** លោកសាក្សី ខ្ញុំក៏បានបញ្ជាក់នូវអ្វីដែលលោកបានឆ្លើយ និងអ្វីបានឃើញនៅឯទំនប់។ លោកថា តាវ៉ាល់ ឡើងនិយាយស្វាគមន៍ ប្រតិភូចិន គឺថាមិនអាចទៅរួចទេ។ ដូច្នេះ មិនត្រឹមតែថាលោកខុសនូវកាលបរិច្ឆេទទេ គឺថាខុសតាំងពីការថា គាត់ឡើងនិយាយនៅពេលនោះផង។ តើខុសអ៊ីចឹងមែនទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំទាន់អាលឆ្លើយតប! សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។ ការសួរសំណួរនេះដូចជាមិនត្រឹមត្រូវទេ គួរតែសួរបញ្ជាក់ថា តើគណៈប្រតិភូចិនមកការដ្ឋាននោះច្រើនដងដែរឬក៏អត់បានត្រឹមត្រូវ ព្រោះបើសួរអ៊ីចឹងអាចឲ្យមានការច្រឡំជាមួយនឹងកាលបរិច្ឆេទ ហើយនិងច្រឡំជាមួយនឹងការមកទស្សនកិច្ចច្រើនជាន់គ្នា។

**លោក វ៉ិចទ័រ កូប៉េ៖**

ប្រាកដហើយលោកព្រះរាជអាជ្ញា យើងនិយាយអំពីប្រតិភូចិនឈ្មោះ ឆឹង យឹងគួយ។ បាទ នាយករដ្ឋមន្ត្រីចិនមកធ្វើដំណើរទស្សនកិច្ច ១៥ថ្ងៃនៅក្នុងខែធ្នូ ៧៧។ ខ្ញុំដឹងថាតំណាងសហព្រះរាជអាជ្ញាកំពុងតែចង់រក្សានូវព័ត៌មាននេះ នូវភស្តុតាងនេះ ហើយយើងខ្ញុំក៏ចង់ដឹងច្បាស់នូវអ្វីដែលសាក្សីនិយាយនោះផងដែរ។

**ប្រធានអង្គជំនុំ៖**

បាទ អញ្ជើញសាក្សីឆ្លើយតបទៅនឹងសំណួរដែលសួរបញ្ជាក់ដោយមេធាវីការពារក្តី នួន ជា អម្បាញ់មិញនេះ។ ក៏ប៉ុន្តែយើងចង់បញ្ជាក់ប្រាប់សាក្សីឲ្យបានច្បាស់លាស់ ដើម្បីញែកឲ្យបានច្បាស់លាស់រវាងដំណើរការសម្ពោធ ហើយនិងដំណើរការទៅទស្សនកិច្ច វាខុសគ្នា មិនមែនដូចគ្នាទេ លោកត្រូវគិតឲ្យបានច្បាស់លាស់ ពីព្រោះចំណុចនេះក៏ជាចំណុចសំខាន់នៃការផ្តល់សក្ខីកម្មសាក្សីដែរ របស់សាក្សីដែរ។ អ៊ីចឹងគឺកុំឲ្យច្រឡំគ្នារវាងទៅទស្សនកិច្ច ទៅមើលទៅអីហ្នឹង វាផ្សេងពីទៅសម្ពោធ វាខុសគ្នានូវអង្គហេតុ នូវដំណើរការពីរហ្នឹង គឺខុសគ្នា។ លោកប្រយ័ត្នប្រយែងឲ្យមែនទែន សូមឆ្លើយនូវសំណួរបាទ។

[១៤:១២:៥០]

**លោក ឈុំ សេង៖**

**ឆ៖** សំណួរហ្នឹងខ្ញុំស្តាប់មិនទាន់បាន ដូច្នេះ សូមលោកសួរម្តងទៀត។

**ប្រធានអង្គជំនុំ៖**

លោកមេធាវីវ៉ិចទ័រ កូប៉េ តាំងសំណួរចុងក្រោយរបស់លោកសាជាថ្មីម្តងទៀត។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** បាទ ខ្ញុំសូមរៀបសំណួរឡើងវិញ។ លោកសាក្សី លោកនិយាយថា មានពិធីបើកសម្ពោធ បើកការដ្ឋានដែលនាយករដ្ឋមន្ត្រីចិន អ៊ឹង យ៉ឹងគួយ ក៏មានវត្តមាននៅទីនោះ។ ហើយពេលនោះ លោកនិយាយថា ទំនប់នោះវាហើយប្រហែលជា ៦០ ទៅ ៧០ភាគរយហើយ។ ហើយលោកឆ្លើយថា តាវ៉ាល់ឡើងនិយាយ ហើយតាហ៊ីង្ស ក៏មានវត្តមានក្នុងពេលនោះដែរ។ ប៉ុន្តែទាំងតាហ៊ីង្ស ទាំងតាវ៉ាល់ ត្រូវបានគេចាប់ខ្លួនមុនពេលបើកពិធីសម្ពោធស្តីអំពីការលើកទំនប់ហ្នឹង។ ដូច្នេះ បញ្ជាក់ឲ្យឃើញថា តាហ៊ីង្ស និង តាវ៉ាល់ មិនមានវត្តមាននៅទីនោះទេ នៅពេលនោះ ត្រឹមត្រូវដែរឬទេ?

**លោក ឈុំ សេង៖**

**ឆ៖** បាទ ពិតជាមិនត្រឹមត្រូវ ព្រោះកាលដែលសម្ពោធអាងទឹកត្រពាំងថ្មនោះ ដែល តាវ៉ាល់ ឡើងនិយាយ ពេលនោះ តាវ៉ាល់ បាននិយាផ្ទាល់ថា គេមកសម្ពោធនិងមកទស្សនកិច្ច។ គាត់និយាយសម្ពោធ ក៏គាត់និយាយ ថាមកទស្សនកិច្ច ក៏គាត់និយាយ។ ដូច្នេះ ខ្ញុំគ្រាន់តែនិយាយតាមភាសាតាវ៉ាល់ទេ។ ដូចជា លោកប្រធាន បានលើកមុនថា ទស្សនកិច្ចផ្សេង ហើយនិងសម្ពោធផ្សេង។ ដូច្នេះ ភាសាទស្សនកិច្ច និងភាសាសម្ពោធនេះ គឺខ្ញុំបាទនិយាយតាមភាសា តាវ៉ាល់ ដែលខ្ញុំបាទបានឃើញ។ ហើយចំពោះ តាវ៉ាល់, តាម៉ោង, អ៊ឹង យ៉ឹងគួយ នោះ គឺបានមកនៅហ្នឹងស្ពានទី១ គេពុំទាន់ចាប់ខ្លួនគាត់ទេ។

**ស៖** សូមអរគុណលោកសាក្សី ខ្ញុំបន្តទៅសួរសំណួរផ្សេងទៀត ប៉ុន្តែពាក់ព័ន្ធនឹង តាវ៉ាល់ ដដែល។ តើ តាវ៉ាល់ ជាបញ្ញវ័ន្ត ឬក៏មិនមែនទេ តាមការចងចាំរបស់លោក?

[១៤:១៥:៤៧]

**ឆ៖** បាទតាម តាវ៉ាល់ បើតាមខ្ញុំស្មាន គឺមិនដឹងជានិស្សិតបញ្ញវន្តខ្ញុំមិនដឹងទេ។ ក៏ប៉ុន្តែតាមមើលកម្រិតសរសេរ ខ្ញុំថាមនុស្សនេះគឺមនុស្សអ្នកចេះគួរសម ព្រោះការសរសេររបស់គាត់ផ្ទាល់ដៃគាត់ គឺមិនដែលដល់ក្រដាស ហើយក្រដាសមួយទំព័រសរសេរតែ បួនប្រាំបន្ទាត់តែប៉ុណ្ណឹង។ ជាក់ស្តែង ដូចសរសេរមកខ្ញុំអ៊ីចឹង គាត់ដាក់ថា៖ “សមមិត្តសេង ជាទីស្នេហាបំផុត! សូមសមមិត្តអនុវត្ត” ស្អីៗទៅអាហ្នឹងស្រេចនឹងគាត់សរសេរ ឬក៏គាត់ថា៖ “ថ្ងៃស្អែកសមមិត្តត្រូវទៅដកកម្លាំងពីកូនខ្លែងមកអាងត្រពាំងថ្មវិញ” អ៊ីចេះ ដែលគាត់សរសេរមកខ្ញុំគឺថាសរសេរម្តងហ្នឹងឯង។ ហើយខ្ញុំក៏ធ្លាប់ឃើញគាត់សរសេរជាញឹកញាប់ តាំងពីគូរអាងត្រពាំងថ្ម គឺផ្ទាល់ៗដៃគាត់គឺមិនដែលដល់ក្រដាសទេ សរសេរតែបញ្ឈរអ៊ីចឹង។ បានខ្ញុំថាមនុស្សតាវ៉ាល់ គឺជាមនុស្ស មិនមែនជាមនុស្សល្ងង់ប៉ុន្មានទេ បាទ។

**ស៖** តើលោកធ្លាប់ដែលឮសួរគាត់និយាយភាសាបារាំងទេ?

**ឆ៖** បាទ ខ្ញុំពុំដែលឮគាត់និយាយភាសាបារាំងទេ។ បើឃើញៗតែគាត់ផឹកស្រាសាច់ដុំ គឺគាត់អ្នកផឹកស្រាសាច់ដុំពេលនោះ គឺខ្ញុំបាទបានឃើញមែន។

**ស៖** មានសាក្សីមួយរូបដែលបានឆ្លើយប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជាថា នៅពេលដែលតាហ៊ីង្ស ហើយនិង តាវ៉ាល់ ដើរនៅលើទំនប់ហ្នឹងទាំងពីរនាក់ហ្នឹងគឺនិយាយភាសាបារាំងដាក់គ្នា។ លោកដែលឮ ឬក៏កត់សម្គាល់ឃើញគាត់និយាយភាសាបារាំងទេ?

**ឆ៖** ខ្ញុំបាទពុំដែលឮទេ ពុំដែលឮសួរគាត់និយាយភាសាបារាំងទេ។

**ស៖** ក្នុងចម្លើយលោកឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា លោកសាក្សីគឺ ERN អង់គ្លេស គឺ 00728629, បារាំង 01123594 និងខ្មែរ 00730793។ លោកបានឆ្លើយប្រសិនបើ តាវ៉ាល់ មកពិនិត្យមើលការដ្ឋានលើកទំនប់នោះ គឺថាលោកត្រូវស្ដាប់ឮៗ ស្ដាប់សំឡេងចប ប្រសិនណាជាសំឡេងចបហ្នឹង-- *(គ្មានការបកប្រែ)*--

**ប្រធានអង្គជំនុំ៖**

អត់មានភាសាខ្មែរ។ យ៉ាងម៉េចទៅ ខាងបកប្រែភាសា អត់មានភាសាខ្មែរទេអំមិញ។

*(មានបញ្ហាបច្ចេកទេស)*

[១៤:១៩:៥៤]

**ប្រធានអង្គជំនុំ៖**

បាទ លោក វ៉ិចទ័រ កូប៉េ សូមចាប់ផ្ដើមម្ដងទៀត សំណួរចុងក្រោយអម្បាញ់មិញនេះ ហើយមិញបានមានការបកប្រែភាសាដាច់ច្រើន បាច់ឆ្ងាយ ហើយអាចទំនងជាអ្នកបកប្រែ បកមិនទាន់។ សូមលោកយឺតជាងមុនបន្តិច ដើម្បីឲ្យអ្នកបកប្រែ បកទាន់បានល្អ បាទ។

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ ខ្ញុំនឹងនិយាយឲ្យយឺតបន្តិចលោកប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី ខ្ញុំចង់សួរតទល់ជាមួយលោក ដោយយកសម្រង់លោកឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលក្នុងនោះលោកបានឆ្លើយថា លោកចាំថានៅពេលដែល តាវ៉ាល់ មកដល់ការដ្ឋានលើកទំនប់ហ្នឹង គឺលោកឮសូរដំណើរគាត់ដើរយ៉ាងរហ័ស ហើយលោកថា បើសិនណាលោកឮសូរ

តាវ៉ាល់ ដើរមកយ៉ាងរហ័សអ៊ីចឹង គឺម្នាក់ៗគឺថា ម្នាក់គឺថាខ្លាចណាស់ ឮសូរ តាវ៉ាល់ មកអ៊ីចឹង។ តើលោកបានឆ្លើយថាអ៊ីចឹងប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជាមែនទេ?

**លោក ឈុំ សេង៖**

**ឆ៖** បាទ ពិតមែនណាស់។ ខ្ញុំបានឆ្លើយប្រាប់ឯកសារកម្ពុជាមែន ព្រោះប្រជាពលករ ប្រជាជនដែលរែកដីនោះ តាមខ្ញុំស្មានទាំងរូបគេ ក៏ដូចរូបខ្ញុំ គឺខ្លាចតាវ៉ាល់ ជាងខ្លាចខ្លា។ ពេលគ្រាមួយនោះ គឺផែការវាយសម្រុកទាំងយប់ ទាំងថ្ងៃ។ ពេលនោះ តាវ៉ាល់ បានក្លែងខ្លួនស្លៀកពាក់ខោអាវកណ្ដោចកណ្ដាចយប់ ហើយពាក់មួកស្លឹកត្នោត ដោយដៃម្ខាងគឺកាន់ដំបង។ ពេលនោះ ដើរមកមើល បើសិនជាមិនឃើញអាណា បើអាណាមិនកាប់ដីទេ ដឹងតែត្រូវក្បាលមួយដំបងហើយ។ ដូច្នេះ តែព្រនង់ អ្នកៗ ដឹងថាតាវ៉ាល់ យើងក៏ចាំតែមើល ដូចជាខ្ញុំនៅកណ្ដាលអ៊ីចេះ ចាំមើលស្ដាប់ត្រចៀកសងខាង គឺស្ដាប់សងខាងបើសិនជាឮពីខាងត្បូង គឺឮថា ពុបប៉ាប់ៗ យើងឆាប់ពុបប៉ាប់ដូចគេទៅ។ បើមកពីជើងឮ ពុបប៉ាប់ៗ យើងត្រូវតែពុបប៉ាប់ដូចគេទៅ ហើយបើយើងនៅកណ្ដាល បើគេចុងដើម គេធម្មតា យើងធម្មតានឹងគេទៅ។ ព្រោះពេលនោះ តាវ៉ាល់ ដើរយប់ ដើម្បីដើរពិនិត្យ។ បាទ រឿងនេះ ខ្ញុំពិតជាបាននិយាយមែន។

[១៤:២២:៤៨]

**ស៖** ឥឡូវនេះ លោកនិយាយនៅក្នុងចម្លើយរបស់លោកដែរថា នៅត្រង់ ERN ជាភាសាអង់គ្លេស 00728623, ហើយបារាំង 01123589, ខ្មែរ 00730783។ លោកឆ្លើយថា៖ "កំហុសតែម្យ៉ាងគត់សម្រាប់ តាវ៉ាល់ ហ្នឹងគឺសម្លាប់មនុស្សហ្នឹងឯង"។ តើនេះគឺជាអ្វីដែលលោកបានឆ្លើយប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជាមែនទេ? ហើយបើមែននោះ តើលោកចង់និយាយថាដូចម្ដេច?

**ឆ៖** បាទ ព្រោះតាវ៉ាល់ គឺថ្នាក់ដឹកនាំកងចល័តតំបន់។ ដូច្នេះ ការសម្លាប់នេះ ខ្ញុំជឿថា ប្រសិនបើគ្មានការអនុញ្ញាតពីតាវ៉ាល់ ឬតាវ៉ាល់ បន្ទូរដៃឲ្យប្រធានកង ក៏ប្រធានកងក៏មិនប៊ានធ្វើអ៊ីចឹង ប្រធានវរៈ ក៏មិនប៊ានធ្វើអ៊ីចឹង ព្រោះនេះជាគំនិតរបស់ តាវ៉ាល់ ជាការបញ្ជារបស់តាវ៉ាល់។ នេះជាកំហុសធ្ងន់ធ្ងររបស់គាត់។

**ស៖** លោកសាក្សី រូបដែលលោកបានលាបគូរ លាបពណ៌សម្រាប់ តាវ៉ាល់ ហ្នឹងគឺវាច្បាស់លាស់ហើយ ខ្ញុំមិនដឹងថានៅពេលដែលលោកឮដំណឹងថា ពេលគេទៅហៅឲ្យទៅរៀនសូត្រ ហើយលោកថាក្រោយមក បើអ្នកណាត្រូវបាន តាវ៉ាល់ ហៅទៅរៀនសូត្រហ្នឹង មិនដែលបានវិលត្រឡប់មកវិញទេ។ ហើយក្រោយមក គឺ -- តើចំណុចនេះត្រឹមត្រូវដែរ ឬក៏អត់ទេ?

[១៤:២៤:៥៨]

**ឆ៖** បាទចំណុចនេះព្រោះតាវ៉ាល់ ឧស្សាហ៍ហៅទៅប្រជុំបាទ។ ត្រង់ភាសានេះ ប្រជុំ និងរៀនសូត្រដូចនិយាយភាសាតែមួយ។ អាទៅប្រជុំក៏គេនិយាយរៀនសូត្រ រៀនសូត្រក៏គេហៅប្រជុំអ៊ីចេះ។ ដូច្នេះ គ្រប់គ្នាឱ្យតែឮ តាវ៉ាល់ ហៅទៅថា "អូ៎!ទៅប្រជុំ" ខ្លះគេថាទៅរៀនសូត្រ ខ្លះគេហៅទៅរៀនសូត្រ គាត់ទៅប្រជុំ។ ពេលខ្លះហៅទៅ គឺគាត់សុំព្រមានជាក់ស្ដែងដូចជាលើកកាប់ដីកប្បាសនៅជប់វ៉ារី។ ពេលនោះ ហៅប្រជុំហើយគាត់សួរ ទៅដល់ភ្លាម គឺគាត់ចែកបារីម្នាក់មួយសុងៗអីទៅហើយពុះខ្នុរ កាត់ខ្នុរឱ្យហូប។ ហើយគាត់ប្រធានវរៈឡើងរាយការណ៍។ ពេលនោះគឺខ្ញុំភ្លេចឈ្មោះគាត់ឡើងរាយការណ៍ថា ទី១ អំពីសកម្មភាព អំពីការងាយស្រួលនិងការលំបាក។ ហើយតាហ្នឹងគាត់រាយការណ៍ថា ពិតជាលំបាកណាស់ ចំណុច១ គឺវាមានអង្រ្គង ដុបស្តុក អត់មានកាំបិតកាប់ កាប់តែនឹងចប –ហើយប្រយ័ត្នដែរ អាកាប់ចបនឹងបាក់ក៏ខ្លាំងដែរ– ពេលនោះ តាវ៉ាល់ ក៏ប្រាប់ថាបើចង់ស្រួលគាត់នឹងបើកផ្លូវជាតិលេខ៦ ឱ្យពួកមិត្តឯងទាំងអស់គ្នាដាំកប្បាសលើថ្នល់ជាតិលេខ៦នេះ។ ពេលនោះបារីក៏ដកហូតយកទៅវិញ ពេលនោះ គឺដឹងតែបណ្តេញចេញ គឺរត់ប៉ែងជើងគ្នាហើយ ពេលនុ៎ង។

[១៤:២៧:០១]

**ស៖** លោកសាក្សីប្រហែលជាសំណួរខ្ញុំនោះគឺថា លោកស្តាប់ទៅមិនបានយល់បានល្អទេយ៉ាងមើលទៅ។ សំណួរខ្ញុំសួរអ៊ីចេះ ថានៅពេលដែលលោកបានដឹងថា តាវ៉ាល់ ហៅទៅរៀនសូត្រ ហើយមិនបានត្រឡប់មកវិញនេះ តើលោកសប្បាយចិត្តទេ ដែលថាមេឃាតករនេះ មនុស្សកំណាចម្នាក់នេះនៅពេលដែលគេចាប់ខ្លួន លោកសប្បាយចិត្តទេ?

**ឆ៖** បាទ--

**ប្រធានអង្គជំនុំ៖**

លោកសាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

លោកប្រធាន ខ្ញុំសូមជំទាស់។ សួរមនុស្សម្នាក់ថាសប្បាយចិត្តដែរឬទេ ដែលមនុស្សម្នាក់ទៀតហ្នឹងត្រូវបានគេសម្លាប់នោះ។ សំណួរហ្នឹងមិនសមស្របទេ ក៏ប៉ុន្តែក្នុងសំណួរនេះដូចជាមិនទំនាក់ទំនងរវាងការចាប់ខ្លួន ឬក៏សម្លាប់របស់ តាវ៉ាល់ ហើយនិងការដែលគាត់ជាមនុស្សឃោរឃៅ។ អ៊ីចឹងមិនបានបង្ហាញទំនាក់ទំនងនេះទេ មុននឹងសួរសំណួរនេះ មុននឹងសួរសំណួរដែលថាចង់បញ្ហាញពីទំនាក់ទំនង

រវាងការចាប់ខ្លួនគាត់ ហើយនិងការដែរគាត់ឃោរឃៅនេះ ត្រូវតែបង្ហាញមូលដ្ឋានសិន ទំនាក់ទំនងនេះសិនលោកប្រធាន។

[១៤:២៨:២១]

**លោក វ៉ិចទ័រ កូប៉េះ**

លោកតំណាងសហព្រះរាជអាជ្ញា គឺថាលោកច្រឡំខ្ញុំទាំងស្រុកហើយ សំណួរខ្ញុំនេះគឺសួរថាតើការចាប់ខ្លួន -- បាទខ្ញុំសូមរៀបសំណួរឡើងវិញ។ តើការហៅឲ្យគេទៅប្រជុំ ហើយមិនត្រឡប់ទៅត្រឡប់មកវិញនេះ គឺជារឿងមួយដែលអាចធ្វើឲ្យសាក្សីរូបនេះគាត់សប្បាយចិត្តហើយពេលនោះពីព្រោះគាត់ក៏បាននិយាយអំពី តាវ៉ាល់ នេះច្រើនហើយ ហើយគឺដូចខ្ញុំយល់ថា សំណួរនេះគឺជាសំណួរដែលត្រឹមត្រូវហើយ ព្រោះខ្ញុំសួរអំពីការចាប់ខ្លួន។

**សួរដោយលោក វ៉ិចទ័រ កូប៉េះ**

**ស៖** ខ្ញុំសូមរៀបសំណួរឡើងវិញលោកសាក្សី។ តើ តាវ៉ាល់ នៅពេលដែល តាវ៉ាល់ បាត់ខ្លួនហើយអត់មកក្តាប់ ក្តោបក្តាប់វិញនេះ តើលោកសប្បាយចិត្តទេ?

**លោក ឈុំ សេង៖**

**ឆ៖** ទាំងអស់ក្រោមការគ្រប់គ្រងរបស់ តាវ៉ាល់ គ្មានអ្នកណាសប្បាយចិត្តទេ មានតែលើកដៃទៅលើថា "សាធុ!ៗ"។ នេះគឺកាម្ម: គឺអំពើដែលគាត់បានសាង សាងល្អបានល្អ សាងអាក្រក់បានអាក្រក់។ មានតែពលករទេដែលផ្តន្ទាថែម ឲ្យឯងស្លាប់ទៅ មានតែប៉ុណ្ណឹងទេបាទ។

[១៤:២៩:៤២]

**ស៖** សូមអរគុណលោកសាក្សី។ លោកក៏បានឆ្លើយផងដែរនៅពេលដែលលោកឆ្លើយ ខ្ញុំជឿថាជាសំណួររបស់ខាងសហព្រះរាជអាជ្ញាថា នៅពេលថា តាវ៉ាល់ ជាមនុស្សស្មោះស្ម័គ្រ ស្មោះត្រង់នឹងបក្ស លោកឆ្លើយថាគាត់ហ្នឹងជាមនុស្សស្មោះត្រង់នឹងបក្ស បើស្មោះត្រង់អ៊ីចឹងហេតុអីក៏គេចាប់ខ្លួនគាត់?

**ឆ៖** បាទ ពេលហ្នឹងគាត់បាននិយាយមែន ប្រាប់មកយើងទាំងគេទាំងអស់ស្មោះត្រង់នឹងបក្សហើយចំពោះគាត់ក៏ស្មោះត្រង់នឹងបក្ស។ ដូច្នេះវាបានឮត្រឹមតែបបូរមាត់ ត្រឹមសម្តី តែចិត្តគំនិតរបស់គាត់ គឺយើងមិនអាចមើលឃើញ មិនដឹងជាគេស្មោះត្រង់ ឬមិនស្មោះត្រង់គឺខ្ញុំអត់ដឹង។

**ស៖** ខ្ញុំយល់ហើយនូវអ្វីដែលលោកកំពុងតែនិយាយនេះ។ តែសំណួរថាតើមូលហេតុអ្វី ឬក៏នៅពេលនោះលោកមានបានស្តាប់ឮទេថាហេតុអ្វីបានជា តាវ៉ាល់, តាហ៊ីង្ស និងអ្នកដទៃទៀតត្រូវបាន

ចាប់ខ្លួន? លោកដឹងទេ ថាហេតុអីក៏ៗពួកគាត់ត្រូវបានគេហៅទៅរៀនសូត្រហើយ អត់ឃើញមកវិញ មូលហេតុអី?

**ឆ៖** បាទ ខ្ញុំបាទពុំដឹងជាមូលហេតុ មកពីមូលហេតុអ្វីទេ ព្រោះគាត់ក៏ជាថ្នាក់ដឹកនាំដែរ ក៏ប៉ុន្តែពេលដែលនិរតីចុះមកដល់សម្លាប់កម្មាភិបាលភូមិភាគពាយ័ព្យ គឺត្រូវបាត់ខ្លួនបណ្តើរៗប៉ុណ្ណឹងទេ តែត្រង់ថាមកពីមូលហេតុអី ឬមកពីរឿងអី គឺខ្ញុំអត់ដឹងអត់ដល់។

**ស៖** លោកសាក្សី ខ្ញុំត្រូវសួរតទល់ជាមួយលោកនៅចម្លើយរបស់អ្នកផ្សេងដែលចម្លើយនោះក៏និយាយពី តាវ៉ាល់ និង តាហ៊ីង្សដែរ ខ្ញុំសូមអានចម្លើយរបស់អ្នកផ្សេង។

ហើយលោកប្រធានខ្ញុំសូមការអនុញ្ញាតដើម្បីបង្ហាញឈ្មោះសាក្សីម្នាក់នេះ គឺជាមនុស្សដដែល ដែលខ្ញុំបានឆ្លើយពីម្សិល គឺE3/9076 ខ្ញុំសូមបង្ហាញទំព័រភាសាខ្មែរតែមួយទំព័រទេដើម្បីសួរសាក្សី ថាតើគាត់ស្គាល់មនុស្សម្នាក់នេះទេ ស្គាល់សាក្សីដែលឆ្លើយប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជាឬអត់?

[១៤:៣២:៣៥]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។

**សួរដោយលោក វ៉ិចទ័រ កូប៉េះ៖**

**ស៖** លោកសាក្សី សូមលោកកុំនិយាយឈ្មោះមនុស្សម្នាក់នេះឲ្យចេញមកក្រៅអី ប៉ុន្តែលោកគ្រាន់តែអានបានហើយ លោកស្គាល់មនុស្សម្នាក់នេះទេ? បាទ លោកគ្រាន់តែឆ្លើយថាស្គាល់ ហើយបើមិនស្គាល់ថាមិនស្គាល់អ៊ីចឹងបានហើយ កុំបញ្ចេញឈ្មោះគាត់។ លោកស្គាល់បុរសម្នាក់នេះទេ?

**ប្រធានអង្គជំនុំ៖**

បញ្ហាប្រដាប់ឧបករណ៍បកប្រែភាសា។

លោកវ៉ិចទ័រ កូប៉េ សួរសំណួរគាត់សាជាថ្មីម្តងទៀត សំណួរលោកចុងក្រោយអម្បាញ់មិញនេះ។

**សួរដោយលោក វ៉ិចទ័រ កូប៉េះ៖**

**ស៖** លោកសាក្សី លោកស្គាល់បុរសម្នាក់នេះទេ កុំនិយាយបញ្ចេញឈ្មោះគាត់ ប៉ុន្តែលោកស្គាល់ ឬក៏មិនស្គាល់?

**លោក ឈុំ សេង៖**

**ឆ៖** បាទ ខ្ញុំពិតជាស្គាល់មនុស្សនេះ។

**ស៖** លោកស្គាល់គាត់ច្បាស់ទេ?

**ឆ៖** បាទ ស្គាល់ច្បាស់។

[១៤:៣៥:៣៧]

**ស៖** តើគាត់គឺជាមនុស្សដែលស្គាល់ តាវ៉ាល់ ច្បាស់លាស់ដែរទេ នៅពេលនោះ?

**ឆ៖** បាទ ពេលហ្នឹង គឺកងខ្ញុំ និងកងគេនោះ ខុសគ្នា ហើយត្រង់ដែលគេច្បាស់លាស់ គេជិតដិត នឹង តាវ៉ាល់ ច្បាស់នឹង តាវ៉ាល់ ខ្ញុំមិនអាចដឹងទេ។

**ស៖** ឥឡូវខ្ញុំសូមអានសម្រង់នៃចម្លើយរបស់គាត់ឲ្យលោកស្ដាប់ ហើយក្រោយមក ខ្ញុំសួរមើលថាតើលោកយល់យ៉ាងម៉េច? មានប្រតិកម្មយ៉ាងម៉េចដែរ។ អ៊ីចឹង គឺឯកសារ E3/976, ERN ជាភាសាអង់គ្លេស 00731171, ខ្មែរ 00728870 ដល់ 71។ មិនទាន់មាន ERN ជាភាសាងបារាំងនៅឡើយទេ។ ឯកសារនេះ គឺ E3/9076 មានវគ្គសួរឆ្លើយសម្រាប់សាក្សីរូបនេះ លោកសាក្សី។ “ចុះ តាជាល? ឆ្លើយ៖ តាជាល គាត់មកជាមួយតាហ៊ីង្ស គឺថា -- តើពួកគេមកជាមួយគ្នាអត់? ជាផ្លូវការគេមកជាមួយគ្នា និយាយគ្នាជាធម្មតា។ ចុះ តាញ៉ឹមៗ ដែលមកទេ? ថា តាញ៉ឹម មក ប៉ុន្តែគាត់មិនដែលចេញពីឡានហ្នឹបទេ។ គាត់មកមែនទេ? គាត់មក ប៉ុន្តែគាត់មិនដែលចេញក្រៅឡានទេ។ មូលហេតុអី? តាញ៉ឹមគឺថាមកជួបតាវ៉ាល់ ហើយគាត់ដើរជុំវិញ។ តាជាល គាត់បាននិយាយថា នៅពេលតាញ៉ឹម មក តាហ៊ីង្សចាត់កម្លាំងបួនទៅប្រាំនាក់ឲ្យការពារគាត់។ តើ តាញ៉ឹម មកញឹកញាប់ទេ? ថាគាត់មកញឹកញាប់នៅពេលដែលមានផែនការ ក្រោយមកគាត់មកទាំងយប់ ទាំងថ្ងៃ មកពេលល្ងាច ជួនកាលមកម៉ោងពីររសៀល។ តើតាញ៉ឹម មកដើម្បីធ្វើអ្វី? ឆ្លើយ៖ គាត់យកស្បែកជើងៗខ្មែរយើង យកមកពីបូព៌ាមកសម្រាប់ឲ្យកងចល័ត។ អ៊ូ! យកស្បែកយើងមក? ឆ្លើយថា៖ ស្បែកជើងស្អាតៗណាស់ ចែកឲ្យពួកយើងខ្ញុំ នៅពេលនោះ គឺថាមានផែនការ។ ខ្ញុំខ្លាចផែនការនេះមែនទែន។ សួរ៖ តើផែនការអ្វីទៅ? ឆ្លើយ៖ នៅពេលតាវ៉ាល់ និយាយក្នុងពេលជាមួយគ្នានោះ គឺថាគេចែកក្រមា ដែកកេះ បារី ជាដើម។ល។ ឲ្យមេដឹកនាំ ហើយនៅពេលថា ពេលមួយគាត់និយាយថា អ្នកឯងទាំងអស់គ្នានេះ គឺសុទ្ធតែជាស័ក្តិ៣ ហើយគាត់ដើរចេញពីកិច្ចប្រជុំទៅ ដោយនិយាយសើចលេងជាមួយកម្លាំង។ គាត់ប្រើប្រាស់ពាក្យពេចន៍ដូច កងទ័ពអ៊ីចឹងផែនការហ្នឹង គឺផែនការភ្នំកូនខ្លែង។ ផែនការនេះមិនបានសម្រេចទេ ប៉ុន្តែខ្ញុំបានដឹងអំពីផែនការហ្នឹង។ មិនមែនជាកិច្ចប្រជុំដើម្បីសម្លាប់មនុស្សទេ ប៉ុន្តែជាប្រជុំដាក់ផែនការ ផែនការសម្ងាត់។ សួរ៖ ឆ្នាំណា? ឆ្លើយ៖ ប្រហែលជាចុងឆ្នាំ៧៧។ តើមានផែនការមែនទេ? គឺថាមានផែនការបំពាក់អាវុធទៅ

ដល់កម្លាំងកងចល័ត ប៉ុន្តែមិនអាចសម្រេចផែនការនោះបាន។ ឧបករណ៍សម្ភារៈមានហើយ ក៏ប៉ុន្តែការរីកចម្រើនអំពីផែនការនេះ មិនដឹងបានទៅមុខប៉ុន្មានទេ យើងវាមិនបានដឹងច្បាស់ទេ។ ដូច្នេះ យើងអត់ចង់និយាយអំពីបញ្ហានេះទេ។ នៅពេលហ្នឹងមានផែនការបែបនោះ ថានឹងបំពាក់អាវុធយើង តើមានបំពាក់អាវុធទេ? គឺថាអាវុធហ្នឹង គឺថាមានបំពាក់មែន ប៉ុន្តែផែនការមិនអាចអនុវត្តបាន ហើយក្រោយមកផែនការនោះក៏ស្ងាត់ទៅ។ អ្នកណាជាអ្នកមកចាប់ខ្លួននៅពេលហ្នឹង? គាត់ថា តាវ៉ាល់ ហើយនិងតាហ៊ីង្ស ត្រូវបានគេចាប់ខ្លួនយកទៅបាត់ទៅ"។

លោកសាក្សី នេះគឺជាសម្រង់របស់សាក្សីម្នាក់ ដែលលោកថាស្គាល់តាវ៉ាល់ ហើយសាក្សីនេះក៏ស្គាល់តាវ៉ាល់។ តើចំណុចនេះ វាអាចធ្វើឱ្យលោកនឹកឃើញដល់រឿងហ្នឹងទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំទាន់អាលឆ្លើយតប! សូមអញ្ជើញលោកសហព្រះរាជអាជ្ញារងអន្តរជាតិ!

[១៤:៤០:៣៣]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

លោកប្រធាន ខ្ញុំជំទាស់នឹងការអាននេះ ពីព្រោះថាជាការពិតណាស់ ដែលសាក្សីបានបញ្ជាក់ថាគាត់ស្គាល់បុគ្គលដែលឆ្លើយ ដែលរៀបរាប់បញ្ហាទាំងអស់នេះហើយ ហើយគាត់ទាំងពីរហ្នឹងស្គាល់តាវ៉ាល់ ក៏ប៉ុន្តែ ភាគីការពារក្ដីមិនបានចោទសំណួរណាមួយទាក់ទងទៅនឹងលើផែនការណាមួយនោះទេ គាត់ចាប់ផ្ដើមអាន កថាខណ្ឌដែលយ៉ាងវែងនៃចម្លើយរបស់សាក្សីហ្នឹង ធ្វើយ៉ាងណាដើម្បីឱ្យនាំមុខចម្លើយសាក្សីដែលនឹងឆ្លើយបន្តបន្ទាប់នេះ។ អ៊ីចឹងខ្ញុំឃើញថា វិធីសាស្ត្រនៃការសួរសំណួរនេះ មិនអាចទទួលយកបានទេ ត្រូវចោទសំណួរបើកជាមុនសិន ហើយបន្ទាប់មកទៀតបានអាចប្រៀបធៀបចម្លើយរបស់គាត់ និងចម្លើយអ្នកផ្សេងទៀត។ នៅក្នុងស្ថានភាពយើងនេះ គឺថារបៀបសួររបស់គាត់នេះ គឺជះឥទ្ធិពលទៅលើសាក្សីហើយ។ អ៊ីចឹងត្រូវតែចាប់ផ្ដើមដោយសួរសំណួរបើកជាមុនសិន មុននឹងអានសម្រង់ដ៏វែងយ៉ាងដូច្នេះជូនសាក្សីស្ដាប់។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំបានសួរសាក្សីហើយ ថាតើគាត់ស្គាល់ ឬក៏ដឹងថាហេតុអ្វីបានជា តាវ៉ាល់ និងតាហ៊ីង្ស ត្រូវបានគេចាប់ខ្លួន? គាត់ថាគាត់មិនដឹងទេ។ ឥឡូវនេះ សាក្សីរូបម្នាក់ផ្សេងនេះ ហាក់ដូចជាផ្ដល់មូលហេតុនៃការចាប់ខ្លួន។ ក្រោយពីសួរថា តើគាត់ស្គាល់សាក្សីរូបនេះ ឬក៏អត់? គាត់ឆ្លើយថា

គាត់ស្គាល់។ ដូច្នេះ ខ្ញុំយល់ថាខ្ញុំអាចមានសិទ្ធិអានសម្រង់នេះ ចេញពីចម្លើយរបស់សាក្សីឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា ឲ្យសាក្សីរូបនេះស្តាប់។

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:៤៣:៣០]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះបដិសេធនូវសេចក្តីជំទាស់របស់សហព្រះរាជអាជ្ញារងអន្តរជាតិ ពីព្រោះរបៀបតាំងសំណួរចុងក្រោយដែលរៀបចំសួរសាក្សីដោយមេធាវីការពារក្តីលោក នួន ជា គឺលោកវ៉ិចទ័រ កូប៉េ។ លោកវ៉ិចទ័រ កូប៉េ អាចតាំងសំណួរបន្តទៀត ចំពោះសាក្សីរូបនេះបានហើយ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សីខ្ញុំបានអានសម្រង់ពីបុគ្គលម្នាក់អម្បាញ់មិញនេះឲ្យលោកស្តាប់ហើយ គាត់និយាយអំពីកិច្ចប្រជុំមួយនោះ ដែល តាវ៉ាល់ ឡើងនិយាយចែកបារី ក្រមា អាវស។ តើវាជួយរំឭកដល់ការចងចាំរបស់លោកទេ ឬក៏លោកមិនចាំអ្វីទាល់តែសោះ?

**លោក ឈុំ សេង៖**

**ឆ៖** បាទ--

**ប្រធានអង្គជំនុំ៖**

មេធាវី កុំអាល លោក វ៉ិចទ័រ កូប៉េ! លោក ហ្សង់ម៉ាក ឡាវែន៍ ដូចមានបញ្ហាអី?

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

[១៤:៤៤:៤០]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ខ្ញុំមានបញ្ហាមួយ ប្រហែលជាបញ្ហាបកប្រែក៏មិនដឹង។ រាល់ពេលដែលលោកសួរសំណួរទៅសាក្សីរាល់ដងនោះ លោកតែងតែនិយាយថា “តើខ្ញុំសួរអ៊ីចឹងនឹកឃើញទេ ចងចាំវិញទេ?” អ៊ីចឹងគួរតែសួរថាតើពិតជាត្រឹមត្រូវដែរឬទេ ប៉ុណ្ណឹងទៅ កុំឲ្យសួរថា “ខ្ញុំនិយាយយ៉ាងដូច្នេះនេះ គឺខ្ញុំអាចធ្វើឲ្យខ្ញុំនឹកឃើញដល់រឿងនោះ ឬក៏អត់?” ព្រោះថាឥឡូវនេះ លោកកំពុងតែសួរផ្ទាញ់សាក្សីហើយ មិនមែនរំឭកការចងចាំគាត់ទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំមិនមានបញ្ហាក្នុងការរៀបចំសំណួរឡើងវិញទេ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី តើលោកមានព្រឹត្តកម្មយ៉ាងម៉េចដែរចំពោះចម្លើយរបស់សាក្សីម្នាក់នេះ?

**លោក ឈុំ សេង៖**

**ឆ៖** បាទ សំណួរនេះ សូមលោកសួរម្តងទៀត។ សូមលោកមានប្រសាសន៍ម្តងទៀតបាទ ខ្ញុំស្តាប់អត់បាន បាទ។

**ស៖** សាក្សីម្នាក់នេះបាននិយាយអំពីកិច្ចប្រជុំ ដែលក្នុងពេលនោះ តាវ៉ាល់ ឡើងនិយាយ។ គាត់និយាយទៅកាន់កងចល័ត ចែកក្រុមា អារស ថាមានផែនការសម្ងាត់ ប៉ុន្តែផែនការសម្ងាត់ហ្នឹងអនុវត្តអត់ចេញ។ តើលោកមានប្រតិកម្មយ៉ាងម៉េចដែរ ឬយល់យ៉ាងម៉េចដែរចំពោះចម្លើយរបស់មនុស្សម្នាក់នេះដែលខ្ញុំអានឲ្យលោកស្តាប់នេះ?

**ឆ៖** បាទ រឿងទាំងអស់ដែលសាក្សីមុននិយាយ ឬក៏ឆ្លើយខ្ញុំបាទមិនដែលដឹង ហើយមិនដែលឮ បាទ មិនដែលដឹងមិនដែលឮ ហើយបើកន្សែងខោអាវ ស្បែកជើង គឺពិតជាបានបើកមែន គឺជាប្រធានវរៈបើកឲ្យ។ តែចំពោះអ្នកនោះដែលមកបើកឲ្យ គឺពុំមានទេ។ ដូច្នេះ ខ្ញុំចង់និយាយបញ្ជាក់បន្តិច ពីរឿងកម្លាំងទៅកូនខ្លែងចំនួន១០០នាក់ គឺខ្ញុំទៅផ្ទាល់ទៅដកកម្លាំងមកវិញ។ ពេលទៅដល់នោះ កម្លាំងទាំងអស់គឺឃើញតែចបទេ បង្គីគឺគ្មាន ឃើញតែចប ទៅដល់ហ្នឹង ទៅបានប្រហែលជាបីបួនខែមិនដឹង វាមិនកំណត់ ខ្ញុំក៏ភ្លេចដែរត្រង់ហ្នឹង។ ទៅគឺឃើញតែនាំគ្នា មានត្រពាំងមួយធំអ៊ីចឹង នាំគ្នាបិទត្រពាំងនោះតែម្តង បិទត្រពាំងនោះ ក៏ធ្វើស្នាចធ្វើអី ក៏បាចៗៗៗ ប៉ុន្តែថ្ងៃបានត្រីគេយកមកកន្លែងវិញ។ ពេលនោះ តាវ៉ាល់ បញ្ជាឲ្យខ្ញុំទៅដកកម្លាំងមកវិញ ខ្ញុំទៅពីរនាក់ឈ្មោះ តូ ។ បាទ ខ្ញុំសូមបញ្ជាក់តែប៉ុណ្ណឹងបាទ។

[១៤:៤៧:៤៥]

**ស៖** បាទ គួរឲ្យចាប់អារម្មណ៍មែនទែន ពេលលោកនិយាយអំពីភ្នំកូនខ្លែងនេះ។ សាក្សីរូបនេះនិយាយថា ផែនការនេះ គឺហៅថាផែនការភ្នំកូនខ្លែង។ ដោយសារខ្លួនលោកផ្ទាល់នេះ ក៏បានឆ្លើយជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា លោកបានឆ្លើយដូចតទៅ ERN គឺ 00728632, បារាំង 01123597, ខ្មែរ 0030798 “សួរ៖ តើមានអ្វីកើតឡើង? លោកឆ្លើយ៖ នៅពេល រស់ ញឹម និង សោ ភឹម ត្រូវបានគេចាប់ខ្លួន គេបានបញ្ជូនមនុស្ស ពីរ-បីរយនាក់ទៅភ្នំកូនខ្លែង ក្រោយមកគេហៅឲ្យមកត្រពាំងថ្មវិញ។”

ដំបូងខ្ញុំសួរផ្នែកមួយនៃឃ្លានេះនៅពេលដែល រស់ ញឹម និង សា ភឹម ត្រូវគេតាមប្រមាញ់ ចង់ លោកចង់និយាយយ៉ាងម៉េចកន្លែងនេះ?

**ឆ៖** រឿងទាំងអស់ហ្នឹង បើសិនជានិយាយដល់ សោ ភឹម គឺខ្ញុំពុំបានដឹងទេ បើត្រឹមតាញឹម ខ្ញុំអាចដឹងខ្លះៗ។ ក៏ប៉ុន្តែ ដែលខ្ញុំនិយាយៗ រស់ ញឹម ទៅជារស់ ញឹម, រស់ ភឹម អីទៅវិញ។ ដូច្នេះការវាយនោះ គឺការខុស គឺមិនត្រឹមត្រូវទេ។

[១៤:៤៩:៤១]

**ស៖** ខ្ញុំមិនច្បាស់ទេ ប៉ុន្តែគ្រាន់នៅក្នុងទំព័រដដែលនេះ លោកនិយាយអំពី តាញឹម និង តាភឹម។ ខ្ញុំឃើញជាភាសាអង់គ្លេសត្រង់ទំព័រដូចគ្នាហ្នឹង ថា តាភឹម និងតាញឹម ខ្មែរមួយទំព័រខាងក្រោយ បារាំងក៏អីចឹង។ តើតាញឹម និងតាភឹម លោកនិយាយពីឈ្មោះនេះពីរដង អំពីឈ្មោះ តាញឹម, តាភឹម នេះ។ ហេតុអ្វីក៏លោកនិយាយពីឈ្មោះ សោ ភឹម?

**ឆ៖** បាទ ញឹម នោះ រស់ ញឹម។ ប៉ុន្តែតាភឹម ហ្នឹង មិនដឹងជាស្អី ភឹម ខ្ញុំអត់ស្គាល់។ ក៏ប៉ុន្តែខ្ញុំថាប្រហែលជាការវាយការណ៍នេះវាខុស។ ខ្ញុំចង់បញ្ជាក់ប្រាប់តែប៉ុណ្ណេះ។ ខ្ញុំពុំដែលនិយាយបានដល់ទៅ សោ ភឹម ឬ តាភឹម ឬតាអីទេ ខ្ញុំមិនដែលបាននិយាយដល់។ ខ្ញុំនិយាយ បើនិយាយត្រឹម រស់ ញឹម ខ្ញុំនិយាយមែន។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ប្រហែលជាដល់ពេលសម្រាកសិនហើយ។ ហើយខ្ញុំនឹងស្វែងរកឯកសារជាភាសាខ្មែរ ថាតើគាត់មាននិយាយអំពីឈ្មោះ សោ ភឹម ឬក៏អត់។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសមស្របសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងបីដប់នាទី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។ មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ រួមទាំងមេធាវីប្រឹក្សារបស់គាត់មកកាន់កន្លែងផ្តល់សក្ខីកម្ម នៅក្នុងបន្ទប់សវនាការនេះ នៅវេលាម៉ោងបី និងដប់នាទី។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១៤:៥១ នាទី ដល់ម៉ោង ១៥:០៩ នាទី)*

[១៥:០៩:២៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដី លោក នួន ជា ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សីនេះ។

បាទ សូមអញ្ជើញ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី មុនពេលឈប់សម្រាកហ្នឹង យើងនិយាយអំពីឈ្មោះ សោ ភឹម។ លោកថា លោកមិនដែលបាននិយាយអំពីឈ្មោះ សោ ភឹម ប្រាប់អ្នកស៊ើបអង្កេតនៃមជ្ឈមណ្ឌលឯកសារកម្ពុជាទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំសូមការអនុញ្ញាតបង្ហាញទៅឲ្យសាក្សីមើលទំព័រជាភាសាខ្មែរនៃចម្លើយរបស់គាត់ជូនមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយនិងសូមសួរទៅសាក្សីរូបនេះ ថាតើគាត់មានបានឃើញឈ្មោះ សោ ភឹម នេះទេ? ហើយថាតើគាត់ពិតជាបានលើកឡើងអំពីឈ្មោះ សោ ភឹម នេះ ឬក៏អត់?

[១៥:១០:៣០]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី ថាតើលោកមានបានឆ្លើយប្រាប់អ្នកស៊ើបអង្កេតអំពីឈ្មោះ សោ ភឹម នេះទេ?

**លោក ឈុំ សេង៖**

**ឆ៖** បាទ ខ្ញុំបាទបាននិយាយត្រឹម រស់ ញឹម ក៏ប៉ុន្តែអក្សរដែលបានវាយចេញនេះ ទៅជា សោ ញឹម, សោ ភឹម។ បើខ្ញុំនិយាយពីរឿង រស់ ញឹម ខ្ញុំនិយាយមែន ក៏ប៉ុន្តែដល់ចេញមកជាអក្សរនេះ ស្រាប់តែចេញ សោ ញឹម, សោ ភឹម។ ដូច្នេះ អត់ត្រូវត្រង់ចំណុចនេះ។ តាញឹម មិនមែនឈ្មោះ សោ ញឹម ទេ

រស់ ញឹម។ ហេតុអីដាក់ សោ? ដល់ទៅ សោ ញឹម, សោ ភឹម។ បានន័យប្រហែលជាចំណុចខុសឆ្គងពីការវាយអង្គុលីលេខនេះ។ បាទ សូមជម្រាប។

[១៥:១២:១៥]

**ស៖** តែនៅខាងក្រោមនៃឯកសារដដែលនេះ ឯកសារនេះសរសេរថា "ដោយសារតែស្ថានភាពមិននឹងនរនេះ ក្រោយមក ខ្ញុំឮសូរ តាញឹម និង តាភឹម បានចាប់ខ្លួន តាជាល និងមនុស្សមួយចំនួនទៀត"។ ក្រោយមកហ្នឹង ក៏លោកនិយាយអំពីឈ្មោះ តាញឹម និង តាភឹម ដែរ យ៉ាងម៉េចដែរ?

**ឆ៖** បាទ ក្រោយមកទៀតហ្នឹង រឿងទាំងអស់ ខ្ញុំបាននិយាយត្រឹម តាញឹម តាអី គឺខ្ញុំបាននិយាយមែន ថាបាត់ខ្លួនបាត់អី គឺខ្ញុំនិយាយមែន។ តែដល់ឈ្មោះ តាភឹម ខ្ញុំមិនដែលបាននិយាយដល់។

**ស៖** បាទ មិនថ្វីទេលោកសាក្សី។ ឥឡូវនេះ ខ្ញុំកម្រិតសំណួររបស់ខ្ញុំតែត្រឹម រស់ ញឹម បានហើយ ប៉ុន្តែលោកពិតជាបានឆ្លើយថា "នៅពេលគេតាមចាប់ខ្លួន សោ ភឹម គេក៏បានបញ្ជូនកម្លាំងពីរ-បីរយនាក់ទៅភ្នំកូនខ្លែង ក្រោយមកក៏ហៅមកត្រពាំងថ្មវិញ"។ តើមានអ្វីកើតឡើងចំពោះមនុស្សដែលគេបញ្ជូនទៅកូនខ្លែងនេះ?

[១៥:១៣:៤៨]

**ឆ៖** បាទ ពេលនោះគឺខ្ញុំឮផ្ទាល់នឹងត្រចៀក នេះជាសម្តី តាវ៉ាល់ ថា តាញឹម បញ្ជូនកម្លាំង២០០ ទៅ៣០០នាក់។ បញ្ជូនទៅដល់ត្រើយហើយ បែរជាបញ្ជូនមកវិញ។ នេះគឺជាសម្តី តាវ៉ាល់ ផ្ទាល់ ដែលខ្ញុំឮនឹងត្រចៀក។

**ស៖** ចុះ តាវ៉ាល់ មាននិយាយថា ហេតុអ្វីបានជា តាញឹម បញ្ជូនកម្លាំង២០០ ទៅ៣០០នាក់នេះទៅកូនខ្លែង?

**ឆ៖** បាទ រឿងទាំងអស់នេះ ខ្ញុំដឹងអត់ដល់ទេ ក៏ប៉ុន្តែគ្រាន់តែឮថា កម្លាំងពី២០០ ទៅ៣០០នាក់នេះ តាញឹម បញ្ជូនជិតទៅដល់កន្លែងហើយ ប៉ុន្តែមិនដឹងទៅដល់កន្លែងណាទេ។ គាត់មិនបានបញ្ជាក់ទេ ក៏ប៉ុន្តែបញ្ជូនមកវិញ។ នេះសម្តីគាត់និយាយប៉ុណ្ណឹង ហើយខ្ញុំឮក៏តែប៉ុណ្ណឹងដែរ។

**ស៖** ឥឡូវនេះ និយាយគ្នាអំពីភ្នំកូនខ្លែងវិញ។ តើភ្នំកូនខ្លែង និងទំនប់ត្រពាំងថ្មនេះមានចម្ងាយប៉ុន្មានគីឡូម៉ែត្រពីគ្នា?

**ឆ៖** បាទ ខ្ញុំមិនបានវាស់ទេ ក៏ប៉ុន្តែស្មាន បើសិនជាទៅផ្លូវត្រង់ វាមិនខុសពីខ្ទង់២០គីឡូលើសខ្ទង់៣០គីឡូហ្នឹង ក៏ប៉ុន្តែបើផ្លូវវាងឆ្ងាយជាងហ្នឹងទៀត។

**សៈ** តើកម្លាំងទាំងអស់នេះគេមានបំពាក់អាវុធឲ្យទេនៅពេលបញ្ជូនទៅភ្នំកូនខ្លែង?

**ធៈ** បាទ ពេលដែលបញ្ជូនទៅកូនខ្លែង ខ្ញុំបាទពុំដឹងច្បាស់ទេ តែពេលដែលឲ្យខ្ញុំទៅហៅកម្លាំងមកវិញ អានោះបានខ្ញុំទៅឃើញពិតនឹងភ្នែកខ្ញុំ គឺឃើញមានតែចបម្នាក់មួយៗហើយត្រឡប់មកវិញ តែត្រង់អាវុធ ខ្ញុំមិនបានឃើញទេ។

**សៈ** ហើយតើកម្លាំងទាំងអស់នេះមានពាក់ព័ន្ធអីជាមួយនឹង តាវិត និង តាស្រេង ទេ?

**ធៈ** បាទកម្លាំងទាំងអស់នេះ ខ្ញុំស្គាល់តាវិតទេ បើស្រេង ខ្ញុំមិនដែលស្គាល់មិនដឹង ស្រេង ណា។

**សៈ** តើ តាវិត ជាបងប្រុសរបស់ តាស្រេង មែនទេ?

**ធៈ** បាទ មិនមែន ស្រេង ទេ គឺស្រេះ –ស-្រ-េះ– បើ េ- ង –ស្រេង– បាទ សូមកែឈ្មោះហ្នឹងបន្តិច។

**សៈ** សូមទោសចំពោះអំនានរបស់ខ្ញុំ។ តើតាវិត ហើយនិង តាស្រេះ ជាបងប្អូនបង្កើតនឹងគ្នាឬ?

**ធៈ** បាទ ពិតជាត្រឹមត្រូវ ព្រោះឈ្មោះ ស្រេះ នេះគឺ --ឈ្មោះវិត នេះគឺបងបង្កើតឈ្មោះស្រេះ។

**សៈ** តើកម្លាំងទាំងអស់នេះ -- បើសិនណាជាមិនដឹងគឺថានិយាយថាមិនដឹង។ តើកម្លាំងទាំងអស់នេះដែលបញ្ជូនទៅភ្នំកូនខ្លែងមានអ្វីពាក់ព័ន្ធជាមួយនឹងផែនការសម្ងាត់ដើម្បីបំពាក់អាវុធដល់កម្លាំងកងចល័តដែរឬទេ តើមានទំនាក់ទំនងគ្នាទេរវាងចំណុចទាំងពីរនេះ?

[១៥:១៨:២៦]

**ធៈ** បាទ រឿងទាក់ទង ខ្ញុំបាទពុំដឹងដល់ទេ។ ក៏ប៉ុន្តែត្រឹមតែការបញ្ជូនកម្លាំង ខ្ញុំដឹងមិនច្បាស់ដែរកន្លែងហ្នឹង ក៏ប៉ុន្តែបើច្បាស់ជាងគេបំផុតដូចខ្ញុំនិយាយរួចមកហើយ ថាខ្ញុំបានទៅគ្រាន់តែ តាវ៉ាល់ប្រើឲ្យទៅដកកម្លាំងមកវិញប៉ុណ្ណោះ តែរឿងពាក់ព័ន្ធអីផ្សេងៗខ្ញុំបាទដឹងអត់ដល់ទេ។

**សៈ** លោកសាក្សី ខ្ញុំសូមសួរផ្ទៀងផ្ទាត់ជាមួយលោកដោយយកសម្ដីរបស់សាក្សីម្នាក់ផ្សេងយកមកសួរលោក។ ខ្ញុំក៏សូមសួរដូចស្រង់សម្ដីសាក្សីដទៃទៀតដែរ គឺសូមឲ្យក្រដាសទៅឲ្យលោកមើលហើយលោកកុំនិយាយពីឈ្មោះរបស់សាក្សីនេះ ហើយបើខ្ញុំសួរថាតើលោកស្គាល់មនុស្សនេះទេ? សូមកុំនិយាយឈ្មោះឲ្យឮតាមក្បាលមីក្រូនេះ។

**លោក វ៉ិចទ័រ កូប៉េះ**

លោកប្រធានគឺឯកសារ E3/7805 ជាពិសេសគឺសម្រង់ត្រង់ភាសាអង់គ្លេស 00277817 ដល់ 18, ខ្មែរ 00267746 និងបារាំង 00315176 ដល់ 77 ហើយនៅត្រង់កន្លែងនេះ គឺខ្ញុំមានជាភាសាខ្មែរ

នៅត្រង់ទំព័រទី១ សូមបញ្ជូនទំព័រទី១ នេះដើម្បីឲ្យគាត់មើល ពិនិត្យមើល តើគាត់ស្គាល់ឬអត់។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី លោកស្គាល់មនុស្សម្នាក់នេះទេ?

**លោក ឈុំ សេង៖**

**ឆ៖** បាទ ខ្ញុំបាទ ពិតជាស្គាល់។

**ស៖** លោកស្គាល់គាត់ច្បាស់ទេ?

**ឆ៖** បាទ ស្គាល់ច្បាស់។

[១៥:២១:១២]

**ស៖** តើគាត់មានតួនាទីដូចលោកដែរអត់ទេនៅពេលនោះ? តើគាត់ជាប្រធានកងដែលគ្រប់គ្រងកម្លាំង១០០នាក់ដែរ ឬក៏គ្រប់គ្រងកងតូចមួយនៅឯការដ្ឋានលើកទំនប់នោះដែរឬទេ? – បាទ មេកងធំ?

**ឆ៖** ឈ្មោះហ្នឹង ខ្ញុំស្គាល់ច្បាស់ណាស់ ក៏ប៉ុន្តែរឿងតួនាទី និងភារកិច្ចរបស់គាត់ ខ្ញុំមិនច្បាស់ថាគាត់ធ្វើអីទេ។ ក៏ប៉ុន្តែក្នុងនាមហ្នឹង ខ្ញុំជឿថាប្រហែលជាថ្នាក់ដឹកនាំក្នុងកងចល័តហ្នឹងដែរ ក៏ប៉ុន្តែមិនដឹងជាកងតូច ឬក៏ធំ ឬក៏អី ខ្ញុំអត់ដឹង។

**ស៖** ខ្ញុំសូមអានសម្រង់មួយចេញពីចម្លើយរបស់គាត់ ហើយសួរទៅលើថា តើលោកយល់យ៉ាងដូចម្តេចដែរ? “សំណួរ៖ តើលោកឃើញថ្នាក់លើចុះមកពិនិត្យការដ្ឋានទំនប់ត្រពាំងថ្មទេ? ថ្នាក់លើកពិតជាបានមកត្រួតពិនិត្យមែន ដូចជាតាជាល ដែលទទួលខុសត្រូវតំបន់៥។ ខ្ញុំបានឮថា គាត់ស្លាប់បាត់ហើយ ហើយតាញ៉ឹម ហៅ មូល សម្បត្តិ ដែលជាឪពុករបស់តាជាល ខ្ញុំឮថាគាត់ស្លាប់បាត់ទៅហើយ។ តាមអ្វីដែលខ្ញុំដឹង តាញ៉ឹម គឺជាដន្លងជាមួយនឹងមេភូមិភាគបូព៌ា ហើយចង់មកបង្កបញ្ហាចលាចលហ្នឹងនៅពាក់កណ្តាលភូមិភាគពាយ័ព្យ គាត់មកពីភូមិភាគបូព៌ា ហើយក្រោយមកក៏ចាប់ភូមិភាគពាយ័ព្យហើយក្រោយមកទៀត ក៏ខាងកម្មាភិបាលភូមិភាគនិរតីក៏មកលើកក្រោយ គឺថាចាប់កម្មាភិបាលនិរតីសម្លាប់ចោលទាំងអស់។ គេហៅទៅប្រជុំនៅឯស្វាយចំនួនពីរដង។ តាញ៉ឹម គាត់ជាអ្នកធ្វើជាធិបតីភាពក្នុងកិច្ចប្រជុំនេះ។” ខាងក្រោមបន្តិច លោកនិយាយចំពោះ ស្រេះ ដែលលោកឡើងឡើងអម្បាញ់មិញគឺថា “គេចាប់គាត់ហើយ បោះគាត់ចូលក្នុងឡាន ហើយដឹកគាត់យកទៅបាត់ទៅ”។ តើ ស្រេះ ជាបងប្រុស

ដែលដឹកនាំកងចល័តរបស់គាត់រត់គេចទៅប្រទេសថៃ។ ខ្ញុំឮសួរថាអ្នកទាំងអស់ហ្នឹងស្លាប់អស់ហើយ។” តើលោកមានប្រតិកម្មយ៉ាងណាដែរ ចំពោះចម្លើយរបស់អតីតសមមិត្តរបស់លោកនេះ ដែលធ្វើជាមេកងធំដែរនោះ?

**ឆ៖** ចំពោះឈ្មោះ រ៉ិត គេនឹង ស្រេះ ជាបងប្អូនបង្កើតមែន តែក្នុងនោះ ដែលគេចាប់ ស្រេះ ហ្នឹង គឺចាប់នឹងមុខខ្ញុំហ្នឹងឯង។ គឺឈ្មោះ ញ៉ាវ ៗនោះ ហៅមកប្រជុំនៅស្ពានទី៣ រួចក៏យោធាចាប់បានក៏បោះដាក់លើឡាន។ ដូច្នេះ ពេលដែលចាប់ ស្រេះ រួចហើយ រ៉ិត, វុយ, ធួន អីហ្នឹងផ្អើលក៏រត់ចេញពីអង្គភាពមិនដឹងទៅណា។ ដូច្នេះ សម្រាប់រូបខ្ញុំក៏មានការបារម្ភដែរ ថាអង្គការពិតជាសាមុងដោយកន្ទេល ហើយមិនដឹងចំអ្នកណាចំអ្នកណីទេ បាទ។ ពេលនោះ គឺខ្ញុំមានការព្រួយបារម្ភ។

[១៥:២៥:១៩]

**ស៖** បាទ វាហាក់ដូចជាអ៊ីចេះលោកសាក្សី ថាមនុស្សទាំងពីរនាក់នេះ ដែលខ្ញុំអានសម្រង់ឲ្យស្តាប់អម្បាញ់មិញនេះ គឺហាក់បីដូចជាដឹងអំពីស្ថានការណ៍នៅការដ្ឋានទំនប់ត្រពាំងថ្មយ៉ាងច្បាស់ ហើយអ្នកទាំងពីរមាននិយាយអំពី តាញឹម ដែលបង្កកម្លាំងពាក់កណ្តាលភូមិភាពពាយ័ព្យ ហើយមានផែនការសម្ងាត់។ នៅពេលខ្ញុំអានសម្រង់នេះ ឲ្យលោកស្តាប់ តើលោកធ្លាប់ឮរឿងនេះដែរទេ?

**ប្រធានអង្គជំនុំ៖**

ដើមបណ្តឹងរដ្ឋប្បវេណី មានបញ្ហាអីអត់មានមករំខានអ្នកដទៃនៅក្នុងសវនាការបានទេ។ រក្សារបៀបរៀបរយស្ងៀមស្ងាត់។ បើត្រូវការមាត់កអីចាំបាច់ សូមចាកចេញពីបន្ទប់សវនាការទៅខាងក្រៅជៀសវាងរំខានដល់កិច្ចដំណើរការនីតិវិធី។

អញ្ជើញបន្តនីតិវិធីលោកមេធាវី រ៉ិចទ័រ កូប៉េ។

**សួរដោយលោក រ៉ិចទ័រ កូប៉េ៖**

**ស៖** បាទ ខ្ញុំនឹងរៀបសំណួរឡើងវិញ។ លោកសាក្សី ខ្ញុំបានអានសម្រង់នៃចម្លើយរបស់មនុស្សពីរនាក់ដែលលោកស្គាល់អ្នកទាំងពីរយ៉ាងច្បាស់ដែលធ្វើការនៅឯទំនប់ត្រពាំងថ្មដែរ ដែលអ្នកទាំងពីរបាននិយាយអំពី ញឹម មេដឹកនាំភូមិភាគពាយ័ព្យដែលបានបង្កភាពចលាចលគឺថា ពាក់កណ្តាលភូមិភាគពាយ័ព្យ ហើយយកកម្លាំងទៅបំពាក់អាវុធ លាក់កម្លាំង ជាមួយ វ៉ាល់ ហើយនិង ហ៊ឹង្ស។ តើមនុស្សពីរនាក់និយាយអ៊ីចឹង លោកដឹងរឿងហ្នឹងដែរ ឬក៏ជារឿងមួយដែលលោកមិនដឹងទេ?

[១៥:២៧:២៨]

**លោក ឈុំ សេង៖**

**ឆ៖** រឿងទាំងអស់ហ្នឹង ខ្ញុំបាទពុំដឹងទេ ខ្ញុំបាទសូមជម្រាប។

**ស៖** ខ្ញុំយល់ហើយ នេះហើយសំណួរចុងក្រោយ បានខ្ញុំបន្តទៅប្រធានបទផ្សេង។ តើលោកអាចពន្យល់ ឬក៏មានការពន្យល់អ្វីមួយថា ហេតុអ្វីបានជាលោកមិនដឹងរឿងនេះ? ដោយសារថាពេលលោកឆ្លើយខាងដើម គឺលោកមានភាពជិតស្និទ្ធជាមួយនឹង តាវ៉ាល់ ខ្លាំងណាស់។ សូមលោកពន្យល់បន្តិចមើលហេតុអីក៏លោកមិនដឹងផែនការនោះ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំទាន់អាលឆ្លើយតប! សូមអញ្ជើញលោកចៅក្រម ក្លូឌា ហ្វេនស៍!

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

មេធាវី នេះជាលើកទី២ហើយដែលលោកសួរសាក្សី ឲ្យពន្យល់នូវអ្វីដែលសាក្សីមិនដឹង។ ខ្ញុំគិតថាការធ្វើបែបនេះ ប្រហែលជាមិនអាចដំណើរការទៅមុខបានទេ លោកគួរតែរៀបសំណួរឡើងវិញ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំអាចពន្យល់ ព្រោះខ្ញុំអត់ចេះនិយាយខ្មែរ អ៊ីចឹងហើយខ្ញុំចង់ដឹងឲ្យគាត់ពន្យល់ហេតុផល ថាហេតុអីបានជាគាត់មិនដឹងរឿងហ្នឹង។ តែយ៉ាងណាក៏ខ្ញុំបន្តទៅមុខទៀតទៅចុះ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី ឥឡូវនេះខ្ញុំសូមសួរលោកអំពីរចនាសម្ព័ន្ធកងទ័ពនៅឯការដ្ឋានលើកទំនប់នោះ នៅក្នុងចម្លើយឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា លោកបាននិយាយអំពីអង្គការចាត់តាំងជាពិសេស គឺថា ដោយយករចនាសម្ព័ន្ធកងទ័ពថ្នាក់ខ្ពស់បំផុតយកមកប្រើ គឺថា កិច្ចការនេះគឺថាទៅជារៀបកម្លាំងរបៀបជារចនាសម្ព័ន្ធកងទ័ព។ លោកក៏និយាយអំពីការគោរពសម្រាប់ការ ការគោរពក្នុងការអនុវត្តតាមបញ្ជា ខ្សែចង្វាក់បញ្ជាណាមួយនោះ។ លោកដឹងមូលហេតុអីទេ បានជាការងារនៅឯការដ្ឋានលើកទំនប់នោះ បែរជារៀបចំបែបជាកងទ័ពបែបនេះទៅវិញ?

[១៥:៣០:០៦]

**លោក ឈុំ សេង៖**

**ឆ៖** បាទ ការរៀបចំដូចជាកងតូច កងធំ កងវរសេនាតូច វរសេនាធំនេះ គឺជាអង្គការជាអ្នករៀប អង្គការជាអ្នកចាត់តាំងឲ្យរៀប ហើយឲ្យហៅឈ្មោះអ៊ីចឹងឯង។ ដូច្នេះ ចល័តគឺមានតួនាទីរែកដី

កាប់ជីកប្រឡាយអីហ្នឹងទេ ក៏ប៉ុន្តែ ត្រង់ចំណុចដែលថារៀបចល័តឲ្យធ្វើជាកងទ័ព ឲ្យធ្វើជាអ្វី គឺខ្ញុំអត់បានដឹងដល់ ខ្ញុំមិនដឹង។ ហើយចំពោះរឿងដែលមិត្តទាំងពីរនាក់នេះ ដែលខ្ញុំស្គាល់ច្បាស់ហ្នឹង ប្រហែលជា ខ្ញុំគ្រាន់តែប្រហែលទេ ប៉ុន្តែខ្ញុំពិបាកនិយាយ គេអ្នកដឹង មិនដឹងគេដឹងមកពីណា មកពីណី ខ្ញុំអត់ដឹងដែរ បើសម្រាប់ខ្ញុំអត់ដឹងរឿងហ្នឹង។

**ស៖** តើខ្ញុំគួរយល់យ៉ាងម៉េចទៅវិញ ចំពោះចម្លើយរបស់លោក ដែលលោកបានឆ្លើយថាខ្សែចង្វាក់បញ្ជាហ្នឹង គឺថាត្រូវតែគោរពតាម។ មានន័យថា នៅពេលដែលលោកបញ្ជាទៅកូនចៅរបស់លោក កូនចៅរបស់លោកត្រូវតែធ្វើតាមបញ្ជារបស់លោកដែរឬ? ហើយនៅពេលដែលលោកទទួលបញ្ជាពីមេរបស់លោក លោកត្រូវធ្វើតាមរបស់លោកដែរឬ? តើលោកចង់និយាយថាយ៉ាងដូច្នេះ ឬយ៉ាងម៉េច?

**ឆ៖** បាទ ត្រឹមត្រូវណាស់ ព្រោះហ្នឹងដូចជា តាវ៉ាល់ បញ្ជាមក តាខូវ តាខូវបញ្ជាមកខ្ញុំ ខ្ញុំបញ្ជាទៅកងតូចក្រោមទៀត ឲ្យអនុវត្តតាមផែនការដែល តាវ៉ាល់ ដាក់ចុះ។ ពិតជាធ្វើយ៉ាងនេះមែន។

[១៥:៣២:០៦]

**ស៖** ឥឡូវនេះ ខ្ញុំយល់ហើយថាលោកធ្លាប់ធ្វើជាទាហានលន់ នល់ ខ្ញុំគិតថាទាហានលន់ នល់ក៏គេត្រូវតែស្តាប់ការបង្គាប់បញ្ជាដែរ។ តើការបញ្ជាបែបរចនាសម្ព័ន្ធកងទ័ពនៅត្រពាំងថ្មនេះ វាដូចគ្នាឬក៏ស្រដៀងគ្នាទៅនឹងរបៀបបញ្ជានៅពេលដែលលោកធ្វើទៅជាទាហានលន់ នល់ដែរឬទេ?

**ឆ៖** សម្រាប់ធ្វើកងទ័ពទាហានលន់នល់ បញ្ជាមែន។ បញ្ជាត្រង់ថា កាំភ្លើងខ្លី គាត់បាននិយាយថាកាំភ្លើងដែលសៀតចង្កេះ មិនមានល្អមើលទេ សម្រាប់បាញ់អាណាដែលមិនស្តាប់បញ្ជាមេ ជាពិសេសសំខាន់នៅលើសមរភូមិប្រយុទ្ធ មិនមែនសៀតយកល្អមើលទេ។ តែគេនឹងសម្លាប់មនុស្ស បើសម្រាប់បញ្ជារបស់ តាវ៉ាល់ នេះគឺបញ្ជាដូចគ្នា បើនរណា បើបញ្ជាហើយនរណាមិនធ្វើតាម គឺត្រូវតែវាយចោលហើយនៅពេលនោះ។ នេះជាបញ្ជារបស់តាវ៉ាល់។

**ស៖** ខ្ញុំយល់ច្បាស់ហើយនូវអ្វីដែលលោកកំពុងតែនិយាយនេះ ប៉ុន្តែនៅចម្លើយឆ្លើយជូនមជ្ឈ-មណ្ឌលឯកសារកម្ពុជា លោកបានឆ្លើយ ខ្ញុំជឿជាក់ថាលោកបានបញ្ជាក់ចំណុចនេះនៅក្នុងសវនាការដែរដែលថាមេដូចជាលោកនេះគឺថាមានសិទ្ធិសម្លាប់។ តើលោកអាចពន្យល់បានទេថា លោកអាចពន្យល់បានទេពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធនៃការបញ្ជាដែលថា ក្នុងឋានៈលោកជាមេកងប៉ុណ្ណឹងតើលោកពិតជាមានសិទ្ធិសម្រេចសម្លាប់នរណាដោយមិនចាំបាច់ស្តាប់បញ្ជាពីខាងលើដែរឬក៏យ៉ាងណា?

**ឆ៖** បាទ ត្រង់ចំណុចហ្នឹង គឺ តាវ៉ាល់ ប្រគល់សិទ្ធិ១ឲ្យថា សម្រាប់មេកងដែលក្តាប់ប្រវត្តិរូប

ជននោះបាន ឬក៏នរណាប្រឆាំងអង្គការ អាចមានសិទ្ធិសម្លាប់បាន ត្រឹមឋានៈប្រធានកងធំ ធំដូចខ្ញុំមានសិទ្ធិសម្លាប់បាន ក៏ប៉ុន្តែចំពោះខ្ញុំនិងកងរបស់ខ្ញុំ គឺពុំដែលបានសម្លាប់មនុស្សទេ។

**ស៖** អ៊ីចឹងថា មាន -- បើការបញ្ជាពីត្រឹមតែ តាវ៉ាល់ មកមេកង ដែលថា គឺគាត់ប្រគល់អាដែងការបញ្ជាបែបដាច់ណាត់អ៊ីចឹង មកឲ្យមេកងអ៊ីចឹង តើអ៊ីចឹង ឬក៏យ៉ាងណា?

**ឆ៖** បាទ ពេលហ្នឹង គឺតាវ៉ាល់ ប្រជុំមេកង មេវរៈទាំងអស់។ លំដាប់ត្រឹមមេកងធំ ដូចខ្ញុំគឺអាចសម្លាប់មនុស្សបាន ឲ្យតែមនុស្សនោះប្រកែកនឹងអង្គការ ហើយមនុស្សនោះប្រឆាំងនឹងបដិវត្តន៍ បាទឬក៏មនុស្សនោះជាទាហានលន់ នល់។ ជាពិសេស សំខាន់បំផុតតាមឲ្យច្បាស់ គឺពួកអាខ្មាំងយួន ហើយនិងពួកអាសេ.អ៊ី.អា របស់ចក្រពត្តិអាមេរិក។ បើចំណុចប៉ុន្មានដែលនេះ គឺចាប់បាន គឺប្រធានកងមានសិទ្ធិសម្រេច គឺសម្លាប់។

[១៥:៣៦:៣៥]

**ស៖** តើសិទ្ធិនេះជាសិទ្ធិដែលចេញមកពីការបញ្ជាដាច់ខាតរបស់ តាវ៉ាល់ តើត្រឹមត្រូវទេ?

**ឆ៖** បាទ ពិតជាត្រឹមត្រូវ។

**ស៖** រួចចុះ តាវ៉ាល់ ហ្នឹងបានទទួលហ្នឹងមកពីណាដែរ? ឬក៏គាត់ចេញបញ្ជាដោយផ្ទាល់ខ្លួនដាច់ខាតពីត្រឹមគាត់នេះ មកមេកងៗដូចជារូបលោកនេះ?

**ឆ៖** បាទ ចំណុចនេះ ខ្ញុំដឹង ខ្ញុំមិនដឹងទេថា តាវ៉ាល់ ទទួលផែនការពីណាទេ។ ខ្ញុំដឹងថាត្រឹមតែរូបខ្ញុំ ព្រមទាំងឋានៈប្រហែលខ្ញុំហ្នឹង គឺទទួលបញ្ជាពី តាវ៉ាល់។ ខ្ញុំដឹងតែប៉ុណ្ណេះទេ។

**ស៖** បាទ ឥឡូវនិយាយអំពីការសម្លាប់មនុស្ស១០ ឬក៏១២នាក់ ដែលលោកបាននិយាយកាលពីម្សិលមិញ។ ប៉ុន្តែដំបូងសូមចាប់ផ្តើមថា តើការសម្លាប់នេះ គេសម្លាប់នៅឯណា? លោកឆ្លើយថាសម្លាប់នៅឯស្ពានទី១។ តើស្ពានទី១ហ្នឹង មានចម្ងាយប៉ុន្មានបើប្រៀបធៀបមកការដ្ឋានលើកទំនប់នេះ?

**ឆ៖** បាទ ស្ពានទី១ហ្នឹង គឺការដ្ឋាននៅជិតទេ ក្បែរៗហ្នឹង ក៏ប៉ុន្តែ ដំណាក់កាលនោះៗដីទំនាបដីវាទំនាប។ ដូច្នេះ យើងត្រូវការលើកកម្ពស់ឲ្យខ្ពស់ជាងទើបបានស្មើត្រឹមហ្នឹង។ ពេលនោះ ដូចខ្ញុំបាននិយាយរួចហើយ តាវ៉ាល់ បញ្ជាផ្ទាល់ឲ្យដុតភ្លើងឲ្យឆេះល្អ គ្នាចំនួន១២នាក់ដុតភ្លើងឲ្យឆេះល្អរួច ពន្លត់អាដែងមានអាណ្តាតភ្លើងពន្លត់ឲ្យនៅតែរងើក។ ហើយទាំង១២នាក់នោះ គឺឈ្មោះ ផន គេជាអ្នកបញ្ជាឲ្យចាប់ដៃកតគ្នា ហើយគេក៏បោះក្រមាមួយឲ្យអាមុខដើរកាន់។ ដើរកាន់មក ដើរឲ្យមកជាន់ភ្លើង ក៏ប៉ុន្តែអា១១នាក់ហ្នឹងវាអត់ដើរជាន់ តែដល់ដើរជាន់ ជាន់អាមួយដែលដើរក្រោយគេ។ ដល់អ៊ីចឹងទៅ វាស្រែក

អាយ៉ូអាយ៉ា វាលែងដៃពីគេ វាមកបោសជើងថា "អ៊ូ!បងភ្លើងក្តៅ ភ្លើងក្តៅ"។ បាទ តែប៉ុណ្ណឹងស្រាប់តែមានឃោធាមកចង១ទៅបាត់ អត់ដឹងទៅណា។ ស្រាប់តែដល់ព្រឹកឡើង ទៅរែកដីចាក់លើកខ្នងទំនប់ ហើយខ្ញុំមិនដែលបានរែកដីហ្នឹងគេទេ គឺខ្ញុំឡើងលើទំនប់ឈូសឆាយកន្លែងណាដែលខ្ពស់មកទាប។ ដល់តែឡើងទៅឈូសឆាយទៅ ឃើញមានរងើកនៅសល់នោះមែន។ បាទ បានខ្ញុំថា អ៊ូ! អា១១នាក់នេះប្រហែលជាគេទុកដាក់នេះយប់មិញហើយយ៉ាង។ នេះខ្ញុំឃើញខ្មោចពិតមែន។

[១៥:៤០:០០]

**ស៖** លោកស្គាល់ឈ្មោះមនុស្ស១១ ឬ១២នាក់ ដែលគេសម្លាប់នេះទេ?

**ឆ៖** បាទ ខ្ញុំអត់ស្គាល់ទេ ក៏ប៉ុន្តែគ្រាន់តែដឹងថា ប្រជាជនដែលជម្លៀសទៅពីទីក្រុងភ្នំពេញ។

**ស៖** តើអ្នកទាំងអស់នេះធ្វើការនៅក្នុងកងមួយណា? តើអ្នកដឹកនាំកងហ្នឹង ឬក៏មេកងហ្នឹង ជាអ្នកណា?

**ឆ៖** បាទ ត្រង់ចំណុចហ្នឹង គឺ១២នាក់ហ្នឹង មិនច្បាស់ថា នៅកងណាច្បាស់លាស់ទេ គឺមួយរោងហ្នឹង បណ្តោយរោងហ្នឹង ដល់ទៅមើល ឲ្យតែឃើញអាណាដែលដេក គឺដកចេញទាំងអស់។ អត់ច្បាស់ថា កង១, កង២, កង៣ ទេ ឲ្យតែដើរទៅឃើញអាណាដែលដេកមិនកាប់ដី គឺត្រូវដកចេញទាំងអស់ ហើយខ្ញុំអត់ច្បាស់ថាតើប្រធានកងគេឈ្មោះអី ឬឈ្មោះអី អត់ដឹង ក៏ប៉ុន្តែដឹងតែចំនួនដែលខ្ញុំរាប់ ដែលខ្ញុំឃើញនឹងភ្នែក។

**ស៖** ប៉ុន្តែលោកដឹងទេ អ្នកណាជាអ្នកបញ្ជាឲ្យសម្លាប់អ្នកទាំងនេះ បើខ្ញុំយល់មិនច្រឡំទេ លោកឆ្លើយថា មេកងគឺថាមានសិទ្ធិសម្លាប់អ្នកណាម្នាក់បាន។ ប៉ុន្តែនេះ សម្រាប់ការសម្លាប់មនុស្សទាំងនេះ តើអ្នកណាជាបញ្ជាឲ្យសម្លាប់?

**ឆ៖** សំណួរនេះ លោកសួរខ្ញុំច្រើនដងហើយ ហើយខ្ញុំបញ្ជាក់ថា មានតែ តាវ៉ាល់ ទេ ដែលបញ្ជាឲ្យសម្លាប់ ក្រៅពីនោះគ្មានអ្នកណាបញ្ជាទេ។

**ស៖** ប៉ុន្តែលោកទើបតែឆ្លើយថា មេកងទាំងអស់នេះ ត្រូវគេប្រគល់សិទ្ធិថា អាចមានសិទ្ធិសម្លាប់មនុស្សបាន ដោយសារខ្លួនជាមេកង ឬក៏ខ្ញុំយល់ច្រឡំ?

**ឆ៖** បាទ ត្រឹមត្រូវណាស់ ប្រធានកងអាចសម្លាប់មនុស្សបាន នេះគឺជាការបញ្ជាមកពី តាវ៉ាល់ គាត់បញ្ជាឲ្យសម្លាប់ ដូចខ្ញុំបានលើកឡើងរួចហើយ ពួកយួន ទាហានលន់នល់, កា.ហ្សេ.បេ, សេ.អ៊ី.អា អ៊ី។ បាទ គឺជាអ៊ីចឹងមែន។

[១៥:៤២:៥៧]

**សៈ** លោកមានស្តាប់ -- តើលោកបានស្តាប់ឮផ្ទាល់ត្រចៀកថា តាវ៉ាល់ ជាអ្នកបញ្ជាទៅដល់អ្នកណាឱ្យសម្លាប់មនុស្សទាំងអស់នោះ។ លោកបានស្តាប់ឮ តាវ៉ាល់ បញ្ជាទេ?

**ឆះ** បាទ ខ្ញុំបាទមិនបានឮទេ ក៏ប៉ុន្តែបើ តាវ៉ាល់ ហៅប្រជុំ គឺខ្ញុំបានចូលប្រជុំ។ ព្រោះចូលប្រជុំហ្នឹង ថ្នាក់ត្រឹមប្រធានកងធំ ឡើងទៅវរៈ គឺ តាវ៉ាល់ ប្រជុំប្រាប់ទាំងអស់។ តែត្រង់ឃើញថា បញ្ជាអ្នកណា ឱ្យបុគ្គលណាមួយសម្លាប់បុគ្គលណាមួយ គឺខ្ញុំមិនដែលឃើញ។ មិនដែលឮ។

**សៈ** ប៉ុន្តែលោកដឹងថា អ្នកណាដែលពិតជាបានប្រាប់ទៅអ្នកដែលសម្លាប់ផ្ទាល់ដៃនោះ អ្នកណាជាអ្នកបញ្ជា ឬក៏ប្រាប់ទៅអ្នកដែលសម្លាប់ផ្ទាល់ដៃនោះ?

**ឆះ** ខ្ញុំអត់ដឹងទេ មិនដឹងថាអ្នកណាជាអ្នកបញ្ជាធំជាង តាវ៉ាល់ ទៀតទេ។ ខ្ញុំដឹងថាត្រឹម តាវ៉ាល់ ប៉ុណ្ណឹង ចុះក្រោម។

**សៈ** ចុះលោកដឹងអ្នកសម្លាប់ផ្ទាល់ដៃទេ? អ្នកសម្លាប់ផ្ទាល់ដៃជាអ្នកណា?

**ឆះ** ត្រង់ចំណុចហ្នឹង ខ្ញុំបាទពុំដឹងទេ ហើយពុំដែលឃើញដែរ។

**សៈ** ចុះធ្វើម៉េចបានជាលោកដឹងថា មានគេបានសម្លាប់មនុស្ស១១នាក់?

**ឆះ** បាទ មនុស្ស១១នាក់ហ្នឹង ព្រោះដូចខ្ញុំជម្រាបហើយថាដឹកៗឱ្យជាន់ភ្លើង អា១១នាក់ហ្នឹងវាអត់ជាន់ បាទហើយអាមួយដែលជាន់វារួចខ្លួនឱ្យទៅដេកវិញ ព្រោះអានេះវាងងឹតមាន់មែន ហើយដល់យកទៅនេះគឺយោធា គេអ្នកយកទៅ អ្នកដែលមានអាវុធ បើនិយាយឱ្យខ្លីទៅ។ យកទៅខ្ញុំក៏អត់ដឹងថាគេយកទៅណា។ ទើបនឹងព្រឹកដែលក្រោករែកដីហ្នឹងទេ បានខ្ញុំទៅឃើញខ្មោចនៅលើខ្នងទំនប់ដែលលុបដីវាអត់ទាន់អស់។ ខ្ញុំមិនដែលរែកដី ដូចខ្ញុំជម្រាបប្រាប់ហើយថាខ្ញុំគ្រាន់តែកកាយ ដីៗណាដែលខ្ពស់ដាក់ទំនាប ដល់ខ្ញុំកកាយទៅ ឃើញខ្មោច។ ដូច្នេះខ្ញុំថាខ្មោចនេះ ខ្មោចអា១១នាក់យប់មិញនេះឯង ព្រោះមើលទៅរងោករងោងៗនៅលើខ្នងទំនប់នេះ។

[១៥:៤៦:០៩]

**សៈ** បាទ អាចត្រូវបានគេសម្លាប់អាច ប៉ុន្តែសាកសពដែលលោកកប់ហ្នឹង ធ្វើម៉េចបានលោកដឹងថាជាមនុស្សតែមួយ ដែលមួយថ្ងៃមុនហ្នឹងត្រូវបានគេសាកល្បងធ្វើតេស្តមើល ចង់ដឹងថាងងឹតមាន់មែនឬក៏អត់នោះ ធ្វើម៉េចបានលោកដឹងថាអ្នកដែលគេសម្លាប់នោះគឺជាអ្នកដែលគេតេស្តដោយសារងងឹតមាន់ហ្នឹង?

**ឆ៖** ពេលហ្នឹង ខ្ញុំក៏នៅហ្នឹងដែរ វាពីកន្លែងដែលធ្វើតេស្តមកកន្លែងដែលកាប់ដី ក៏មិនជាចម្ងាយប៉ុន្មានដែរ បាទ។ ដូច្នេះ ខ្ញុំក៏នៅក្បែរហ្នឹងដែរ បានជាខ្ញុំឃើញហេតុការណ៍ផ្ទាល់ ឃើញ ខ្ញុំបាទឃើញៗត្រឹមតែ អាផន – ឈ្មោះផនទេ ដែលដឹកដៃ បោះក្រមាឲ្យ ដឹកដៃអាមុខ ចាប់ដៃ តែត្រង់ដែលយកពីតាមរោងតាមអីហ្នឹង ខ្ញុំទៅអត់ទាន់ទេ។

**ស៖** ប៉ុន្តែនៅពេលដែលលោកពាក់ព័ន្ធទៅនឹងការពង្រាបខ្នងទំនប់នេះ តើលោកមាននៅចាំ ឬក៏ស្គាល់សពណាមួយថាជាមនុស្សដែលលោកបានឃើញពីមួយថ្ងៃ ពីរថ្ងៃមុន?

**ឆ៖** បាទមនុស្សដែលស្លាប់ហ្នឹងគឺខ្ញុំអត់ស្គាល់ គ្រាន់តែដឹងតែចំនួនប៉ុណ្ណោះ តែបើឲ្យខ្ញុំស្គាល់ថាឈ្មោះ ក, ខ អីគឺខ្ញុំអត់ស្គាល់ទេ ឈ្មោះអីៗ។

**ស៖** សំណួរចុងក្រោយលោកសាក្សី។ តើលោកអាចជួយពន្យល់បន្តិចបានទេថាហេតុអីបានជាលោកអាចសន្និដ្ឋានថាសាកសពទាំងហ្នឹង គឺសាកសពដែលលោកកាយពង្រាបខ្នងទំនប់ហ្នឹងទៅគឺថាជាមនុស្សដដែល ដែលលោកបានឃើញ ហើយថាជាមនុស្សដែលគេយកមកធ្វើតេស្តរឿងងងឹតមាន់ហ្នឹង?

**ឆ៖** ដែលខ្ញុំថាហ្នឹង ព្រោះអ្នកទាំងអស់ហ្នឹង គឺគ្មានខោអាវ ស្លៀកពាក់ទេ ភាគច្រើនគឺអត់មានអាវ ជួនកាលមានតែខោរឹតមួយ ជួនកាលមនុស្សខ្លះមានខោវែង ក៏ប៉ុន្តែអាវគឺគ្មាន អត់មានអាវពាក់ ដល់ខ្ញុំទៅឃើញខ្មោចនោះ គឺអត់អាវទាំងអស់ ច្រងេងច្រងាងនៅហ្នឹង ត្រួតពីលើគ្នា ចាក់ដីលុបខ្លះ លុបជើងនៅខ្លួននៅអី គឺសុទ្ធតែអត់អាវ។ បានខ្ញុំថា អ៊ូ! អានេះអាយប់មិញហើយ។ សំខាន់បំផុតដែលខ្ញុំចំណាំគឺវាអត់អាវ គ្មានអាណាមួយបានពាក់អាវទេ។

[១៥:៤៩:៤០]

**ស៖** តើលោកធ្លាប់ដែលនិយាយទៅកាន់ តាវ៉ាល់ទេ ក្រោយពីរឿងរ៉ាវសម្លាប់ទ្រង់ទ្រាយធំនេះ តើលោកមានដែលបាននិយាយទៅកាន់ តាវ៉ាល់ ទេ? តើលោកមាននិយាយជំទាស់តវ៉ា ឬក៏លោកនិយាយសួរ -- លោកសួរទៅគាត់ថា ហេតុអីបានគាត់ធ្វើយ៉ាងដូច្នេះ ដោយសារតែលោកជិតដិត លោកមាននិយាយជាមួយ តាវ៉ាល់ ទេ?

**ឆ៖** បាទ សូម្បីតែខ្ញុំជិតដិតក៏ខ្ញុំខ្លាច តាវ៉ាល់ ដូចជាបងប្អូនដែរ។ ខ្លាចដូចខ្លា បើស្រួលមិនស្រួលខ្លាចជាងខ្លាទៀតណា៎។ តាវ៉ាល់ ដើរមកពីត្បូង យើងដើរទៅពីជើងបើមានដុប មានអី មានព្រៃ ឬក៏មានព្រៃមានអី បើមិនឈឺជុះអាចម៍ ក៏ត្រូវតែចូលទៅព្រៃជុះអាចម៍ដែរ ព្រោះមិនប៊ានជួបមុខ។ បាទ ដូច្នេះរឿងខ្ញុំ និង តាវ៉ាល់ នេះ គាត់តែងតែហៅខ្ញុំប្រើ ឲ្យទៅនេះទៅនោះ ហើយមកវិញគាត់ក៏ចេះតែសួរ

សម្លុតខ្ញុំ ក្រែងថា ខ្ញុំទៅមិនដល់គោលដៅ។ បានខ្ញុំប្រាប់ថា បងទៅដល់គោលដៅហើយ តែវាមិនឃើញមានអីៗអ៊ីចេះ គឺខ្ញុំបាននេះមាន។ ប៉ាននិយាយតែប៉ុណ្ណោះ។ ក្រៅពីនោះទៀត គេបញ្ជាថាឲ្យទៅ គឺត្រូវតែទៅ។ បញ្ជាឲ្យធ្វើអីត្រូវតែធ្វើនោះ។ បាទ ខ្ញុំគឺប៉ុណ្ណឹងទេ។

**ស៖** ចុះលោកធ្លាប់ដែលឮសួរថា គាត់ជាមនុស្សដែលពាក់ព័ន្ធក្នុងការសម្លាប់មនុស្ស ១១នាក់នេះទេ? តើការសម្លាប់មនុស្ស១១នាក់ វាអាចជាមូលហេតុដែលនាំឲ្យគេចាប់ខ្លួន តាវ៉ាល់ ឬក៏យ៉ាងណា?

**ឆ៖** រឿងដែលចាប់ខ្លួន តាវ៉ាល់នេះ ខ្ញុំបាទយល់មិនដល់ទេ។ មិនដឹងជាចាប់មូលហេតុអី ក៏ប៉ុន្តែដឹងតែត្រឹមនិរតីចូលមក ក៏បាត់ខ្លួន តាវ៉ាល់ តែប៉ុណ្ណោះ។

[១៥:៥១:៥៤]

**ស៖** តើលោកមានបានដឹងការសម្លាប់កម្មករ ពលករ ក្នុងរូបភាពស្រដៀងគ្នានេះទេ ក្រោយពីតាវ៉ាល់ បាត់ខ្លួនទៅ -- បាទ ក្រោយពីតាវ៉ាល់ បាត់ខ្លួនទៅ គឺថាការសម្លាប់មនុស្សនៅការដ្ឋានត្រពាំងថ្មមានការសម្លាប់ដទៃទៀតលំនាំស្រដៀងគ្នានេះទេ?

**ឆ៖** បាទ ចំណុចហ្នឹងខ្ញុំមិនដែលបានឃើញទេ ព្រោះ តាវ៉ាល់ បញ្ជាឲ្យសម្លាប់១១នាក់រួច ខ្ញុំក៏គេត្រូវដកពីអាងត្រពាំងថ្ម មកកាប់ចម្ការកប្បាសនៅភ្នំកងវ៉ា នៅស្រុកសិរីសោភ័ណសព្វថ្ងៃ។

**ស៖** ខ្ញុំជឿជាក់ថា លោកបានឆ្លើយប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជាថា ក្រោយពីគេចាប់ខ្លួនតាវ៉ាល់ ទៅលោកនៅទីនោះបួនទៅប្រាំខែទៀត។ តើលោកពិតជាស្នាក់នៅឯត្រពាំងថ្មបួនប្រាំខែទៀតក្រោយពេលចាប់ខ្លួន តាវ៉ាល់ អ៊ីចឹងឬទេ?

**ឆ៖** បាទ រឿងហ្នឹងពិតណាស់ ពេលដែលចាប់ខ្លួន តាវ៉ាល់ រួច ខ្ញុំនៅបំពេញការងារនៅហ្នឹងចំនួនប្រហែលជាបួន ឬប្រាំខែ។ នៅពេលនោះ គឺនៅធ្វើស្ពាន ដល់ស្ពានវាអត់មានស៊ីម៉ង់ត៍ វាអត់មានដែក មានលួសអីទាំងអស់ គេក៏ដកខ្ញុំឲ្យទៅចម្ការកប្បាស។

**ស៖** ក្នុងរយៈពេលបួនទៅប្រាំខែហ្នឹង លោកនៅតែបន្តធ្វើការលើកទំនប់ហ្នឹងដដែលឬយ៉ាងណាក្រោយពេលចាប់ខ្លួន តាវ៉ាល់ ទៅ ហើយថាតើមានការសម្លាប់ទ្រង់ទ្រាយស្រដៀងៗគ្នានេះទេ ឬក៏ការសម្លាប់ដែលលោកបានឃើញហ្នឹង គឺថាជាការសម្លាប់តែម្តងគត់ដែលលោកធ្លាប់ឮពេញ មួយរយៈកាលនោះ?

**ឆ៖** បាទ ពេលនោះ ដែលគេចាប់ តាវ៉ាល់ ហើយឈ្មោះនៅថ្មី គឺ តានិន និង តាចេង មកពីភូមិភាគនិរតីនេះ ក៏ប៉ុន្តែខ្ញុំក៏ពុំដែលឃើញគាត់សម្លាប់អ្នកណាដែរ ហើយក៏មិនដែលឮថាបញ្ជាឲ្យសម្លាប់

នរណាដែរ។

**លោក វ៉ិចទ័រ កូប៉េះ**

សូមអរគុណលោកសាក្សី។ ខ្ញុំត្រូវចូលទៅប្រធានបទមួយថ្មីតែម្តង តែខ្ញុំមើលទៅឃើញម៉ោងកៀកនឹងម៉ោងបួនហើយលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណៗលោកមេធាវី។

បាទ សវនាការនៅថ្ងៃនេះ ដល់ពេលសមស្របនឹងសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ នៅត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃពុធ ទី១៩ ខែសីហា ឆ្នាំ២០១៥ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ។ សវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងបន្តធ្វើសវនាការស្តាប់សក្ខីកម្មសាក្សី ឈុំ សេង ហើយនិងផ្តើមស្តាប់សក្ខីកម្មសាក្សី ដែលមានរហស្សនាម 2-TCW-908 សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។

អង្គជំនុំជម្រះអរគុណលោក ឈុំ សេង ដំណើរការស្តាប់សក្ខីកម្មរបស់លោកនៅក្នុងឋានៈជាសាក្សីនៅមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះកោះអញ្ជើញលោក មកឲ្យបន្តផ្តល់សក្ខីកម្មនៅថ្ងៃស្អែកទៀតដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ ឥឡូវនេះ លោកអាចសម្រាកបានហើយ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនលោក ឈុំ សេង ត្រឡប់ទៅកាន់កន្លែងដែលគាត់ស្នាក់នៅ ហើយឲ្យសូមអញ្ជើញគាត់មកចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅថ្ងៃស្អែកនៅវេលាម៉ោងប្រាំបួនព្រឹក។ ហើយអង្គជំនុំជម្រះក៏សូមអរគុណលោក ឌុច ផារី មេធាវីប្រឹក្សាសាក្សី អង្គជំនុំជម្រះអញ្ជើញលោកមកចូលរួមសវនាការក្នុងដំណើរការស្តាប់សក្ខីកម្ម ឈុំ សេង នៅថ្ងៃស្អែកទៀត។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប នួន ជា និង ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ទាំងពីររូបត្រឡប់ចូលរួមសវនាការវិញនៅថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៥:៥៧ នាទី)*